# ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

## ក្រសួងមហាផ្ទៃ និងអង្គការ IOM បើកសិក្ខាសាលាថ្នាក់ជាតិស្ដីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

https://www.postkhmer.com/ នៀម ឆេង | Publication date 31 July 2020 | 09:43 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃ និងអង្គការអន្តរជាតិ ទេសន្តរប្រវេសន៍ហៅកាត់ថា IOM បានបើកសិក្ខាសាលាថ្នាក់ជាតិលើកទី ២ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ ស្ដីពីកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ដើម្បីកំណត់គោលបំណងដើម្បីដាក់ចូលក្នុងផែនការសកម្មភាពរបស់កម្ពុជាលើកិច្ចការទេសន្តរប្រវេសន៍។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានថ្លែងថា មុននឹងបើកសិក្ខាសាលានេះ ក្រុមបច្ចេកទេសអន្តរក្រសួងបានជ្រើសរើសគោលបំណងអាទិភាព ៣ រួមមានការធានាថា ជនទេសន្តរប្រវេសន៍មានភ័ស្តុតាងអត្តសញ្ញាណ និងឯកសារគ្រប់គ្រាន់ ការគ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីចង្វាក់គ្នា និងការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូសកលសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងស្របច្បាប់។

លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានប្រសាសន៍ក្នុងពិធីបើកសិក្ខាសាលាថាជនទេសន្តរប្រវេសន៍បានជួបនឹងគ្រោះថ្នាក់ជាច្រើនរួចមកហើយ ហើយក្នុងពេលបច្ចុប្បន្ននេះការធ្វើទេសន្តរប្រវេសន៍រឹតតែប្រឈមខ្លាំងដោយហេតុថា ការរាតត្បាតនៃជំងឺកូវីដ១៩ នៅមិនទាន់ស្ងប់ស្ងាត់នៅឡើយ និងកំពុងកើនឡើងចំនួនអ្នកឆ្លងថ្មីច្រើនរាល់ថ្ងៃនៅក្នុងប្រទេសជាច្រើន។ ស្ថានភាពនេះបានធ្វើឲ្យប្រទេសទទួលពលករ ប្រឈមខ្លាំងទៅនឹងភាពប្រែប្រួលជាអវិជ្ជមាននៃចរន្តសេដ្ឋកិច្ចក្នុងតំបន់ និងសេដ្ឋកិច្ចពិភពលោកដែលជំរុញឲ្យដំណើរការរោងចក្រសហគ្រាស និងវិស័យសេវាកម្មនានារាំងស្ទះ ឬផ្អាកដំណើរការជាបន្តបន្ទាប់។ លោកបន្តថា វិធានការបិទព្រំដែន និងការបិទការនាំចូលពលករបរទេសក៏ជាមូលហេតុចម្បងមួយដែរ ដែលធ្វើឲ្យពលករត្រូវធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ថា តើគួរបន្តស្នាក់នៅក្នុងប្រទេសគោលដៅដោយមិនមានការងារធ្វើ ឬក៏ត្រូវត្រឡប់មកភូមិកំណើតវិញដើម្បីជួបជុំគ្រួសារ។ លោកបញ្ជាក់ថា ចាប់ពីថ្ងៃទី ២១ ខែមីនា ដល់ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០២០ មានពលករកម្ពុជាដែលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ក្នុងអំឡុងពេលកូវីដ១៩ចំនួន ១០៣ ០០០ នាក់ដែលក្នុងនោះស្ត្រីមានចំនួន ៤៥ ភាគរយ។ កម្ពុជាកំពុងសង្គ្រោះពលករដែលបានឆ្លងដែនដោយខុសច្បាប់តាមច្រករបៀង ហើយត្រូវបានចាប់បញ្ជូនមកវិញក្នុងពេលដែលប្រទេសគោលដៅបិទប្រទេស ឬអនុវត្តវិធានការរឹតត្បិតដើម្បីទប់ស្កាត់ការឆ្លងកូវីដ១៩។

លោក ស ខេង ថ្លែងដូច្នេះថា៖ «បន្ទាប់ពីការសម្រេចក្នុងអង្គប្រជុំនេះ ព្រះរាជាណាចក្រកម្ពុជានឹងសម្រេចដាក់បញ្ចូលគោលបំណងដែលជ្រើសរើសបានដាក់ចូលក្នុងផែនការសកម្មភាពសម្រាប់ឆ្នាំជាបន្ទាប់ ដើម្បីធានាថាការធ្វើទេសន្តរប្រវេសន៍របស់ប្រជាជនកម្ពុជាទៅប្រទេសគោលដៅទាំងឡាយក៏ដូចជាជនទេសន្តរប្រវេសន៍ដែលមកពីបណ្ដាប្រទេសក្រៅចូលមកកម្ពុជានឹងប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់»។ លោកស្នើឲ្យសិក្ខាសាលានេះផ្ដោតលើបញ្ហា ៤ គឺការការពារជនទេសន្តរប្រវេសន៍ទាំងជនទេសន្តរប្រវេសន៍ប្រក្រតី មិនប្រក្រតី អ្នកដែលមានគម្រោងចាកចេញទៅធ្វើការនៅក្រៅប្រទេស ទាំងអ្នកកំពុងស្នាក់នៅធ្វើការនៅក្រៅប្រទេស និងអ្នកវិលត្រឡប់មកវិញ។ កិច្ចការដែលត្រូវផ្ដោតការយកចិត្តទុកដាក់ដែរគឺការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រា និងគ្រប់គ្រងឲ្យបានជាក់លាក់នូវទិន្នន័យជនទេសន្តរប្រវេសន៍គ្រប់ប្រភេទ ដើម្បីងាយស្រួលដាក់វិធានការឆ្លើយតបទៅនឹងស្ថានភាពនានាដែលជាភាពប្រឈមរបស់ពលរដ្ឋ និងប្រទេសជាតិ។ លោកបន្តថា សិក្ខាសាលានេះក៏ពិភាក្សាលើដំណើរការ

វិលត្រឡប់ និងធ្វើសមាហរណកម្មជនទេសន្តប្រវេសន៍ដែលក្នុងកិច្ចការនេះត្រូវរៀបចំគោលនយោបាយ វិធានការ និងនីតិវិធីជាក់លាក់ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យលក្ខខណ្ឌនៃការបញ្ជូន ជាពិសេសការកំណត់វិធានការការពារកុមារដែលសង្ស័យថារងគ្រោះ ជាពិសេសដោយអំពើជួញដូរមនុស្ស។ ការកំណត់អត្តសញ្ញាណដោយស្របច្បាប់ ពិសេសសម្រាប់កូនទេសន្តប្រវេសន៍នៅកម្ពុជាដែលបានកើតនៅក្នុងប្រទេសកម្ពុជាក៏ជាកិច្ចការដែលត្រូវពិភាក្សាផងដែរ។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា CENTRAL យល់ឃើញថា ចំណុចអាទិភាពសម្រាប់ពលករចំណាកស្រុក គួរតែផ្តោតលើនីតិវិធីនៃការជ្រើសរើសកម្មករទៅបំពេញការងារនៅក្រៅប្រទេស។ ការចំណាយនៃការជ្រើសរើស និងឯកសារ គួរតែធ្វើឡើងដោយមានតម្លាភាព និងជាការទទួលខុសត្រូវរបស់ភ្នាក់ងារជ្រើសរើស និងបញ្ជូនពលករ។ លោកថ្លែងថា៖ «កាលណាតម្លៃនេះខ្ពស់ពេកធ្វើឲ្យពលរដ្ឋយើងទៅខ្ចីលុយគេ ខ្ចីលុយក្រៅផ្លូវការដូចជាបងប្អូនញាតិមិត្ត អ្នកជិតខាងក្នុងកម្រិតការប្រាក់ខ្ពស់ ឬខ្ចីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បើគាត់ខ្ចីលុយគេ ពេលគាត់ទៅដល់ប្រទេសទទួលភ្នាក់ងារតម្រូវឲ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលគាត់ដើម្បីយកមកបង់ថ្លៃសេវារកការងារឲ្យធ្វើ។ ការធ្វើបែបនេះធ្វើឲ្យមានបំណុល ឬការរក្សាទុកលិខិតឆ្លងដែន ទិដ្ឋាការ វាធ្វើឲ្យរំខានដល់សេរីភាពក្នុងការដើរហើរ បញ្ចេញមតិ ប្រសិនបើគាត់មិនសប្បាយចិត្តនឹងកន្លែងធ្វើការ គាត់អត់ហ៊ានប្រកែក និងតវ៉ា»។ លោកបន្តថា ចំណុចអាទិភាព១ ទៀតគឺការបណ្តុះបណ្តាលដល់ពលករមុនពេលពួកគាត់ចាកចេញអំពីរបៀបធ្វើការ សិទ្ធិ និងកាតព្វកិច្ចរបស់គាត់។ នៅពេលចរចាជាមួយប្រទេសទទួល រដ្ឋគួរតែចរចាលើការការពារពលករ ជាជាងផ្តោតទៅតែចំនួន។ លើសពីនេះក៏ត្រូវមានការធ្វើអធិការកិច្ចដើម្បីដឹងច្បាស់ពីសុខទុក្ខ និងទីតាំងរបស់ពលករ ហើយស្ថានទូតខ្មែរប្រចាំប្រទេសនីមួយៗគួរចុះជួបពលករឲ្យបានញឹកញាប់។ លោកបន្ថែមថា នៅពេលពលករត្រឡប់មកវិញ រដ្ឋក៏គួរជួយដល់ពលករក្នុងការប្រើប្រាស់ជំនាញដែលគាត់ទទួលបានពីការធ្វើការងារនៅក្រៅស្រុក។ «ការចរចាជាមួយប្រទេសទទួល ខ្ញុំគិតថា រដ្ឋគួរផ្តោតលើរឿង ២ គឺយន្តការក្នុងការការពារ និងវិស័យ និងជំនាញដោយយើងរំពឹងថា ពេលពលករយើងត្រឡប់មកវិញ គាត់ក្លាយជាពលករ ឬកម្មករជំនាញសម្រាប់អភិវឌ្ឍស្រុកយើង»៕

## គ.ជ.ប.ជ បើកកិច្ចប្រជុំ ពង្រឹងការងារប្រឆាំងអំពើជួញដូរមនុស្ស

https://m.postkhmer.com/ នៀម ឆេង 31 July 2020 | 11:48 ICT

**ភ្នំពេញៈ** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ បានបើកកិច្ចប្រជុំមួយកាលពីថ្ងៃទី ២៩ ខែកក្កដា ដើម្បីពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លើយតបនឹងការវាយតម្លៃរបស់សហរដ្ឋអាមេរិក បន្ទាប់ពីអាមេរិកដាក់កម្ពុជាក្នុងលំដាប់ទី ២ នៃបញ្ហាជួញដូរមនុស្ស។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាកាលពីកន្លងមកបានអនុវត្តយ៉ាងសកម្មក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប៉ុន្តែទោះជាយ៉ាងនេះក្តី គណៈកម្មាធិការនេះបានកំណត់នូវផែនការបន្តសម្រាប់អនុវត្តក្នុងការពង្រឹងយុទ្ធនាការសកម្មភាពនេះបន្ថែមទៀត ស្របទៅតាមការវិវឌ្ឍក្នុងសង្គមនាពេលបច្ចុប្បន្ន ដើម្បីធ្វើយ៉ាងណាបន្តកាត់បន្ថយ និងឈានទៅលុបបំបាត់អំពើជួញដូរមនុស្សនេះ។

លោក សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃថ្លែងថា ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធរួមទាំងអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការដោះស្រាយអំពើជួញដូរមនុស្ស។ លោកថា កិច្ចប្រជុំកាលពីថ្ងៃពុធធ្វើឡើង ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចការងារ និងការ

រៀបចំរបាយការណ៍ឲ្យឆ្លើយតបទៅនឹងសកម្មភាពជាក់ស្តែងអំពីការខិតខំប្រឹងប្រែងរបស់កម្ពុជាទៅលើការគាំទ្រ និង ចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

កាលពីខែមិថុនា ក្រសួងការបរទេសអាមេរិកបានចេញរបាយការណ៍ឆ្នាំ ២០២០ អំពីស្ថានភាពការជួញដូរមនុស្សនៅទូទាំងសកលលោក។ កម្ពុជាត្រូវបានដាក់ក្នុងបញ្ជីឃ្លាំមើលកម្រិត ២ ដែលជាប្រទេសមិនបានបំពេញតាមស្តង់ដាអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្ស ប៉ុន្តែកំពុងប្រឹងប្រែងយ៉ាងខ្លាំងលើកិច្ចការនេះ។ កិច្ចប្រឹងប្រែងរបស់កម្ពុជារួមមានការផ្តន្ទាទោសជនល្មើស ការបង្កើតផែនការសកម្មភាព ៥ ឆ្នាំក្នុងការប្រឆាំងការជួញដូរមនុស្ស និងការបង្កើត និងប្រើប្រាស់បច្ចេកវិទ្យាប្រមូលទិន្នន័យ និងអត្តសញ្ញាណជនរងគ្រោះ។ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាជារួមមិនបានបង្ហាញកិច្ចប្រឹងប្រែងឲ្យលើសពីឆ្នាំមុនទេ។ អាជ្ញាធរមិនបានប្រឹងប្រែងក្នុងការចែករំលែកព័ត៌មានសំខាន់ៗអំពីការអនុវត្តច្បាប់។ អំពើពុករលួយនៅតែបន្តកើតមានដែលប៉ះពាល់ដល់ការអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌ និងការការពារជនរងគ្រោះ។ អាជ្ញាធរក៏មិនបានស៊ើបអង្កេតលើរបាយការណ៍អំពីការជួញដូរមនុស្សក្នុងសេវាកម្សាន្ត និងនៅតាមឡតដ្ឋ និងមិនបានធ្វើឲ្យប្រសើរឡើង ផ្នែកផ្សេងទៀតនៃការជួញដូរមនុស្ស។ នេះបើតាមរបាយការណ៍ដដែល។

របាយការណ៍របស់អាមេរិកលើកជាអនុសាសន៍ជាច្រើនចំណុច រួមមានឲ្យកម្ពុជាគោរពនីតិវិធីត្រឹមត្រូវស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស។ រដ្ឋាភិបាលគួរអនុញ្ញាតការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតបង្កប់ក្នុងប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស និងត្រូវបង្កើនកញ្ចប់ថវិកាសម្រាប់កិច្ចការនេះ។ របាយការណ៍លើកជាអនុសាសន៍ថា៖ «[កម្ពុជា] ត្រូវតែបង្កើនការធ្វើអធិការកិច្ចដោយមិនប្រកាសមុននៅកន្លែងធ្វើការដែលមានភាពងាយរងគ្រោះខ្លាំង ជាពិសេសនៅឡតដ្ឋ ដលផលកសិដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើច្រវាក់បំណុល»។

លោកស្រី ជូ ប៊ុនអេង បានថ្លែងពីម្សិលមិញថា កម្ពុជាបានប្រឹងប្រែងយ៉ាងខ្លាំង តែមិនអាចឲ្យបានដូចស្តង់ដាទាមទារទេ។ លោកស្រីលើកឡើងថា៖ «ឆ្នាំនេះយើងប្រឈមនឹងកូវីដ១៩ទៀត តែយើងនៅតែប្រឹងប្រែងធ្វើ ប៉ុន្តែរឿងដែលសំខាន់ ការវាយតម្លៃ គាត់មានស្តង់ដាផ្អែករបស់គាត់ ដែលយើងពិបាកនឹងនិយាយ។ ប៉ុន្តែបើថា យើងមិនបានប្រឹងប្រែងគឺអត់ត្រូវទេ។ យើងឆ្ងល់ដែរ យើងបានសរសេរប្រាប់ថា យើងបានធ្វើច្រើនជាងមុន ប៉ុន្តែគាត់ដាក់មកវិញថា វាតិចជាងមុន។ គាត់ថា ការងារខ្លះ អត់ពេញក្នុងស្តង់ដា តែយើងថា វាជារឿងដែលយើងបានធ្វើត្រឹមត្រូវ។ ដូច្នេះយើងឃើញស្តង់ដា ២ បាត់ហើយ»៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០៨នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 02-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៨នាក់ ស្រី ០២នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១១៩នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 02-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១១៩នាក់ ស្រី ៥០នាក់ និងកុមារ ១៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៧នាក់ ស្រី ៥៦នាក់

https://www.facebook.com/GDIOfficial 02-08-2020

នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៧នាក់ ស្រី ៥៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៤នាក់ ស្រី ០២នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ១១នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 01-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១១នាក់ ស្រី ០៥នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៦៥នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 01-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦៥នាក់ ស្រី ៣២នាក់

និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤៣នាក់ ស្រី ៥៤នាក់

https://www.facebook.com/GDIOfficial 01-08-2020

នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន១៤៣នាក់ ស្រី៥៤នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៤នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 31-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៤នាក់ ស្រី ២០នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥២នាក់

https://www.facebook.com/GDIOfficial 31-07-2020

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥២នាក់ ស្រី ១៤នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 31-07-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ ស្រឹម ស៊ីម ភេទប្រុស អាយុ ២៩ឆ្នាំ មានទីលំនៅភូមិគោកចា ឃុំគោកស្រុក ស្រុកជំបែ ខេត្តត្បូងឃ្មុំ, ២-ឈ្មោះ ចាន់ ថន ភេទប្រុស អាយុ ២៩ឆ្នាំ មានទីលំនៅភូមិ០៤ ឃុំពាមក្រសោព ស្រុកមណ្ឌលសីមា ខេត្តកោះកុង, ៣-ឈ្មោះ អ៊ុំ ទូច ភេទប្រុស អាយុ ៨២ឆ្នាំ មានទីលំនៅភូមិថ្មី ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង, ៤-ឈ្មោះ សាត គាំង ភេទប្រុស អាយុ ២៦ ឆ្នាំ មានទីលំនៅភូមិព្រៃករូង ឃុំជំរីពួក ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង និង ៥-ឈ្មោះ ខេង សារ៉ាត់ ភេទស្រី អាយុ ៣៦ឆ្នាំ មានទីលំនៅភូមិត្បែងពក ឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត ដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## សមត្ថកិច្ចឆែកឆេរហាងម៉ាស្សា បង្កប់រកស៊ីផ្លូវភេទមួយកន្លែង នៅពោធិ៍សាត់ ឃាត់ខ្លួន១២នាក់

http://www.freshnewsasia.com/ 2020-08-02 12:09pm

**(ពោធិ៍សាត់)៖** សមត្ថកិច្ចក្រុងពោធិ៍សាត់ បានចុះឆែកឆេរហាងម៉ាស្សា បង្កប់រកស៊ីផ្លូវភេទមួយកន្លែង ដោយឃាត់ខ្លួនជនសង្ស័យប្រុសស្រីចំនួន ១២នាក់ និងដកហូតឧបករណ៍ប្រើប្រាស់សារធាតុញៀន និងវត្ថុតាងប្រព្រឹត្តបទល្មើសមួយចំនួនទៀត។ ប្រតិបត្តិការខាងលើ ធ្វើឡើងនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ នៅចំណុចផ្ទះជួលហាងម៉ាស្សា បង្កប់រកស៊ីផ្លូវភេទមួយកន្លែង មុំស្ពានឈើចាស់ ស្ថិតនៅភូមិបន្ទាយដីលើ សង្កាត់បន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ប្រតិបត្តិការនេះ ធ្វើឡើងដោយកម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាលបន្ទាយដី ដឹកនាំ និងបញ្ជាផ្ទាល់ ដោយលោក កួយ កាន់យ៉ា ព្រះរាជអាជ្ញា នៃអយ្យការ អមសាលាដំបូងខេត្តពោធិ៍សាត់។

**សេចក្តីរាយការណ៍ បានឱ្យដឹងថា ក្នុងប្រតិបត្តិការខាងលើ សមត្ថកិច្ច ក៏បានដកហូតវត្ថុតាង រួមមាន៖**

* ម្សៅក្រាមពណ៌សថ្លា ចំនួន០៤កញ្ចប់តូច
* ថង់ផ្លាស្ទិចមួយចំនួន
* ដែកកេះ ចំនួ ន០៣ដើម
* ឧបករណ៍ជក់មួយកំប្លេ
* ទូរស័ព្ទដៃ ចំនួន០៣គ្រឿង
* ម៉ូតូ ចំនួន០៣គ្រឿង
* ស្លាកលេខម៉ូតូ ចំនួន០១សន្លឹក
* កូនកាបូបពណ៌ខ្មៅ ចំនួន០២
* កាបូបស្ពាយចំហៀងពណ៌ខ្មៅ ចំនួន០១

* កាំភ្លើងកៃច្នៃ(ប្រើស្នប់) ចំនួន០២ដើម

* បំពង់ទុយោបិតចំនួន០១បាច់។

បច្ចុប្បន្នជនសង្ស័យទាំង ១២នាក់ខាងលើ រួមទាំងវត្ថុតាងទាំងអស់ ត្រូវបាននាំយកទៅអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ ដើម្បីបន្តនីតិវិធី៕

## ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០

### នគរបាលប៉ុស្តិ៍ឃ្សឹមចុះផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈ

http://cambodiapolice.com/policekh/ 4:24 pm 3 សីហា 2020

ក្រចេះ ៖ ព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្សឹម បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីវេទិកាសាធារណៈថ្នាក់ជាតិ នៅភូមិដូង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។ វេទិកានេះក្រោមអធិបតីភាព ឯកឧត្តម លី ផល្លា រដ្ឋលេខាធិកាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រុមការងារថ្នាក់ជាតិ-ថ្នាក់ខេត្តចុះជួយស្រុកស្នួល ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយ និងចែកខិត្តបណ្ណរួមមាន៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

-ចែកសារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន។

-ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សា ទាក់ទងនឹងយេនឌ័រ, អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ ។

នៅក្នុងនោះ កម្លាំងយើងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាង របស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ៕

### វេទិកាសាធារណៈ និង ជួបសំណេះ សំណាល ទទួលសំណូរ និងសំណូមពរ របស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងស្រុកស្រីស្នំ ខេត្តសៀមរាប !

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 3 ខែ សីហា ឆ្នាំ 2020

សៀមរាប៖ នាព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២០ នៅវិទ្យាល័យ ២៨មករា ស្រុកស្រីស្នំ មានរៀបចំវេទិកាសាធារណៈ និងសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តម ស៊ាន បូរ៉ាត រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលចុះជួយស្រុក

ស្រីស្នំ មានការចូលរួមពី សមាជិក សមាជិកា ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះជួយស្រុកស្រីស្នំ លោកអភិបាលស្រុកស្ដីទី មន្ត្រី កងកម្លាំងទាំង៣ប្រភេទ ព្រមទាំងលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សជាច្រើនរូប។

ក្នុងវេទិកានោះ ឯកឧត្តម ប្រធានក្រុមការងារ បានផ្តោតសំខាន់ទៅលើការទប់ស្កាត់ការឆ្លងរីករាលជំងឺកូវីដ-១៩ ក្នុងស្រុកស្រីស្នំ ខណៈស្រុកមួយនេះ នៅតែបន្តមានប្រជាពលរដ្ឋចេញចូលទៅធ្វើការនៅបរទេស ជាពិសេសប្រទេសថៃ ទោះបីមានការហាមប្រាមពីរាជរដ្ឋាភិបាលក៏ដោយ។ ឯកឧត្តម បានណែនាំដល់រដ្ឋបាលស្រុក និងគណៈគ្រប់គ្រងវិទ្យាល័យ ២៨មករា ដែលជាវិទ្យាល័យគម្រូ ត្រូវរៀបចំយុទ្ធនាការផ្សព្វផ្សាយមួយ ដោយរៀបចំសិស្សានុសិស្ស និងយុវជនក្នុងស្រុក ធ្វើការណែនាំដល់ប្រជាពលរដ្ឋនៅតាមភូមិ-ឃុំ ក្នុងស្រុក ដើម្បីឲ្យពួកគាត់ទទួលបានព័ត៌មានបន្ថែមអំពីជំងឺកូវីដ១៩ នាពេលបច្ចុប្បន្ន និងបញ្ឈប់ការទៅធ្វើការដោយខុសច្បាប់នៅបរទេសអំឡុងពេលនៃជំងឺកូវីដ-១៩។

ជាមួយនោះ ឯកឧត្តម ប្រធានក្រុមការងារ ក៏បានទទួលសំណួរ និងសំណូមពរ ចំនួន១០ ពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ការខ្វះខាតប្រព័ន្ធអគ្គិសនីក្នុងភូមិ-ឃុំមួយចំនួន ការធ្វើអត្តសញ្ញាណបណ្ណមានរយៈពេលយូរ ភាពមិនប្រក្រតីការផ្តល់បណ្ណក្រីក្រដល់ប្រជាពលរដ្ឋ ។ សំណួរទាំងអស់នោះ ត្រូវបានដោះស្រាយដោយមន្ត្រីជំនាញ និងមានការទទួលយកពីម្ចាស់សំណួរ ចំពោះបញ្ហាដីធ្លី និងអគ្គិសនី ឯកឧត្តមបានជម្រាបជូនប្រជាពលរដ្ឋថា ការងារទាំងអស់នេះ ត្រូវការរយៈពេលដោះស្រាយបន្តទៀត ដែលមានអង្គភាពជំនាញចូលរួម ក្នុងនោះឯកឧត្តម ក៏បានសំណូមពរដល់ មន្ទីរ និងអង្គភាពជំនាញ ជួយពន្លឿនការចុះសិក្សា ក៏ដូចជាដោះស្រាយជូនប្រជាពលរដ្ឋឲ្យបានឆាប់រហ័ស។

ដោយឡែក ចំពោះសំណើសុំហេដ្ឋារចនាសម្ព័ន្ធក្នុងវិទ្យាល័យ ២៨ មករា ការសាងសង់ផ្ទះស្នាក់លោកគ្រូអ្នកគ្រូ និងបង្កើតភូមិ ឃុំថ្មី តាមរយៈភូមិឧបសម្ព័ន្ធដែលមានស្រាប់របស់ស្រុក ឯកឧត្តមប្រធានក្រុមការងារ បានជម្រាបថា សំណើរមួយចំនួនត្រូវបានបញ្ជូនទៅកាន់រាជរដ្ឋាភិបាលរួចរាល់ហើយ ប៉ុន្តែដោយសារបញ្ហាជំងឺកូវីដ-១៩ សំណើទាំងនោះត្រូវការរយៈពេល ដើម្បីសម្រេចជាក្រោយ។ ទន្ទឹមនោះ ឯកឧត្តម ក៏បានឧបត្ថម្ភថវិកាផ្ទាល់ខ្លួនចំនួន ១លានរៀល សម្រាប់សិស្សស្ម័គ្រចិត្ត ទិញសម្ភារៈបណ្ណាល័យស្ថិតក្នុងឃុំជ្រោយនាងងួន និងឃុំប្រិយ៍៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ៥០នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 03-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៥០នាក់ ស្រី ១៥នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធនធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៥៣នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 03-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៣នាក់ ស្រី ២៥នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៤២នាក់

https://www.facebook.com/GDIOfficial 03-08-2020

នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន១៤២នាក់ ស្រី៥៧នាក់៕

## ពិតជាលឿនពេកហើយប្រពន្ធខ្ញុំ! នេះជាសម្តីខ្លោចផ្សាររបស់ប្តី

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ០៨:៥៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ-ប៉ោយប៉ែត ៖ យោងតាមអាក់ខោនហ្វេសបុកបុរសជាប្តីបង្ហោះថា «**ពិតជាលឿនពេកហើយប្រពន្ធខ្ញុំ**» ។ ហើយតាមព័ត៌មានមុននេះថា ប្តីរបស់ស្ត្រីរងគ្រោះបានទៅជួបមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសុំឱ្យជួយក្នុងរឿងយកសពប្រពន្ធត្រឡប់ពីបាងកកវិញ ប៉ុន្តែត្រូវមន្ត្រីណែនាំនិងឱ្យទាក់ទងទៅមន្ត្រីស្ថានទូតប្រចាំប្រទេសថៃ ដើម្បីឱ្យរៀបចំឯកសារដែលមានទាំងលេខទូរស័ព្ទផងដែរ ។ សូមបញ្ជាក់ថា មនុស្ស៤នាក់បានបាត់បង់ជីវិតក្នុងថ្លុកឈាម ដោយសារការបាញ់ប្រហារមួយ ដែលមិនទាន់ដឹងពីមូលហេតុនៅឡើយ នៅក្នុងទីក្រុងបាងកក កើតឡើងកាលពីម៉ោងជាង១១យប់ថ្ងៃទី៣ សីហា ។

នេះបើយោងតាមកាផ្សាយរបស់គេហទំព័រ និងកាសែតក្នុងស្រុកថៃមួយ។ ប្រភពបន្តថា ប្រុស៣ ស្រីម្នាក់ ដែលជាស្ត្រីរងគ្រោះខាងលើ គេដឹងច្បាស់ថា ជាជនជាតិខ្មែរទៅបំរើការងារផ្នែកអនឡាញនៅទីនោះ។ ស្ត្រីរងគ្រោះខាងលើ មានឈ្មោះម៉ៅ ស្រីពៅ អាយុ២៩ឆ្នាំ រស់នៅភូមិក្បាលស្ពាន១ សង្កាត់ និងក្រុងប៉ោយប៉ែត និងមានទីលំនៅឃុំអន្លង់រុន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ ស្ត្រីរងគ្រោះមានកូនប្រុសម្នាក់អាយុជាង១ខួប។ ពេលនេះ បុរសជាប្តី និងសាច់ញាតិកំពុងស្វះស្វែងរកការអន្តរាគមន៍ជួយពីស្ថាប័នពាក់ព័ន្ធធ្វើយ៉ាងណា ដើម្បីទទួលយកសពត្រឡប់មកស្រុកកំណើតធ្វើបុណ្យតាមប្រពៃណីយ៍។ បើតាមប្រភពបញ្ជាក់ថាករណីបាញ់ប្រហារនេះ ដំបូងមានស្នូរផ្ទុះអាវុធជា

ច្រើនគ្រាប់បន្ទាប់មកក៏ស្ងប់ស្ងាត់ទៅវិញ។យ៉ាងណា ក៏ដោយករណីខាងលើគេមិនទាន់ដឹងពីមូលហេតុពិតប្រាកដនៅឡើតទេព្រោះជនសង្ស័យក្រោយបាញ់រះបានគេចខ្លួនបាត់។ ព័ត៌មានបន្ថែមកោះសន្តិភាពនឹងមានផ្សាយជូនបន្ត ។

## ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០

## ឃុំខ្លួនជនត្រូវចោទ ២នាក់ ប្តី-ប្រពន្ធ ពីបទនាំពលករជនជាតិបង់ក្លាដេស១៦នាក់ មកធ្វើការនៅស្រុកខ្មែរ ដោយខុសច្បាប់

https://www.cen.com.kh/ August 4, 2020

ភ្នំពេញ ៖ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០នេះ លោក ម៉ៅ ស៊ីណា ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទ ២នាក់ ប្តី-ប្រពន្ធ (ជនជាតិបង់ក្លាដេស និងជនជាតិខ្មែរ) ពីបទនាំចេញដោយមិនស្របច្បាប់ និងជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២០។

កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យដឹងថា យោងតាមពាក្យបណ្តឹងរបស់ជនជាតិបង់ក្លាដេស ៤នាក់ តំណាងឲ្យជនរងគ្រោះ១៦នាក់ជនជាតិបង់ក្លាដេស នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ កម្លាំងការិយាល័យជំនាញបានធ្វើការឃាត់ខ្លួនជនសង្ស័យ ២នាក់ (ប្តី-ប្រពន្ធ)៖ ឈ្មោះ MOHAMMAD JAHNGIR ភេទប្រុស ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិបង់ក្លាដេសនាយកក្រុមហ៊ុន CEB BIC CIES CO,Lld ទីលំនៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និងប្រពន្ធឈ្មោះ ម៉ម សុខុម អាយុ២៧ឆ្នាំ ទីលំនៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្មគោល២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ។ សមត្ថកិច្ច បានឲ្យដឹងទៀតថា កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២០ ជនរងគ្រោះទាំង១៦នាក់ បានចេញពីប្រទេសបង់ក្លាដេស ចូលមកដល់ប្រទេសកម្ពុជា តាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមរយៈក្រុមហ៊ុនឈ្មោះ CEB BIC CIEB CO.LTD អាសយដ្ឋាននៅ ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញដែលមានឈ្មោះ MOHAMMAD JAHANGIR ជានាយកក្រុមហ៊ុន ពេលមកដល់ត្រូវឈ្មោះ MOHAMMAD JAHANGIR នាំទៅស្នាក់នៅបណ្តោះអាសន្ននៅផ្ទះមួយក្បែរស្នាក់ការក្រុមហ៊ុន សន្យារកការងារឲ្យជនរងគ្រោះធ្វើបានប្រាក់ឈ្នួល៤៥០ដុល្លារអាមេរិកក្នុងមួយខែ និងធ្វើទិដ្ឋាការការងាររយៈពេលមួយឆ្នាំ និងផ្តល់កន្លែងស្នាក់នៅ។

មុនពេលចេញពីប្រទេសបង់ក្លាដេស ឈ្មោះ MOHAMMAD JAHANGIR បានឲ្យជនរងគ្រោះបង់លុយឲ្យក្នុងម្នាក់ៗ ចំនួន៣០០០ដុល្លារអាមេរិក សម្រាប់ថ្លៃសំបុត្រយន្តហោះ និងទិដ្ឋាការងារ ហើយបានបោកប្រាស់ធ្វើកាត EMIGRATION CLEARANCE CARD ចេញដោយក្រសួងការងារបង់ក្លាដេស ប្រគល់ឲ្យជនរងគ្រោះកាន់។ ពេលមកដល់ប្រទេសកម្ពុជា បានឲ្យជនរងគ្រោះម្នាក់ៗបង់លុយបន្ថែមចំនួន៥០០ដុល្លារអាមេរិកទៀត និងបានប្រមូលយកលិខិតឆ្លងដែន និងកាត EMIGRATION CLEARANCE CARD ទុកដោយកាតនោះក្លែងក្លាយមិនអាចសុំធ្វើទិដ្ឋាការប្រភេទE វីសាការងារ (VISA-E) បានទេ គឺធ្វើបានតែទិដ្ឋាការប្រភេទT វីសាទេសចរណ៍ (VISA-T) ប៉ុណ្ណោះ។ បន្ទាប់មកឈ្មោះ MOHAMMAD JAHANGIR បានចាត់ចែងនាំឲ្យជនរងគ្រោះទៅធ្វើការនៅការដ្ឋានសំណង់នានានៅកម្ពុជា មិនបានទទួលប្រាក់ឈ្នួលពេល។

សមត្ថកិច្ច បានបន្តថា ជនរងគ្រោះ១៦នាក់ (ជនជាតិបង់ក្លាដេស) ត្រូវបានឈ្មោះ Mohammad Jahangir និងប្រពន្ធ ព្រមទាំងបក្ខពួកឈ្មោះ Zahorul Modal ភេទប្រុស អាយុប្រហែល៤០ឆ្នាំ ដែលមានអសយដ្ឋាន village Shikol Post Narnotto. P.S: Kahaloo District Borgra Bangladesh និងឈ្មោះ Shajahan ភេទប្រុស អាយប្រហែល៤០ឆ្នាំ ជនជាតិបង់ក្លាដេស រស់នៅប្រទេសបង់ក្លាដេស បានធ្វើសកម្មភាពឃោសនា ជ្រើសរើសសន្យាឲ្យប្រាក់ឈ្នួលចំនួន៤០០-៤៥០ដុល្លារអាមេរិកក្នុង១ខែៗ ពេលមកធ្វើការងារនៅកម្ពុជា។ ដោយបាន

យកប្រាក់មុនមកកម្ពុជាក្នុងម្នាក់ៗចំនួន៣០០០ដុល្លារអាមេរិក, ពេលមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ យកប្រាក់បន្ថែម៥០០ដុល្លាក្នុងម្នាក់ៗ, បានបញ្ជូនជនរងគ្រោះធ្វើការតាមការដ្ឋានសំណង់នានា គ្មានប័ណ្ណការងារ (Work Permit) ខុសច្បាប់ការងារនៅកម្ពុជា និងអត់បើកប្រាក់ឈ្នួល (កេងប្រវ័ញ្ចពលកម្ម), កម្ពុជាមិនមានច្បាប់អនុញ្ញាត ឬកិច្ចព្រមព្រៀងឲ្យមានការជ្រើសរើសបញ្ជូនពលករ ពីប្រទេសបង់ក្លាដេស ចូលមកធ្វើការនៅប្រទេសកម្ពុជានោះទេ។ សមត្ថកិច្ច បានបន្តទៀតថា វត្ថុតាងដកហូតមានលិខិតឆ្លងដែន ចំនួន២៤ក្បាល។

បច្ចុប្បន្នជនត្រូវចោទទាំង២នាក់ ប្តី-ប្រពន្ធ ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ម១) និងមណ្ឌលអប់រំកែប្រែទី២(ម២)៕ **ដោយៈបញ្ញាស័ក្តិ**

## ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងស្ថានទូតអូស្ត្រាលី ពង្រឹងកិច្ចសហប្រតិបត្តិការ ជាពិសេសលើផ្នែកច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងការប្រឆាំងនឹងអំពើហិង្សាទៅលើស្ត្រី

http://www.freshnewsasia.com/ 2020-08-04 10:24pm

**(ព្រះសីហនុ)៖** នារសៀលថ្ងៃអង្គារទី៤ ខែសីហា ឆ្នាំ២០២០ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្ត និងលោក Pablo Kang ឯកអគ្គរាជទូតប្រទេសអូស្ត្រាលីប្រចាំកម្ពុជា បានជួបពិភាក្សាការងារ នៅក្នុងឱកាសដែលលោកចូលបំពេញការងារនៅកម្ពុជា។

នៅក្នុងជំនួបនោះ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ សម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ដោយបានសម្តែងនូវក្តីសង្ឃឹមថា លោកនឹងបន្តការងារក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ លើគ្រប់វិស័យរវាងប្រទេសទាំងពីរបន្តទៅទៀត។ ឆ្លៀតឱកាសនេះ លោកឧត្តមសេនីយ៍ស្នងការ ក៏បានសម្តែងនូវអំណរគុណចំពោះការជួយឧបត្ថម្ភ គ្រប់បែបយ៉ាង ហើយនិងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យដែលរដ្ឋាភិបាលអូស្ត្រាលី បានផ្តល់ ចំពោះកម្ពុជា ជាពិសេសលើវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ជនបទ ផ្នែកច្បាប់ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការប្រឆាំងនឹងអំពើហិង្សាទៅលើស្ត្រី ។ល។ លោកឧត្តមសេនីយ៍ស្នងការ បានវាយតម្លៃខ្ពស់ចំពោះជំនួបនេះដែលនឹងរឹតបន្តឹងបន្ថែមនូវ ទំនាក់ទំនងការងារដ៏ជិតស្និទ្ធរវាង ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងស្ថានទូតអូស្ត្រាលី ជាពិសេសលើផ្នែកច្បាប់ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការប្រឆាំងនឹងអំពើហិង្សាទៅលើស្ត្រី ។ល។ និងបានសម្តែងនូវក្តីសង្ឃឹមថា ឯកឧត្តមឯកអគ្គរាជទូតនឹងបន្តនូវទំនាក់ទំនងដ៏ល្អប្រសើរនេះ៕

## ឃាត់ខ្លួនពលករខ្មែរឆ្លងដែនទៅថៃខុសច្បាប់ចំនួន៧នាក់

http://nokorwatnews.com/ 04-08-2020

ខេត្តបន្ទាយមានជ័យ ៖ ពលករប្រុស ស្រីចំនួន៧នាក់ ត្រូវកម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនសង្កែល្បាតឃើញនៅវេលាម៉ោង៤ល្ងាច ថ្ងៃ ទី៣ ខែសីហា ឆ្នាំ ២០២០ ក្នុងភូមិសាស្រ្ត ប៉ុស្តិ៍សង្កែ ចំណុចភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បន្ទាប់ពី បានចាញ់បោកមេខ្យល់ថា ជូនទៅស្រុកថៃរកការងារកន្លែងល្អៗឲ្យធ្វើ ។

លោកវរសេនីយ៍ត្រី ឡុក ជី នាយនគរបាលប៉ុស្តិ៍ការពារព្រំដែនសង្កែបានប្រាប់ឲ្យដឹងថា នៅល្ងាចថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ លោកបានដឹកនាំនគរបាលជាច្រើននាក់ចុះល្បាតនៅចំណុចភូមិសាស្រ្តសង្កែ ស្រាប់បានប្រទះឃើញពលករ ប្រុស ស្រីចំនួន៧នាក់ បម្រុងលួចឆ្លងដែនខុស ច្បាប់ទៅរកការងារធ្វើនៅ ប្រទេសថៃខណៈដែលគេដឹងថា មកដល់ពេលនេះសមត្ថកិច្ចថៃមិនទាន់បានឲ្យដំណឹងថា តម្រូវការកម្មករធ្វើការនោះទេដោយសារជំងឺ កូវីដ-១៩រាតត្បាតពេញពិភពលោក ពិសេសប្រទេសថៃ ធ្វើឲ្យជនជាតិថៃ កើតជម្ងឺនេះមានស្លាប់ មានឆ្លង រួចបង្ខំឲ្យ

នាយករដ្ឋមន្ត្រីថៃប្រកាសប្រទេសគ្រាមានអាសន្ន។ ក្នុងនោះ រោងចក្រត្រូវបិទទាំងស្រុង ធ្វើឲ្យពលករខ្មែរខ្លះបង្ខំចិត្តចាកចេញពីស្រុក ថៃស្ទើរអស់ មកស្រុកខ្មែរវិញ។ រហូតមកដល់សព្វថ្ងៃនេះដែរប្រទេសថៃមិនទាន់ដំណើរការដូចមុននោះឡើយព្រោះសំអាងថាជំងឺកូវីដ-១៩ មិនទាន់បានធូរស្បើយនៅឡើយ ប្រជាជនថៃមានការប្រុងប្រយ័ត្នទាំងអស់គ្នា។ ជាមួយគ្នានេះដែរសមត្ថកិច្ចថៃបានបញ្ជាក់ទៀតថា អ្វីៗមិនទាន់ដំណើរការនៅឡើយ ដូច្នេះពលករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃប្រយ័ត្នចាញ់បោកមេខ្យល់។

យ៉ាងណាក្រោយពីឃាត់ខ្លួនពលករទាំង៧នាក់នេះ ដែលមកពីខេត្តបន្ទាយមានជ័យមានចំនួន៥នាក់ និងខេត្តតាកែវចំនួន ២នាក់ សមត្ថកិច្ចបានបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីស័កទី១ វិទ្យាល័យម៉ាឡៃដើម្បីពិនិត្យសុខភាពនិងបានធ្វើការណែនាំឲ្យឈប់ចាញ់ការឃោសនារបស់មេខ្យល់កុំឲ្យចាញ់បោកមេខ្យល់ទៀត៕ ៖ប្រាថ្នា

## កម្លាំងនគរបាលខេត្តកំពង់ស្ពឺ ធ្វើបច្ចុប្បន្នភាពផ្ទះសំណាក់ និងហាងម៉ាស្សា កោសខ្យល់

http://cambodiapolice.com/policekh/ 6:28 pm 4 សីហា 2020

**កំពង់ស្ពឺ៖** នៅថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយ កម្លាំងជំនាញអធិការដ្ឋាននគរបាលស្រុកឱរ៉ាល់ និងអធិការដ្ឋានស្រុកថ្ពងបានចុះធ្វើបច្ចុប្បន្នភាពផ្ទះសំណាក់ និងហាងម៉ាស្សាកោសខ្យល់ ក្រោមការដឹកនាំដោយ លោកស្រីវរសេនីយ៍ទោ មួន មល្លិកា នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការចូលរួប ក្រុមការងារ កម្លាំងអធិការដ្ឋានស្រុកឱរ៉ាល់ និងកម្លាំងអធិការដ្ឋានស្រុកថ្ពង។

ជាលទ្ធផលនៅស្រុកឱរ៉ាល់ មានផ្ទះសំណាក់ ០៤កន្លែង មានបន្ទប់៦៤ បុគ្គលិក ១១នាក់ ស្រី០៦នាក់។ ហាងខារ៉ាអូខេ ០១កន្លែង បុគ្គលិក០ ៥នាក់ ស្រី០៤ ។ ជាលទ្ធផលនៅស្រុកថ្ពង មានផ្ទះសំណាក់ ០១កន្លែង មានបន្ទប់១៣ បុគ្គលិក ០១នាក់(ស្រី) ហាងម៉ាស្សា-កោសខ្យល់ ០២កន្លែង មានបន្ទប់០៨ បុគ្គលិក ៦នាក់(ស្រី) ។

លោកស្រីវរសេនីយ៍ទោ មួន មូល្លិកា បានមានប្រសាសន៍ និងណែនាំ ផ្សព្វផ្សាយ ដល់ម្ចាស់ផ្ទះសំណាក់ ម្ចាស់ហាងម៉ាស្សាកោសខ្យល់ ត្រូវគោរពតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល អោយបានភ្ជាប់ភ្ជួន និងទទួលខុសត្រូវខ្ពស់ ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាល់ណាលជាសកលនៅមេរោគកូវីដ-១៩ ៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ២០នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 04-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២០នាក់ ស្រី ០៩នាក់ និងកុមារ ០០នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ២៨នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 04-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២៨នាក់ ស្រី ០៨នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៥នាក់

https://www.facebook.com/GDIOfficial 04-08-2020

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៥នាក់ ស្រី ៤៣នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០២នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ថៃ អនុញ្ញាតឱ្យពលករចំណាកស្រុកធ្វើការនៅប្រទេសរបស់ខ្លួន ក្នុងរយៈពេលយូរជាងមុន

https://business.khmernote.com.kh/ August 5, 2020 Nita

គណៈរដ្ឋមន្ត្រីថៃកាលពីថ្ងៃទី ៤ ខែសីហា បានយល់ព្រមពន្យាររយៈពេលចំពោះពលករចំណាកស្រុកមកពីប្រទេសចំនួន ៣ គឺកម្ពុជា ឡាវ និងមីយ៉ាន់ម៉ាត្រូវបានអនុញ្ញាតឱ្យធ្វើការនៅប្រទេសថៃ ដើម្បីពង្រឹងកម្លាំងពលកម្មរបស់ប្រទេសខ្លួនក្នុងកំឡុងពេលនៃការងើបឡើងវិញនៃសេដ្ឋកិច្ច នេះបើតាមអ្នកនាំពាក្យរដ្ឋាភិបាលថៃលោកស្រី Rachada Thanadirek ។ ក្រសួងការងារថៃ បានស្នើឱ្យមានពលករចំណាកស្រុកចូលទៅក្នុងប្រទេសរបស់ខ្លួនម្តងទៀត ដែលអនុញ្ញាតឱ្យពលករបរទេសដែលមកពីប្រទេសជិតខាងចំនួន ២ ក្រុមរួមមាន៖ ក្រុមទី១ ពលករបរទេសចំនួន ៦៤៩,០៤៦ នាក់ដែលកាន់លិខិតឆ្លងដែន លិខិតបញ្ជាក់អត្តសញ្ញាណ ឬឯកសារធ្វើដំណើរនឹងត្រូវបានអនុញ្ញាតឱ្យទៅធ្វើការនៅប្រទេសថៃចាប់ពីថ្ងៃទី១ ខែសីហាដល់ថ្ងៃទី៣១ ខែតុលា។

ជាមួយគ្នានេះ លិខិតអនុញ្ញាតការងាររបស់ពួកគេអាចត្រូវបានពន្យារដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២២ ដោយផ្តល់ឱ្យនិយោជិករបស់ពួកគេដាក់ពាក្យសុំពន្យាពេល។ ការដាក់ពាក្យសុំនៅឯការិយាល័យការងារខេត្ត ដែលជាកន្លែងដែលពួកគេធ្វើការ ឱ្យបានមុនថ្ងៃទី៣១ ខែតុលា។ បន្ទាប់មកពួកគេត្រូវបំពេញការត្រួតពិនិត្យរាងកាយនៅ

មន្ទីរពេទ្យរដ្ឋ និងដំណើរការពិនិត្យផ្សេងទៀតមុនថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២១ ហើយដាក់ពាក្យសុំអត្តសញ្ញាណប័ណ្ណសម្រាប់ជនមិនមែនជាជនជាតិថៃនៅការិយាល័យស្រុកពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២១ ។

មួយវិញទៀត សម្រាប់ក្រុមទី២ ពលករបរទេសចំនួន ៩២,៥៧២ នាក់ដែលកាន់លិខិតឆ្លងដែននឹងត្រូវបានអនុញ្ញាតឱ្យទៅធ្វើការនៅប្រទេសថៃ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២២ ដែលបានផ្តល់ឱ្យពួកគេចុះឈ្មោះនៅការិយាល័យការងារខេត្តដែលពួកគេធ្វើការមុនថ្ងៃទី៣១ ខែតុលា និងឆ្លងកាត់ការពិនិត្យសុខភាពនៅមន្ទីរពេទ្យរដ្ឋ ក៏ដូចជាទិញការធានារ៉ាប់រងសុខភាព (លើកលែងតែអ្នកដែលមានការធានាសុវត្ថិភាពពីសង្គមរួចហើយ) មុនថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២១ ។ ទន្ទឹមនឹងនេះ លោកស្រី Ratchada បានបន្ថែមថា ការដាក់ពាក្យនេះត្រូវតែបន្តរៀងរាល់បីខែម្តង ប្រសិនបើកម្មករមានបំណងចង់បន្តធ្វើការជាមួយនិយោជកដដែល នោះពួកគេត្រូវដាក់ពាក្យសុំបន្តនៅការិយាល័យការងារខេត្តមុនពេលផុតកំណត់៕ អត្ថបទ៖ នីតា ប្រភព៖ nationthailand

## ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

## សម្តេច ស ខេង អញ្ជើញបើកកិច្ចប្រជុំ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១

https://dap-news.com/national/ ByVNT108 Posted on August 6, 2020

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នាព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ បានអញ្ជើញ បើកកិច្ចប្រជុំគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ឆ្នាំ២០២០ នៅទីស្តីការ ក្រសួងមហាផ្ទៃ។ ឆ្លៀតឱកាសនោះ សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ថា «កិច្ចប្រជុំនាពេលព្រឹកនេះ គឺកិច្ចប្រជុំប្រចាំឆមាសទី១ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ហើយកិច្ចប្រជុំនេះ ក៏ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផល នៃការខិតខំប្រឹងប្រែងរបស់ក្រសួងស្ថាប័ន អង្គភាពជាសមាជិក និងថ្នាក់ក្រោមជាតិ ដើម្បីប្រយុទ្ធប្រឆាំង អំពើជួញមនុស្ស ក្នុងរយៈពេល៦ខែ ឆ្នាំ២០២០»។

សូមជម្រាបថា យោងតាមរបាយការណ៍សង្ខេប សម្រាប់កិច្ចប្រជុំឆមាសទី១ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា សកម្មភាពលទ្ធផល និងភាពប្រឈម និងទិសដៅ ដែលគណៈកម្មាធិការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានប្រឹងប្រែងអនុវត្តកន្លងមកមានដូចខាងក្រោម៖

ទី១-ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២០ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួងស្ថាប័នរាជធានី-ខេត្ត បានបន្តសកម្មភាពរបស់ខ្លួន ទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈម នឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួល នៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិ នៃការរាតត្បាត ដោយជំងឺកូវីដ-១៩។

ទី២-ចាប់ពីខែមីនា ឆ្នាំ២០២០ ក្រសួងស្ថាប័ន និងរាជធានី-ខេត្ត បានប្តូរទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពល ដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឲ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ជាពិសេសអ្នក ដែលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើនជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។

ទី៣-អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែន ទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាម

ច្រក មិនផ្លូវការទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័ក តាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឲ្យបានដល់លំនៅដ្ឋាន។

និងទី៤-បន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្ម ទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ៕ដោយ ៖ អេង ប៊ូឆេង

## សម្តេច ស ខេង អំពាវនាវឲ្យបន្តទប់ស្កាត់ការជួញដូរមនុស្ស ខណៈអាមេរិកវាយតម្លៃកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល

http://btv.com.kh/ 06/08/2020

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់បន្តយកទប់ស្កាត់ការជួញដូរមនុស្សឲ្យបានខ្លាំងក្លាបន្ថែមទៀត ខណៈពេលកន្លងមកកម្ពុជា ត្រូវបានអាមេរិកវាយតម្លៃដាក់ឲ្យស្ថិតក្នុងចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល ចំនួន២ឆ្នាំជាប់គ្នា ហើយនឹងត្រូវធ្លាក់ទៅលេខ៣ដោយស្វ័យប្រវត្តិ បើសិនភាគីពាក់ព័ន្ធមិនមានការប្រឹងប្រែង ឆ្លើយតបទៅនឹងចំណុចខ្វះខាតទាំងនោះ។ ក្នុងកិច្ចប្រជុំគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ឆ្នាំ២០២០ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួង សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានប្រសាសន៍ថា«យើងទាំងអស់គ្នានឹងពិនិត្យពិភាក្សា លើចំណុចខ្វះខាតដែលត្រូវកែលម្អ និងពង្រឹងបន្ថែម ដើម្បីស្តាមុខមាត់ប្រទេសជាតិ ដែលកន្លងមកនេះ ត្រូវបានសហរដ្ឋអាមេរិក វាយតម្លៃដោយដាក់ឲ្យស្ថិតក្នុងចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីឃ្លាំមើល ពីរឆ្នាំជាប់គ្នា ហើយនឹងត្រូវ ធ្លាក់ទៅលេខ ៣ ដោយស្វ័យប្រវត្តិ បើសិនជាមិនមានការប្រឹងប្រែង ឆ្លើយតបទៅនឹងចំណុចខ្វះខាតទាំងនោះ»។

យ៉ាងណាក៏ដោយសម្តេចក្រឡាហោម បានបន្តថា កម្ពុជាមិនផ្តេកផ្តួលទៅលើការវាយតម្លៃរបស់អាមេរិកទាំងស្រុងទេ តែក៏ត្រូវទទួលស្គាល់ថា វាមានចំណុចជាច្រើន ដែលចង្អុលបង្ហាញអំពីភាពខ្វះចន្លោះរបស់យើង គួរឲ្យពិចារណា និងធ្វើការកែលម្អដែរ ដើម្បីជាប្រយោជន៍សម្រាប់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ទាំងមូលនោះ។ សម្តេចក្រឡាហោម ក៏បានជំរុញដល់ភាគីពាក់ព័ន្ធទាំងអស់ត្រូវ ពិនិត្យពិភាក្សាលើចំណុចខ្វះខាតមួយចំនួនដើម្បីស្តារមុខមាត់ប្រទេសកម្ពុជាឡើងវិញ ដើម្បីកុំឲ្យគេមើលមកកម្ពុជាយើងជាប្រទេស ស្ថិតក្នុងចំណាត់ថ្នាក់លេខ២ក្នុងបញ្ជីឃ្លាំមើលបន្តទៀតនោះ។ ជាមួយគ្នានោះដែរ សម្តេចក្រឡាហោម ស ខេង ក៏បានលើកសរសេរដល់អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករដែលវិលត្រឡប់តាមច្រកមិនផ្លូវការទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូនឲ្យបានដល់លំនៅឋានផងដែរ ដែលកត្តានេះសបញ្ជាក់ឲ្យឃើញនៅការខិតខំប្រឹងប្រែងរួមគ្នាក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងគោរពសិទ្ធរបស់បងប្អូនចំណាក់ស្រុកជាដើមនោះ៕ អត្ថបទ ៖ បាន ចក់

## ពលរដ្ឋខ្មែរចំនួន ៦៥នាក់ វិលត្រឡប់ចូលប្រទេសវិញ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 05-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរចំនួន ៦៥នាក់ ស្រី ២០នាក់ ដែលវិលត្រឡប់ចូលប្រទេសវិញ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពី

មន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ក្នុងចំណោមពលរដ្ឋខ្មែរទាំង ៦៥ នាក់ ស្រី ២០នាក់ មាន ៣២នាក់ ជានិស្សិតបញ្ចប់ការសិក្សានៅប្រទេសថៃ និង៣៣នាក់ទៀត ជាអាជីវករចូលផ្សារ រោងក្លឿ។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់ នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្ដរមានជ័យ មានចំនួន ១០៣នាក់

https://www.facebook.com/GDIOfficial 05-08-2020

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន១០៣នាក់ ស្រី៤៨នាក់៕

# ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០

## សម្តេច ស ខេង បញ្ជាឲ្យក្រុមការងារ អនុវត្តច្បាប់ បន្តតាមដានស្រាវជ្រាវ ស្វែងរកមេខ្យល់ ជួញដូរមនុស្ស

https://dap-news.com/national/ ByPH104 Posted on August 6, 2020

ភ្នំពេញ ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបញ្ជាឲ្យក្រុមការងារអនុវត្តច្បាប់ បន្តតាមដានស្រាវជ្រាវស្វែង រកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗដើម្បីបង្ក្រាបឲ្យបានទាន់ពេលវេលា។ ក្នុងកិច្ចប្រជុំគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ឆ្នាំ២០២០ នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ នៅទីស្ដីការ ក្រសួង សម្ដេចក្រឡាហោម ស ខេង បានផ្ដល់អនុសាសន៍ មួយចំនួនដូចជា ៖

ទី១-ជំរុញការចងក្រង និងចែករំលែកទិន្នន័យជាប្រព័ន្ធ ឲ្យមានលក្ខណៈរលូន និង ជាទិន្នន័យរួម ថ្នាក់ជាតិ ដែលឆ្លើយតបទៅនឹងការដោះស្រាយបញ្ហា ជាពិសេស សម្រាប់ចែករំលែកជាមួយអន្តរជាតិ ។

ទី២-កិច្ចការយុត្តិធម៌ ត្រូវបានកែលម្អ តែសូមសំណូមពរ ក្រុមការងារ មេត្តាពង្រឹងក្រុមការងារ ឲ្យមានទំនាក់ទំនងសហការ ល្អជាមួយអង្គភាពពាក់ព័ន្ធនិងធ្វើយ៉ាងណាឲ្យការប្រមូលទិន្នន័យអំពីការផ្តន្ទាទោសអំពើជួញដូរមនុស្ស និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបានទាន់ពេលវេលា បញ្ចប់ការវាយតម្លៃ ដោយដាក់បន្ទុកលើចំណុចខ្វះខាតនៃប្រព័ន្ធយុត្តិធម៌ ។

ទី៣-សូមក្រុមការងារអនុវត្តច្បាប់ បន្តតាមដានស្រាវជ្រាវ ស្វែងរកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗ ដើម្បីបង្ក្រាបឲ្យបានទាន់ពេលវេលា ។ លើសពីនេះទៅទៀត គ្រប់អង្គភាពសមត្ថកិច្ច គប្បីពង្រឹងវិន័យ និងសេចក្ដីថ្លៃថ្នូររបស់កងកម្លាំង បញ្ចៀសឲ្យបានការប្រព្រឹត្តខុសឆ្គងនឹងវិន័យ ក្រមសីលធម៌វិជ្ជាជីវៈ បទបញ្ជា ដែលនាំឲ្យប្រឈមនឹងការដាក់ទោសទណ្ឌជាយថាហេតុ ។

ទី៤-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ក្រុមការងារអន្តរក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបន្តការប្រឹងប្រែងអនុវត្តសកម្មភាព ដែលបានរៀបចំក្នុងការឆ្លើយតបទៅនឹងបញ្ហាចំពោះមុខ រយៈពេលខ្លី មធ្យម វែង ឲ្យអស់លទ្ធភាព ដោយរិះរកមធ្យោបាយ ជម្នះឧបសគ្គ ពង្រឹងកិច្ចសហការដើម្បីចំណាយធនធានតិច បានផលច្រើន និង សម្រេចគោលដៅជាអាទិភាព ។

និងទី៥-គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបន្តចូលរួមសហការ និងគាំទ្រអនុវត្តគោលនយោបាយ និងវិធានការទាំងឡាយ របស់រាជរដ្ឋាភិបាល ឲ្យបានម៉ឺងម៉ាត់ ដើម្បីជម្នះរាល់ឧបសគ្គ និងភាពប្រឈមទាំងឡាយ រក្សា សន្តិភាព ស្ថេរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ទប់ទល់នឹងសភាព ការណ៍ដែលវិវត្តន៍ឥតឈប់ឈរ និងប្រធានសក្តិទាំងឡាយ ដែលប៉ះពាល់ដល់ប្រជាជន និងប្រទេសជាតិ ៕ ៖ អេង ប៊ូឆេង

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបញ្ជាឲ្យក្រុមតាមដានស្រាវជ្រាវរកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១៦:៤៥ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានដាក់បញ្ជាឲ្យក្រុមការងារអនុវត្តច្បាប់ត្រូវបន្តតាមដានស្រាវជ្រាវ ស្វែងរកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗ ដើម្បីបង្ក្រាបឲ្យបានទាន់ពេលវេលាចៀសវាងឲ្យករណីជួញដូរមនុស្សកើតឡើងបន្តទៀត ។ លើកឡើងក្នុងកិច្ចប្រជុំគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ឆ្នាំ២០២០ នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងសម្តេចក្រឡាហោម ស ខេង បានផ្តល់អនុសាសន៍ក៏ដូចជា ដាក់បញ្ជាមួយចំនួនដូចជា ៖

បានឲ្យដឹងថាទី១-ជំរុញការចងក្រង និងចែករំលែកទិន្នន័យជាប្រព័ន្ធឲ្យមានលក្ខណៈរលូន និង ជាទិន្នន័យរួមថ្នាក់ជាតិ ដែលឆ្លើយតបទៅនឹងការដោះស្រាយបញ្ហា ជាពិសេសសម្រាប់ចែករំលែកជាមួយអន្តរជាតិ ។

ទី២-កិច្ចការយុត្តិធម៌ត្រូវបានកែលម្អ តែសូមសំណូមពរ ក្រុមការងារមេត្តាពង្រឹងក្រុមការងារឲ្យមានទំនាក់ទំនងសហការល្អជាមួយអង្គភាពពាក់ព័ន្ធ និងធ្វើយ៉ាងណាឲ្យការប្រមូលទិន្នន័យអំពីការផ្តន្ទាទោសអំពើជួញដូរមនុស្ស និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបានទាន់ពេលវេលា បញ្ចប់ការវាយតម្លៃ ដោយដាក់បន្ទុកលើចំណុចខ្វះខាតនៃប្រព័ន្ធយុត្តិធម៌ ។

ទី៣-សូមក្រុមការងារអនុវត្តច្បាប់ បន្តតាមដានស្រាវជ្រាវ ស្វែងរកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗ ដើម្បីបង្ក្រាបឲ្យបានទាន់ពេលវេលា ។ លើសពីនេះទៅទៀត គ្រប់អង្គភាពសមត្ថកិច្ច គប្បីពង្រឹងវិន័យ និងសេចក្តីថ្លៃថ្នូររបស់កងកម្លាំងបញ្ចៀសឲ្យបានការប្រព្រឹត្តខុសឆ្គងនឹងវិន័យ ក្រមសីលធម៌វិជ្ជាជីវៈ បទបញ្ជា ដែលនាំឲ្យប្រឈមនឹងការដាក់ទោសទណ្ឌដោយថាហេតុ ។

ទី៤-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ក្រុមការងារអន្តរក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបន្តការប្រឹងប្រែងអនុវត្តសកម្មភាព ដែលបានរៀបចំក្នុងការឆ្លើយតបទៅនឹងបញ្ហាចំពោះមុខរយៈពេលខ្លី មធ្យម វែង ឲ្យអស់លទ្ធភាព ដោយរិះរកមធ្យោបាយ ជម្នះឧបសគ្គ ពង្រឹងកិច្ចសហការ ដើម្បីចំណាយធនធានតិចបានផលច្រើន និងសម្រេចគោលដៅជាអាទិភាព ។

និងទី៥-គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបន្តចូលរួមសហការ និងគាំទ្រអនុវត្តគោលនយោបាយ និងវិធានការទាំងឡាយ របស់រាជរដ្ឋាភិបាល ឲ្យបានម៉ឺងម៉ាត់ ដើម្បីជម្នះរាល់ឧបសគ្គ និង

ភាពប្រឈមទាំងឡាយ រក្សា សន្តិភាព ស្ថេរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ទប់ទល់នឹងសភាពការណ៍ដែលវិវត្តន៍ឥតឈប់ឈរ និងប្រធានសក្តិទាំងឡាយដែលប៉ះពាល់ដល់ប្រជាជន និងប្រទេសជាតិ ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុជាប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានឱ្យដឹងថា ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២០ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមក្រសួងស្ថាប័នរាជធានី-ខេត្ត បានបន្តសកម្មភាពការងារតាមទិសដៅដែលបានគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពិសេសស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោកក្នុងវិបត្តិកូវីដ-១៩ ។ លោកជំទាវបារាយការជូនអង្គប្រជុំថា ចាប់ពីខែមីនា ឆ្នាំ២០២០ ក្រសួងស្ថាប័ន និងរាជធានី-ខេត្ត បានប្តូរទិសដៅការងារដោយផ្តោតការយកចិត្តទុកដាក់លើបញ្ហាកើតចេញពីវិបត្តិកូវីដ-១៩ ដែលបានជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យធ្វើឲ្យរាំងស្ទះដោយអន្លើ និងទាមទារឱ្យមានការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់លើជីវភាពប្រជាពលរដ្ឋ ពិសេសអ្នកត្រឡប់ពីប្រទេសក្រៅដ៏ច្រើន ហើយភាគច្រើនជាអ្នកខ្វះលទ្ធភាពក្នុងការទ្រទ្រង់ជីវភាព និងងាយរងគ្រោះ ។

ឆ្លើយតបនឹងបញ្ហានេះ លោកជំទាវបានបន្តថា គ្រប់ភាគីបានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករដែលវិលត្រឡប់តាមច្រកមិនផ្លូវការទាំងយប់ទាំងថ្ងៃ ដោយបានពិនិត្យកម្តៅ និងសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ និងត្រៀមមធ្យោបាយដឹកជញ្ជូនពួកគាត់ឱ្យបានដល់លំនៅដ្ឋាន ហើយបន្តតាមដានស្ថានភាពសុខភាព ជីវភាព ព្រមទាំងផ្តល់សេវាតាមតម្រូវការផ្សេងៗជូនពួកគាត់។ លោកជំទាវក៏បានបន្តរាយការណ៍ជូនសម្តេចព្រមទាំងអង្គប្រជុំអំពីលទ្ធផលការងារផ្នែកគោលនយោបាយច្បាប់ និងបទដ្ឋានគតិយុទ្ធ និងកិច្ចសហប្រតិបត្តិការ, ការងារបង្ការទប់ស្កាត់, ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួយដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ, ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល និងអំពីការវាយតម្លៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះខិតខំបំពេញការងារតាមជំនាញ និងតាមគោលដៅរៀងៗខ្លួនរបស់ក្រុមការងារទាំង៦ និងមន្ត្រីពាក់ព័ន្ធផ្សេងទៀត ទោះបីជាកម្ពុជា មានឧបសគ្គបន្ទុចបង្អាក់ពីមជ្ឈដ្ឋានអន្តរជាតិ ឬការប្រឈមនឹងវិបត្តិសេដ្ឋកិច្ច និងជំងឺឆ្លងកូវីដ១៩ យ៉ាងណា ក៏មិនបានបោះបង់ការខិតខំប្រឹងប្រែងប្រកបដោយស្មារតីអត់ធ្មត់ តស៊ូ ព្យាយាមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែរ៕

## មន្ត្រីជំនាញ កំពុងជំរុញបង្កើតផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត

http://btv.com.kh/nation-news/ 06/08/2020

ភ្នំពេញ៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រួមទាំងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ និងមានវត្តមានរបស់យុវជនជាច្រើន បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីប្រមូលធាតុចូលចាំបាច់ជាច្រើនទៀត។ សម្រាប់សិក្ខាសាលាដែលរៀបចំឡើងព្រឹកថ្ងៃទី៦ សីហាឆ្នាំ២០២០នេះ លោកជំទាវ ញ៉េប សុភាព ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លើកឡើងថា ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនាពេលគឺបង្ហាញច្បាស់ការយកចិត្តទុកដាក់រួមគ្នា សំដៅធ្វើឱ្យកាន់តែប្រសើរឡើងការលើកកម្ពស់កិច្ចការពារកុមារ និងឧត្តមប្រយោជន៍កុមារ។ លោកជំទាវចាត់ទុកថា សកម្មភាពនេះគឺជាអំពើហិង្សាបែបថ្មី មានការរីកសុះសាយលឿន មាន

ភាពស្មុគស្មាញច្រើនក្នុងការគ្រប់គ្រងដោះស្រាយចំពោះបញ្ហានេះ ហើយទាមទារឱ្យក្រុមការងារមានការតាមដាន និងយកចិត្តទុកដាក់ជាខ្លាំង។

ជុំវិញបញ្ហានេះ លោកជំទាវក៏សំណូមពរឱ្យអាណាព្យាបាល ព្យាយាមអប់រំណែនាំដល់ក្មេងៗក៏ដូចជាយុវជនមួយចំនួនឱ្យមានការប្រុងប្រយ័ត្ន ក្នុងការប្រើប្រាស់អ៊ីនធឺណិតផងដែរ ជាពិសេសគឺប្រព័ន្ធបណ្តាញសង្គម ដែលអាចមានផលប៉ះពាល់ច្រើន បើសិនជាការពុំយល់ច្បាស់ពីផលវិជ្ជមាន និងផលអវិជ្ជមានដែលអាចបង្កឡើង។ តាមការលើកឡើងបន្ថែមលោកជំទាវបញ្ជាក់ថា កម្ពុជាបានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារកាលពីខែ កញ្ញា ឆ្នាំ២០១៩ ហើយកម្ពុជាក៏បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTECT កាលពីឆ្នាំ២០១៥ ពាក់ព័ន្ធសកម្មភាពទប់ស្កាត់ ការរំលោភបំពាន និងកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញផងដែរ៕ អត្ថបទ៖ គឹមហុក

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២២នាក់

https://www.facebook.com/GDIOfficial 06-08-2020

នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២២នាក់ ស្រី ៥៨នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៧៨នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 06-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៧៨នាក់ ស្រី ៤០នាក់ និងកុមារ ១០នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ខណៈប្រទេសថៃកំពុងល្បីតឹងបញ្ហាជំងឺកូវីដ១៩ ពលករខ្មែរ បាននាំគ្នាសម្រុកចាកចេញជាបន្តបន្ទាប់

http://peoplenews.asia/ ដោយ រិទ្ធី ថ្ងៃទី07 ខែ08 ម៉ោង 12:22 PM

ភ្នំពេញ៖ ស្រុបពេលដែលប្រទេសថៃកំពុងរឹតបន្តឹងអំពីស្ថានភាពជំងឺកូវីដ១៩ ធ្វើឲ្យពលករខ្មែរដែលទៅរកការងារនៅក្រៅប្រទេសបាននាំគ្នាសម្រុកចាកចេញជាបន្តបន្ទាប់ ក្រោយពីប្រទេសនេះបានរឹតបន្តឹងចំពោះពលករចំណាកស្រុក ជាពេសេសពលរដ្ឋខ្មែរតែម្តង។ ជាមួយគ្នានឹងការចាកចេញពីប្រទេសថៃរបស់ក្រុមពលករខ្មែរទាំងនេះ ក្នុងនោះគេសង្កេតឃើញថា នៅមានប្រជាពលរដ្ឋខ្មែរមួយចំនួនទៀតកំពុងព្យាយាមចូលទៅរកការងារធ្វើនៅប្រទេសថៃឡើងវិញ ប៉ុន្តែសមត្ថកិច្ចនៅតាមព្រំដែនទាំងកម្ពុជា និងថៃបានធ្វើហាមឃាត់ជាបន្តបន្ទាប់។ ប៉ុន្តែនៅពេលនេះបើយោងតាមរបាយការណ៍របស់នាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១០ វេលាម៉ោង ៣រសៀល មានពលរដ្ឋខ្មែរបន្តវិលចូលប្រទេសកម្ពុជាវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន ១២២នាក់ ស្រី៥៨នាក់។ ចំណែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ប្រជាពលរដ្ឋខ្មែរបានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំ ចំនួន ៧៨នាក់ ស្រី ៤០នាក់ និងកុមារ ១០នាក់។

ចំពោះពលរដ្ឋខាងលើកម្លាំងនគរបាលប៉ុស្តិ៍បានធ្វើការណែនាំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័កត្រួតពិនិត្យសុខភាពវាល់កម្តៅ រួចបានអនុញ្ញាតឲ្យពួកគាត់ទៅលំនៅដ្ឋានរៀងៗខ្លួន។ ចំពោះប្រជាពលរដ្ឋខាងលើនេះ ពួកគាត់ហាក់ដូចជាមានសំណាងដែរដោយសារបន្ទាប់ពីខាងមន្រ្តីចត្តាឡីស័កពិនិត្យលើសុខភាព ពួកគាត់យល់ ហើយបានឲ្យពួកគាត់វិលត្រឡប់កាន់លំនៅដ្ឋានរៀងៗខ្លួន តែពុំបានឃុំខលួនរយៈពេល១៤ថ្ងៃ ដើម្បីតាមដានស្ថានភាពជំងឺរបស់ពួកគាត់នោះទេ។

## ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០

### ក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០២០ សមត្ថកិច្ចបង្រ្កាបអំពើជួញដូរមនុស្ស បានចំនួន ៧៩ ករណី

https://www.postkhmer.com/ នៀម ឆេង | Publication date 07 August 2020 | 10:56 ICT

**ភ្នំពេញៈ** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្លែងកាលពីម្សិលមិញថា បើទោះបីជាមានបញ្ហាប្រឈមដោយជំងឺកូវីដ១៩ក៏ដោយ ក៏សកម្មភាពប្រឆាំងការជួញដូរមនុស្សក្នុងរយៈពេល ៦ ខែឆ្នាំ ២០២០ នេះ បានបន្តយ៉ាងសកម្មដោយបានបង្ក្រាបអំពើជួញដូរមនុស្សបាន ៧៩ ករណី។ លោកស្រីមានប្រសាសន៍ប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «បើនិយាយពីការបង្ក្រាបក្នុងរយៈពេល ៦ ខែដូចគ្នា ឆ្នាំ ២០២០ នេះយើងធ្វើបានច្រើនជាងមុន ១ ករណីគឺចំនួន ៧៩ ករណីកើនពី ៧៨ ករណី។ ក្នុងនេះអំពើជួញដូរមនុស្សយើងបង្ក្រាបបាន ២៩ ករណី មានជនសង្ស័យ ៣៦ នាក់ដែលមានជនបរទេស ៣ នាក់។ ក្នុងចំណោម ២៩ ករណីនេះមានជនរងគ្រោះ ១៩០ នាក់»។ លោកស្រីបន្តថា៖ «ចំណែកករណីជួញដូរផ្លូវភេទឆ្នាំនេះការបង្ក្រាបមានការថយចុះ ១៦ ករណី ដោយសារតែឆ្នាំនេះ សេវាកម្សាន្តត្រូវបានផ្អាកច្រើន ដូច្នេះឆ្នាំនេះបង្ក្រាបបាន ៥០ ករណីធៀបនឹង ៦ ខែឆ្នាំមុនដែលមាន ៦៦ ករណី។ ក្នុងនេះមានជនសង្ស័យចំនួន ៦៧ នាក់ដែល ១៤ នាក់ជាជនបរទេស។ ចំណែកជនរងគ្រោះមានចំនួន ៩៧ នាក់»។

លោកស្រី ជូ ប៊ុនអេង បន្តថាការជួញដូរដោយការនាំចេញមិនមានច្រើនទេ ដោយសារតែមានការបិទច្រកព្រំដែនពីប្រទេសជិតខាង និងការបិទជើងយន្តហោះ។ ប៉ុន្តែទោះបីថៃបិទច្រកទ្វារព្រំដែនជាមួយកម្ពុជាក្នុងវិធានការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ក៏ដោយ ក៏ពលរដ្ឋខ្មែរជិត ១ ពាន់នាក់ បានចាញ់បោកមេខ្យល់ដោយព្យាយាមចូល

ទៅប្រទេសថៃ ប៉ុន្តែត្រូវបានថៃចាប់បញ្ជូនមកវិញ។ លោកស្រីថ្លែងថា៖ «ពួកគាត់ (អ្នកដែលថៃចាប់បញ្ជូនមកវិញ) គឺជាជនរងគ្រោះដោយសារអំពើជួញដូរ ហើយដោយសារគាត់ចាញ់បោកមេខ្យល់យកទៅលក់។ ពួកគាត់មិនអាចរកការងារអីបានទេ បានត្រឹមតែចំណាយលុយឲ្យមេខ្យល់។ គេប្រាប់ថា យកទៅឲ្យនិយោជក ប៉ុន្តែពេលចូលទៅដល់មិនបានផលទេ គាត់ក៏បណ្តោយទៅតាមយថាកម្ម គឺគាត់ត្រូវបានគេចាប់ និងបញ្ជូនមកវិញ»។ លោកស្រីបានលើកទឹកចិត្តឲ្យពលរដ្ឋពិចារណា កុំឲ្យចាញ់បោកគេ ព្រោះពេលនេះការផ្សងព្រេងអាចទទួលបានត្រឹមតែការខាតបង់ប្រាក់កាសប៉ុណ្ណោះ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ដែលជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាលពីម្សិលមិញបានធ្វើជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី ១ ឆ្នាំ ២០២០ នេះ។ លោកបានថ្លែងថា៖ «សូមក្រុមការងារអនុវត្តច្បាប់បន្តតាមដានស្រាវជ្រាវ ស្វែងរកមេខ្យល់ជួញដូរមនុស្ស និងល្បិចកលថ្មីៗ ដើម្បីបង្ក្រាបឲ្យបានទាន់ពេលវេលា។ លើសពីនេះទៅទៀតគ្រប់អង្គភាពសមត្ថកិច្ច គប្បីពង្រឹងវិន័យ និងសេចក្តីថ្លៃថ្នូររបស់កងកម្លាំង បញ្ចៀសឲ្យបានការប្រព្រឹត្តខុសឆ្គងនឹងវិន័យក្រមសីលធម៌វិជ្ជាជីវៈ បទបញ្ញាដែលនាំឲ្យប្រឈមនឹងការដាក់ទោសទណ្ឌជាយថាហេតុ»។ លោកបានផ្តល់អនុសាសន៍ដល់ក្រុមការងារប្រឆាំងការជួញដូរមនុស្ស និងអាជ្ញាធរពាក់ព័ន្ធឲ្យចងក្រង និងចែករំលែកទិន្នន័យជាប្រព័ន្ធឲ្យមានលក្ខណៈរលូន និងជាទិន្នន័យរួមថ្នាក់ជាតិដែលឆ្លើយតបទៅនឹងការដោះស្រាយបញ្ហា ជាពិសេសសម្រាប់ចែករំលែកជាមួយអន្តរជាតិ។

លោក ស ខេង បានស្នើឲ្យមានទំនាក់ទំនងឲ្យកាន់តែល្អថែមទៀតជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីឲ្យការប្រមូលទិន្នន័យអំពីការផ្តន្ទាទោសអំពើជួញដូរមនុស្ស ត្រូវបានបញ្ជូនយ៉ាងលឿនមកអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស។ លោកបន្តថា៖ «គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីបន្តចូលរួមសហការ និងគាំទ្រអនុវត្តគោលនយោបាយ និងវិធានការទាំងឡាយរបស់រាជរដ្ឋាភិបាលឲ្យបានម៉ឺងម៉ាត់ដើម្បីជម្នះនូវរាល់ឧបសគ្គ និងភាពប្រឈមទាំងឡាយរក្សាសន្តិភាព ស្ថិរភាពនយោបាយ សេដ្ឋកិច្ច និងសង្គមទប់ទល់នឹងសភាពការណ៍ដែលវិវត្តឥតឈប់ឈរ និងប្រធានស័ក្តិទាំងឡាយ ដែលប៉ះពាល់ដល់ប្រជាជន និងប្រទេសជាតិយើង»៕

## ស្ថានទូតកម្ពុជា ៖ អាជ្ញាធរថៃសម្រេចបន្តសុពលភាពការស្នាក់នៅរបស់ប្រជាពលរដ្ឋខ្មែរ រហូតដល់ខែមករា ឆ្នាំ២០២១

---

http://kampucheathmey.com/ 8/8/2020 6:07 Pm

ភ្នំពេញ ៖ ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃបានឲ្យដឹងថា នៅក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋាភិបាលថៃបានសម្រេចបន្តសុពលភាពស្នាក់នៅដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ រហូតដល់ខែមករាឆ្នាំ២០២១។ បើតាមការបញ្ជាក់ពីស្ថានទូតកម្ពុជាឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានបន្តឲ្យស្នាក់នៅប្រទេសថៃមានចំនួន៤ ក្រុម ដែលរួមមាន ក្រុមទី១. ពលករខ្មែរដែលចូលទៅធ្វើការក្រោមអនុស្សរណៈនៃការ យោគយល់គ្នា (MOU) ចប់កិច្ចសន្យាការងាររយៈពេល៤ ឆ្នាំ។ ក្រុមទី២. ពលករខ្មែរដែលចូលធ្វើការក្រោមមនុស្សសារណៈនៃការយោគយល់គ្នា (MOU) បានអស់សុពលភាពស្នាក់នៅ និងធ្វើការដោយសារនិយោជកចាស់ឈប់ជួល ហើយមិនអាចធ្វើការប្តូរនិយោជកបានទាន់ពេលវេលាតាមច្បាប់កំណត់។ ក្រុមទី៣. ពលករ ព្រមទាំងអ្នកនៅក្នុងបន្ទុក ធ្លាប់បានបញ្ជាក់អត្តសញ្ញាណ និងមានលិខិតឆ្លងដែន

លិខិតធ្វើការ ដែលអស់សុពលភាពស្នាក់នៅ និងធ្វើការចាប់ពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយសារនយោជកពុំបាននាំទៅចុះបញ្ជីឈ្មោះតាមប្រព័ន្ធអនឡាញ ឲ្យបានទាន់ពេលវេលា។

បើតាមស្ថានទូតកម្ពុជា ក្រុមទាំងបីខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅនិងធ្វើការបណ្តោះអាសន្នចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ប៉ុន្តែក្នុងអំឡុងពេលនេះ ដើម្បីទទួលបានការអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការ និយោជក ឬតំណាងនិយោជក ត្រូវនាំពលករទៅដំណើរការដាក់ពាក្យស្នើសុំបន្តទិដ្ឋាការស្នាក់នៅ និងបានអនុញ្ញាតការងារឲ្យបានរួចរាល់ចាប់ពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។ ក្រុមទី៤. ពលករខ្មែរ ដែលចូលធ្វើការព្រឹកហើយវិលល្ងាច និងតាមរដូវ នៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។ ក្រុមទី៤. នេះត្រូវបានអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការបណ្តោះអាសន្នចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ ប៉ុន្តែក្នុងអំឡុងពេលនេះ ដើម្បីទទួលបានការអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ និយោជក ឬតំណាងនិយោជក ត្រូវនាំពលករទៅដំណើរការដាក់ពាក្យដើរសុំបន្តទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារឲ្យបានរួចរាល់ ចាប់ពីថ្ងៃទី១៧ ខែសីហា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។

បើតាមស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃបានបញ្ជាក់ថា ប្រសិនបើប្រជាពលរដ្ឋក៏ដូចជាពលករ មានចម្ងល់លើបញ្ហានេះ ត្រូវទាក់ទងទៅស្ថានទូតតាមរយៈ page facebook ឬលេខទូរសព្ទ៕ កោះកែវ

## ប្រទេសថៃអនុញ្ញាតឱ្យមានការស្នាក់នៅរយៈពេលយូរសម្រាប់ពលករចំណាកស្រុក

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 7 ខែ សីហា ឆ្នាំ 2020

AKP ភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០៖ គណៈរដ្ឋមន្ត្រីថៃបានអនុម័តផែនការរបស់ក្រសួងការងារដើម្បីអនុញ្ញាតឱ្យពលករបរទេសជាង ៥០០.០០០នាក់ ដែលមានឯកសារស្របច្បាប់ស្នាក់នៅបានរយៈពេលយូរជាងមុន សម្រាប់ធ្វើការនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយនេះរហូតដល់ខែមីនា ឆ្នាំ ២០២២ ។

អ្នកនាំពាក្យរបស់រដ្ឋាភិបាលថៃ លោកស្រី Rachada Dhnadirek បាននិយាយថា ការយល់ព្រមនេះត្រូវបានផ្តល់ជូនស្របតាមគោលការណ៍ណែនាំថ្មីរបស់រដ្ឋាភិបាល ស្តីពីការគ្រប់គ្រងពលករចំណាកស្រុកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩។ គោលការណ៍ណែនាំរបស់ក្រសួងមានគោលបំណងដើម្បីធានាថា ប្រទេសថៃរក្សាបាននូវកម្លាំងពលកម្ម ដែលជាតម្រូវការដើម្បីពង្រឹងសេដ្ឋកិច្ច នឹងដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ដែលរាលដាលពីជនជាតិបរទេសផងដែរ។ លោកស្រី Rachada បាននិយាយថា គណៈរដ្ឋមន្ត្រីថៃបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកដែលមានលិខិតឆ្លងដែន លិខិតបញ្ជាក់អត្តសញ្ញាណនឹងឯកសារធ្វើដំណើរផ្សេងៗទៀតដោយមិនរាប់បញ្ចូលលិខិតឆ្លងកាត់ព្រំដែន ដើម្បីបន្តធ្វើការងារចាប់ពីចុងខែតុលាឆ្នាំនេះនៅពេលដែលការអនុញ្ញាតរបស់ពួកគេផុតកំណត់រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ៕ (ប្រភព VNA បកប្រែដោយលោក យា ចិន្តាខន្តី)

## ថៃបញ្ជូនប្រជាពលរដ្ឋខ្មែរ ៣ នាក់អោយវិលមកម្ពុជាវិញបន្ទាប់ពីជាប់ពន្ធនាគារជាង២ឆ្នាំ

https://www.rasmeinews.com/ August 8, 2020, 7:41 PM

**ដោយៈបាយ័ន/ឧត្តរមានជ័យៈ** ប្រជាពលរដ្ឋខ្មែរចំនួន ៣ នាក់ត្រូវបានអាជ្ញាធរថៃធ្វើការបញ្ជូនមកស្រុកកំណើតវិញបន្ទាប់ពីដោះលែងពីពន្ធនាគារពីបទឆ្លងដែន ចូលកាប់ឈើគ្រញូងដោយខុសច្បាប់។ ការប្រគល់និង

ទទួលនេះបានធ្វើឡើងកាលពីវេលាម៉ោង១៦និង១៥នាទីថ្ងៃទី៨ ខែសីហា ២០២០នេះស្ថិតនៅច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែង ខេត្ត ឧត្តរមានជ័យ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាស្រងាំបានឲ្យដឹងថាប្រជាពលរដ្ឋខ្មែរចំនួន ៣ នាក់ដែលត្រូវបានអាជ្ញាធរថៃធ្វើការបញ្ជូនមកគឺមានៈទី១.ឈ្មោះ សាយ សាលី ភេទប្រុសអាយុ៤៦ឆ្នាំរស់នៅភូមិត្រាចខោ ឃុំត្រពាំងប្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ,ហើយត្រូវបានចាប់ខ្លួនកាលថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨កន្លងមកពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ចូលតាមច្រកប្រទាលគង ហើយត្រូវបានយកទៅដាក់ពន្ធនាគារនៅខេត្តអូប៊ុនប្រទេសថៃ។ ទី២.ឈ្មោះ សោម ម៉ន ភេទស្រី អាយុ៤៦ឆ្នាំរស់នៅភូមិទឹកក្រហម ឃុំអូរក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ , និងទី៣.ឈ្មោះ ចាប លើម ភេទស្រីអាយុ៥២ឆ្នាំ រស់នៅភូមិម៉ុបី ឃុំម៉ុបី ស្រុកជាំក្សាន្តខេត្តព្រះវិហារ ។ អ្នកទាំងពីរចាប់ខ្លួនថ្ងៃទី០៧ ខែកក្កដាឆ្នាំ២០ ១៨កន្លងពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ចូលតាមច្រក៥០០ ហើយត្រូវបានយកទៅដាក់ ពន្ធនាគារនៅខេត្តអូប៊ុន ប្រទេសថៃ។

ក្រោយពីទទួលពីភាគីថៃរួចមកភាគីកម្ពុជាបានធ្វើការអប់រំ និងអោយធ្វើកិច្ចសន្យាមិនអោយធ្វើការឆ្លងដែនខុសច្បាប់បែបនេះទៀតឡើយហើយបានអោយវិលត្រលប់ទៅលំនៅដ្ឋានរៀងៗខ្លួន៕BR

## កំលុងពេលជួបវិបត្តិកូវីដនេះ ពលរដ្ឋជាង៧ពាន់នាក់ ត្រូវកម្លាំងយោធភូមិភាគទី៥ទប់ស្កាត់ ដោយសារលួចឆ្លងដែនទៅថៃ

http://www.freshnewsasia.com/ 2020-08-09 07:09pm

**(បន្ទាយមានជ័យ)៖** កំលុងពេលជួបវិបត្តិជំងឺកូវីដ-១៩នេះ កម្លាំងយោធានៃយោធភូមិភាគទី៥ បានរួមគ្នាទប់ស្កាត់ប្រជាពលរដ្ឋប្រមាណជាង ៧ពាន់នាក់ ដែលលួចឆ្លងដែនទៅប្រទេសថៃ ព្រមទាំងខិតខំទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងទៀតផងដែរ។ នេះបើតាមការឲ្យដឹងពីលោកឧត្តមសេនីយ៍ទោ ឈុន ម៉ៅ មេបញ្ជាការប្រចាំទិសទី១ នៃខេត្តបន្ទាយមានជ័យ។ ឧត្តមសេនីយ៍ទោ ឈុន ម៉ៅ បានបន្តថា កងកម្លាំងដែលឈរជើងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ មានយោធាសឹករងខេត្តបន្ទាយមានជ័យ មានយោធាតំបន់អភិវឌ្ឍន៍តេជោភ្នំធំត្រ កងកម្លាំងកងការពារព្រំដែន៥០៣ ចំណុះឲ្យយោធភូមិភាគទី៥។ ជារឿយៗ លោកមេបញ្ជាការ ឈុន ម៉ៅ បានដាស់តឿនដល់កងកម្លាំងចំណុះឲ្យយោធភូមិភាគទី៥ និងអនុវត្តបន្តតាមការណែនាំរបស់មេបញ្ជាការកងទ័ពជើងគោក ក៏ដូចជាមេបញ្ជាការយោធភូមិភាគី៥ ត្រូវខិតខំយកចិត្តទុកដាក់អនុវត្តបន្តនាំគ្នាទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ដែលកើតមានឡើងតាមបណ្តោយព្រំដែន។

លោកមេបញ្ជាការ ថែមទាំងបានដាស់តឿនដល់កងកម្លាំងចំណុះឲ្យទប់ស្កាត និងបង្ក្រាបការជួញដូរមនុស្សអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ទំនិញគេចពន្ធ រថយន្តចង្កូតស្តាំ ជាពិសេសនាំគ្នាទប់ស្កាត់ពលករ ដែលចាញ់បោកមេខ្យល់បោកយកទៅលក់តាមព្រំដែនជាបន្តបន្ទាប់។ ម្យ៉ាងវិញទៀត កងកម្លាំងទាំងអស់ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពឲ្យបានខ្ជាប់ខ្ជួន ត្រូវចេះសហការជាមួយអាជ្ញាធរប្រទេសជិតខាង ទំនាក់ទំនងចងសម្ពន្ធមេត្រីជាមួយនឹងប្រទេសជិតខាង និងត្រូវគោរពតាមបទបញ្ជារបស់ថ្នាក់លើ ដែលបានដាក់ចេញបទបញ្ជាផ្ទៃក្នុងរបស់អង្គភា ក៏ដូចជាបទបញ្ជាលោកមេបញ្ជាការ ត្រូវយកចិត្តទុកដាក់ជាមួយនឹងពលរដ្ឋ គ្រាដែលពលរដ្ឋមានគ្រោះមហន្តរាយផងដែរ៕

## ថៃបញ្ជូនអ្នកទោសខ្មែរ២នាក់ទៀត ត្រឡប់មកវិញតាមច្រកអន្តរជាតិអូរស្មាច់ បន្ទាប់ពីជាប់ទោសជាង២ឆ្នាំពីបទឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2020-08-09 02:54pm

**(ឧត្តរមានជ័យ)៖** អ្នកទោសខ្មែរចំនួន២នាក់ទៀត ត្រូវបានអាជ្ញាធរប្រទេសថៃ បន្តបញ្ជូនខ្លួនត្រឡប់មកវិញ ក្រោយជាប់ទោសចំនួន ២ឆ្នាំ ៦ខែក្នុងទឹកដីថៃ ពីបទឆ្លងដែនខុសច្បាប់។ បើតាមសំដីរបស់សមត្ថកិច្ចប្រចាំច្រកអន្តរជាតិអូរស្មាច់ បានបញ្ជាក់នៅព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២០ថា នៅល្ងាចថ្ងៃម្សិលមិញនេះ អាជ្ញាធរប្រទេសថៃ បានបញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរចំនួន២នាក់ តាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលត្រូវទាហានថៃ ចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូង និងបាននាំទៅឃុំខ្លួន នៅខេត្តសុរិន្ទប្រទេសថៃ បើគិតដល់ថ្ងៃនេះគឺជាប់ទោសរយៈពេល២ឆ្នាំ ៦ខែ។

ប្រជាពលរដ្ឋខ្មែរទាំង២នេះរួមមានទី១៖ ឈ្មោះ មុិ ម៉ៅ ភេទប្រុស អាយុ២៩ឆ្នាំ និងទី២៖ ឈ្មោះ អែម ម៉ុន ភេទប្រុស អាយុ២៩ឆ្នាំ អ្នកទាំង២រស់នៅភូមិអូរថ្ម ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ បន្ទាប់ពីបានស្តែនកម្តៅរកមេរោគកូវីដ-១៩ និងលាងសម្អាតខ្លួនប្រាណដោយទឹកអាល់កុល ពីមន្ត្រីចត្តាឡីសក័ប្រចាំច្រកព្រំដែនរួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំឱ្យបញ្ឈប់ សកម្មភាពឆ្លងដែនខុសច្បាប់តទៅទៀត និងបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរចំនួន ០៤នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 09-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នារសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃចំនួន ០៤នាក់ ស្រី ០២នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ និងសហការប្រគល់ជូនទៅមន្ត្រីចត្តាលីស័ក ដើម្បីធ្វើការពិនិត្យកំដៅ និងអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៩នាក់

https://www.facebook.com/GDIOfficial 09-08-2020

នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៩នាក់ ស្រី ៣៨នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០០នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ មានចំនួន ៤៣នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 08-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៣នាក់ ស្រី ១១នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែនមិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 08-08-2020

នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកមុំបី ស្រុកជាំក្សាន ខេត្តព្រះវិហារ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៧២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 08-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៧២នាក់ ស្រី ៣០នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៦នាក់

https://www.facebook.com/GDIOfficial 08-08-2020

នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ

បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន៥៦នាក់ ស្រី២៧នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៩នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 07-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៩នាក់ ស្រី ២៣នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 07-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ អឿន វិត ភេទប្រុស អាយុ ៣៩ឆ្នាំ, ២-ឈ្មោះ សាន សាលី ភេទប្រុស អាយុ ៣៨ឆ្នាំ, ៣-ឈ្មោះ ចាន់ សុភក្តិ ភេទប្រុស អាយុ ៣៧ឆ្នាំ មានទីលំនៅភូមិដំណាក់រៀង ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ, ៤-ឈ្មោះ ប៉ុង អែម ភេទប្រុស អាយុ ៣៦ឆ្នាំ និង៥-ឈ្មោះ នៅ សំណាង ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅភូមិល្វា ឃុំស្ទំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព អនុវត្តនីតិវិធី ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២០នាក់

https://www.facebook.com/GDIOfficial 07-08-2020

នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ

បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ខេត្តឧត្តរមានជ័យមានចំនួន១២០នាក់ ស្រី៤៤នាក់៕

## កម្លាំងសមត្ថកិច្ចថៃចាប់ពលករខ្មែរប្រុស ស្រីឆ្លងដែនខុសច្បាប់តាមរយៈមេខ្យល់បាន២៦នាក់

http://nokorwatnews.com/ 08-08-2020

ខេត្តបន្ទាយមានជ័យៈយោងការចុះផ្សាយតាមគេហទំព័រក្នុងស្រុករបស់ថៃ( สระแก้ว-77 ข่าวเด็ด )កាលពីវេលាម៉ោង១២និង៣០នាទី ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ នេះបានឲ្យដឹងថាសមត្ថកិច្ចកងកម្លាំង បូរផា ថៃ បានចាប់ឃុំខ្លួនពលករខ្មែរ នៅ២គោលដៅផ្សេងគ្នាបានចំនួន ២៦នាក់ ខណៈអ្នកទាំងនោះ លួចឆ្លងដែនចូលពីស្រុកស្វាយចេក និង ស្រុកថ្មពួករបស់កម្ពុជា ប្រឈមជាមួយស្រុកតាព្រះយ៉ា ខេត្តស្រះកែវរបស់ថៃ ។

កម្លាំងសមត្ថកិច្ចស្រុកតា ព្រះយ៉ា បានចេញល្បាតក្នុងតំបន់ដែលទទួលខុសត្រូវ ដើម្បីរឹតបន្តឹងការលួចចូលប្រទេសដោយខុសច្បាប់ ក្នុងស្ថានការណ៍នៃការរាត្បាតរបស់កូវីដ-19 តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ ខណៈមកដល់បរិវេណភូមិម៉ាក់ កក ឃុំទំពស្តេច ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ សមត្ថកិច្ចបានប្រទះឃើញរថយន្តម៉ាកមីតស៊ុយប៊ីហ្ស៊ី ពណ៌សពីរគ្រឿង ពាក់ស្លាកលេខ7กศ-3326 ក្រុងថេប នឹងរថយន្តតូ យ៉ូតា ពណ៌ទឹកមាស ពាក់ស្លាកលេខฅษ-9859ក្រុងថេប ទើបកាក់សុំត្រួតពិនិត្យមនុស្ស តែរថយន្តទាំង២គ្រឿងមិនព្រមឈប់ រួចថែមទាំងព្យាយាមបើករត់គេចតាមផ្លូវភូមិ ណង ផៃ ទើបសមត្ថកិច្ចថៃដេញតាម។ ប៉ុន្តែដោយសាររថយន្តសមត្ថកិច្ចថៃមិនអាចតាមទាន់ ទើបបើករថយន្តល្បាតចុះល្បាតឡើង តាមផ្លូវដែលរថយន្តទាំង២គ្រឿងបើករត់គេច រហូតមកដល់បរិវេណគំនរសំរាមក្នុងភូមិ ណង ផៃ ឃុំតា ព្រះយ៉ា ស្រុកតាព្រះយ៉ា ត្រង់បង្គោលឡាក់TA575480 ទើបប្រទះឃើញពលករខ្មែរអង្គុយលាក់ខ្លួននៅក្នុងព្រៃ រួចក៏ចូលទៅចាប់ឃុំខ្លួនអ្នកលួចឆ្លងចូលប្រទេសដោយខុសច្បាប់តែម្តង។ ពលករដែលលួចឆ្លងដែននោះមានចំនួន២០នាក់ ក្នុងនោះមានប្រុស១៤នាក់ និងស្រី៦នាក់។

ក្រោយពីធ្វើការសាកសួរ ពលករខ្មែរទាំងអស់បានប្រាប់ថា រថយន្តទាំង២គ្រឿង បានដឹកពួកគេមកទម្លាក់ចោល ហើយបើកគេចបាត់ទៅ។ ជំហានដំបូងសមត្ថកិច្ចប្រាប់ថា ពលករខ្មែរទាំងនេះ ធ្វើដំណើរមកពីខេត្តបាត់ដំបង ,ខេត្ត បន្ទាយមានជ័យ,ខេត្តសៀមរាប និងខេត្តពោធិ៍សាត់របស់ប្រទេសកម្ពុជា ដោយចំណាយលុយឲ្យមេខ្យល់ក្នុងម្នាក់ចំនួន២,៥០០បាតទៅ៣០០០បាត រួចទៅហើយ។បន្ទាប់មកសមត្ថកិច្ចថៃបាននាំខ្លួនពលករខ្មែរខាងលើ ទៅសួរចម្លើយនិងធ្វើកំណត់ហេតុចាប់ឃុំខ្លួននៅអធិការតេម្រួតស្រុកតាព្រះយ៉ា ដើម្បីចាត់ការតាមច្បាប់បន្ត។ បន្ទាប់មកសមត្ថកិច្ចក៏បានចុះល្បាតបន្ថែមទៀត នឹងប្រទះឃើញរថយន្តតាក់ស៊ីពណ៌ខៀវ-លឿង ពាក់ស្លាកលេខมช-7430ក្រុងថេប ខណៈកំពុងដឹកពលករចេញពីភូមិខ្លង ផែង ទើបសមត្ថកិច្ចបើករថយន្តដេញតាម និងទំនាក់ទំនងតាមប៉ុស្តិ៍ត្រួតពិនិត្យ ឲ្យជួយស្ទាត់ចាប់ រហូតរថយន្តខាងលើបើកមកដល់បរិវេណប៉ុស្តិ៍ត្រួតពិនិត្យរបស់សមត្ថកិច្ចស្រុកតាព្រះយ៉ា ទើបចតរថយន្តត្រួតពិនិត្យ រកឃើញថា ឈ្មោះលោក សុថែន ទំផាក់កៀនជនជាតិថៃ អាយុ៤៥ឆ្នាំជាអ្នកបើករថយន្តស៊ីឈ្នួលដឹក ពលករខ្មែរ៦នាក់ ក្នុងនោះប្រុស៤នាក់ និងស្រី២នាក់។ ក្រោយធ្វើការសាកសួរសមត្ថកិច្ចក៏បញ្ជូនពលករខ្មែរទាំង៦នាក់ទៅប្រគល់ឲ្យជំនាញ ដើម្បីចាត់ការតាមនីតិវិធីបន្ត៕

## បញ្ជូនមេបនល្បីឈ្មោះម្នាក់ នៅតុលាការពីបទល្បួងក្មេងស្រី លក់ព្រហ្មចារីឲ្យតាតា

http://nokorwatnews.com/ 08-08-2020

ខេត្តប៉ៃលិនៈ សមត្ថកិច្ចនគរបាលខេត្តប៉ៃលិន បានកសាងសំណុំរឿងបញ្ជូនស្ត្រីមេបនជួញដូរផ្លូវភេទល្បីឈ្មោះម្នាក់ ទៅកាន់សាលាដំបូងខេត្តដើម្បីធ្វើការសាកសួរ និងចោទប្រកាន់ ទៅតាមផ្លូវច្បាប់ក្រោយរំដោះក្មេងស្រី

រងគ្រោះ៥នាក់ចេញពីផ្ទះជួញដូរផ្លូវភេទ។ មន្ត្រីនគរបាលខេត្តប៉ៃលិន បានប្រាប់ឲ្យដឹងថា ស្ត្រីមេបន ល្បីឈ្មោះម្នាក់ ដែលមានជំនាញ លួងក្មេងស្រី លក់ឲ្យតាតានិង អ្នកមានលុយត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន សហការជាមួយ ការិយាល័យនគរបាល ព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាល ខេត្តប៉ៃលិនឃាត់ខ្លួនបានកាលពីថ្ងៃទី៥ខែសីហារួចកសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងខេត្តនៅរសៀលថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ បន្ទាប់ពីឃាត់ខ្លួនបាន នៅត្រង់ចំណុច ភូមិអូរតាពុកក្រោម សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ ប្រភពដដែល បានបញ្ជាក់ថា មេខ្យល់ល្បីឈ្មោះនោះឈ្មោះ ឡុង យ៉ា អាយុ២៨ឆ្នាំ មុខរបរ កោសជប់ ជ្រកកោនក្រោមស្លាក ផ្ទះសំណាក់ យីហោ " LSC " ឋិតនៅក្នុងសង្កាត់ទួលល្វា ក្រុងប៉ៃលិន។ ចំណែកនារីរងគ្រោះ ក្នុងបទល្មើសជួញដូរផ្លូវភេទនេះ មានចំនួន ៥ នាក់ ក្នុងនោះ ជនរងគ្រោះទី១-ឈ្មោះ ញ រ ន អាយុ១៦ឆ្នាំ,២- ឈ្មោះ ហ ស ថ អាយុ១៦ឆ្នាំ,៣- ឈ្មោះ យ រ ស អាយុ១៦ឆ្នាំ,៤-ឈ្មោះ ហ ស ដ អាយុ១៧ឆ្នាំ និង៥ឈ្មោះ អ ស ឡ អាយុ១៧ឆ្នាំ ទាំងអស់គ្នា រស់ នៅភូមិផ្សារព្រំ ក្រុងប៉ៃលិន ។

ក្រោយពីសាកសួរ រួចនៅថ្ងៃទី៦ខែសីហាឆ្នាំ២០២០ សមត្ថកិច្ចនគរបាលជំនាញ បានបញ្ជូនមេបនទៅកាន់សាលាដំបូង ខេត្តប៉ៃលិន ដើម្បីសាកសួរនិងចោទប្រកាន់តាមផ្លូវច្បាប់។ ឯស្ត្រីរងគ្រោះ៥នាក់ត្រូវបានអប់រំឲ្យវិលត្រឡប់ទៅលំនៅឋានវិញ៕

## ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០

## រដ្ឋាភិបាលថៃ អនុញ្ញាតឲ្យពលករខ្មែរ ភូមានិងឡាវ ទៅធ្វើការនៅប្រទេសថៃឡើងវិញ

http://kampucheathmey.com/ 10/8/2020 4:42 Pm

**ភ្នំពេញ ៖** លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឲ្យដឹងនៅថ្ងៃទី១០ សីហានេះថា រដ្ឋាភិបាលថៃ បានអនុញ្ញាតឲ្យប្រទេសចំនួន៣ នៅក្នុងតំបន់អាស៊ានរួមមានកម្ពុជា ភូមានិងឡាវ បញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅប្រទេសថៃឡើងវិញ បានចាប់ពី ខែសីហា ឆ្នាំ២០២០នេះតទៅ។ លោកបានបន្តថា ជាជំហានដំបូងក្នុង១ខែៗរដ្ឋាភិបាលថៃអនុញ្ញាតឲ្យប្រទេសកម្ពុជាបញ្ជូនពលករខ្មែរចំនួន២៤០០នាក់ ភូមា៤៥០០នាក់និងឡាវ១០០០នាក់ទៅធ្វើការនៅតាមក្រុមហ៊ុននានានៅប្រទេសថៃ ដោយផ្តោតទៅលើវិស័យសំណង់ និងចំណីអាហារ ដើម្បីការពារការឆ្លងរីករាលដាលជំងឺកូវីដ១៩។ លោកបានបន្ថែមទៀតថា ចំពោះលក្ខខណ្ឌវិញរដ្ឋាភិបាលថៃ មិនតម្រូវឲ្យពលករបរទេសទាំងនោះ មានវិញ្ញាបនបត្របញ្ជាក់ថា គ្មានជំងឺកូវីដ១៩នោះ ប៉ុន្តែត្រូវធ្វើតេស្តរកជំងឺកូវីដ១៩ពេលទៅដល់ប្រទេសថៃនិងតម្រូវឲ្យធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃជាមុនសិន មុននឹងអនុញ្ញាតឲ្យចូលធ្វើការដោយក្រុមហ៊ុនទទួលពលករនៅថៃជាអ្នកធានារ៉ាប់រងទាំងកន្លែងធ្វើចត្តាឡីស័ក អាហារបីពេល សម្ភារផ្សេងៗ និងការធ្វើតេស្តចំនួន២ដង ដែលសរុបការចំណាយទាំងអស់ចំនួន១៣៩០០បាតហើយ ក្នុងកំឡុងពេលធ្វើចត្តាឡីស័កនេះ ពលករទទួលបានប្រាក់ឈ្នួលចំនួនពាក់កណ្តាលនៃប្រាក់ខែគោលផងដែរ។

លោកបានឲ្យដឹងទៀតថា ក្នុងករណីពលករណាម្នាក់មានឆ្លងជំងឺកូវីដ១៩នោះ ថៅកែក្រុមហ៊ុនជាអ្នកធានារ៉ាប់រងទៅលើការព្យាបាលនិងសេវាផ្សេងៗទៀតរហូតដល់ចេញពីមន្ទីរពេទ្យ។ លោកបានបញ្ជាក់ថា តាមផែនការនៅឆ្នាំ២០២០នេះកម្ពុជាគ្រោងនឹងបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសប្រមាណ២០ម៉ឺននាក់ ក្នុងនោះប្រទេសថៃ១ម៉ឺននាក់ ជប៉ុន សឹង្ហបុរី ហុងកុងនិងម៉ាឡេស៊ីប៉ុន្តែ រហូតមកដល់ពេលនេះបញ្ជូនបានត្រឹមតែ៥ម៉ឺននាក់ប៉ុណ្ណោះដោយសារប្រទេសទាំងនោះមានបញ្ហាជំងឺកូវីដ១៩។ សូមរំលឹកថាបច្ចុប្បន្ននេះ កម្ពុជាមានពលករកំពុងធ្វើការនៅក្រៅប្រទេសប្រមាណ១លាន២សែននាក់ ក្នុងនោះប្រទេសថៃមានច្រើនជាងគេ គឺមានរហូត១លាននាក់ដោយបានផ្ញើថវិកាមកក្រុមគ្រួសារប្រមាណជាង២ពាន់លានដុល្លារអាមេរិកក្នុង១ឆ្នាំៗ ដែលបានជួយលើកស្ទួយដល់សេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិកាន់តែប្រសើរឡើងថែមទៀត៕ **អត្ថបទ៖ សំអឿន**

## សមត្ថកិច្ចថៃនៅស្រុកតាប្រាយ៉ាចាប់ពលករខ្មែរបញ្ជូនមាតុភូមិនិវត្តន៍

https://www.rasmeinews.com/ August 10, 2020, 6:17 PM

ដោយៈប.ជ័យ/ស្រះកែវថៃៈសមត្ថកិច្ចទាហានឈុតប៉ារ៉ា និងតម្រួតព្រំដែនថៃនៅស្រុកតាប្រាយ៉ាខេត្តស្រះកែវ បានចាប់ខ្លួន រួចបញ្ជូនមាតុភូមិនិវត្តន៍ពលករខ្មែរចំនួន២០ នាក់/ស្រី៦នាក់កាលពីថ្ងៃ៨ ខែសីហាឆ្នាំ២០២០ ខណៈពលករខ្មែរបានលួចឆ្លងដែនចូលប្រទេសថៃខុសច្បាប់តាមរយៈមេខ្យល់។ តម្រួតនគរបាលរដ្ឋបាលនៅស្រុកតាប្រាយ៉ាត្រូវស្រង់សម្តីដោយនគរបាលកម្ពុជានៅឃុំគោករមៀតបានឱ្យដឹងកាលពីថ្ងៃទី៩ ខែសីហាថាៈ ពលករខ្មែរដែលត្រូវសមត្ថកិច្ចថៃចាប់បានចំនួន២០នាក់ / ស្រី៦នាក់ នោះ គឺមេខ្យល់យកប្រាក់ថ្លៃជូន ហើយឆ្លងកាត់ព្រំដែនខាងកម្ពុជា ថៃរួច ។តម្រួតថៃចាប់ ហើយត្រូវនាំទៅធ្វើចត្តាឡីស័ករួចបញ្ជូនមកកម្ពុជាវិញនៅថ្ងៃទី១០ខែសីហាឆ្នាំ២០២០៕S/

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥នាក់

https://www.facebook.com/GDIOfficial 10-08-2020

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥នាក់ ស្រី ១៨នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០០នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃចំនួន ០៤នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 10-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នារសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរបានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃចំនួន ០៤នាក់ ស្រី ០២នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ និងសហការប្រគល់ជូនទៅមន្ត្រីចត្តាលីស័ក ដើម្បីធ្វើការពិនិត្យកំដៅ និងអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យចូល-ចេញ ជាធម្មតា៕

# ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០
# កម្ពុជា និងអង្គការសហប្រជាជាតិ ប្រកាសដំណើរការគម្រោងរួមគ្នា ប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 12 ខែ សីហា ឆ្នាំ 2020

AKP សៀមរាប ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០៖ នៅព្រឹកថ្ងៃ៧រោច ខែស្រាពណ៍ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃអង្គារ ទី១១ ខែសីហា ឆ្នាំ២០២០ នៅសាលប្រជុំសាលាខេត្តសៀមរាប មានធ្វើពិធីប្រកាសដំណើរការគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយវិបត្តិកូវីដ-១៩ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងលោកស្រី Kristin Parco ប្រធានអង្គការទេសន្តរប្រវេសន៍ អន្តរជាតិ ជាតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។ ពិធីនេះក៏មានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គលេខាធិការ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន៦ រដ្ឋបាលខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធមកពីខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ព្រមទាំងអង្គការ IOM អង្គការUN និងក្រោមការសម្របសម្រួលរបស់ គ.ជ.ប.ជ។

លោកជំទាវ យូ សុភាព អភិបាលរងខេត្ត និងជាលេខាធិការដ្ឋានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តសៀមរាប បានមានប្រសាសន៍ថា ការអនុវត្តគម្រោងរួមគ្នានេះ ពិតជាមានប្រយោជន៍ និងមានភាពចាំបាច់ណាស់ សម្រាប់នាំយកមកជាមួយនូវព័ត៌ មានថ្មីៗ ពីការរៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបនឹងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយវិបត្តិកូវីដ-១៩ ដែលអាចជាវិភាគទានដល់ការដោះស្រាយបញ្ហានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សំខាន់នោះ គឺជាការចែករំលែក ជួយសម្រាលការលំបាក និងការជួយគ្នាក្នុងគ្រាមានអាសន្នអន់ក្រ ហើយក៏ជាប្រពៃណីដែលថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ តែងតែប្រតិបត្តិជាប់ជាប្រចាំគ្រប់កាលៈទេសៈ មិនប្រកាន់ពណ៌សម្បុរ ជាតិសាសន៍ និន្នាការនយោបាយណាមួយឡើយ។ លោកជំទាវ យូ សុភាព បានឱ្យដឹងទៀតថា ចាប់តាំងពីកើតមានវិបត្តិជំងឺកូវីដ-១៩ ដោយគិតត្រឹមថ្ងៃទី១០ ខែមីនា ដល់ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០នេះ ប្រជាពលរដ្ឋត្រឡប់ពីក្រៅប្រទេសសរុបចំនួន ១៦.៣៦៨នាក់ ស្រី ៧.១៦១នាក់ ហើយត្រូវបានធ្វើចត្តាឡីស័កនៅក្នុងមណ្ឌលតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់ និងធ្វើការទប់ស្កាត់ការចំណាកស្រុកខុសច្បាប់តាម រយៈមេខ្យល់ បានចំនួន ២១០នាក់ ស្រី៨០នាក់ កុមារ ៧នាក់ ក្នុងនោះកុមារី ៥នាក់។

ក្នុងកិច្ចប្រជុំនោះលោកជំទាវ ជូ ប៊ុនអេង បានធ្វើការវាយតម្លៃ និងកោតសរសើរចំពោះ កិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តនូវសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាវិធានការណែនាំរបស់ក្រសួងសុខាភិបាល ក្នុងការប្រយុទ្ធប្រឆាំងបង្ការទប់ស្កាត់ពីការរីករាលដាលនូវជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ រួមទាំងការទប់ស្កាត់ចំពោះការធ្វើចំណាកស្រុកដោយខុសច្បាប់ តាមរយៈមេខ្យល់ ទទួលបានជោគជ័យទៀតផង។ លោកជំទាវ ក៏បានលើកឡើងផងដែរថា ពលករដែលងាយរងគ្រោះបំផុតគឺស្ត្រីមានផ្ទៃពោះ ជនរងគ្រោះដោយអំពើហិង្សាផ្នែកយេនឌ័រ និងកុមារ ត្រូវចាត់ជាអាទិភាពសម្រាប់ការកំណត់អត្តសញ្ញាណ ដំណើរការបញ្ជូនករណីនិងគាំទ្រសម្រាប់តាមដានបន្តកាន់តែប្រសើរឡើងនៅតាមសហគមន៍គោលដៅ។ លោកជំទាវ ជូ ប៊ុនអេង បានឱ្យដឹងទៀតថា ការកំណត់ជ្រើសរើសយកខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្តបាត់ដំបង ក្នុងការអនុវត្តគម្រោងរួមគ្នា ការពង្រឹងយន្តការរបស់រាជ រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសង្គមកិច្ច ព្រមទាំងបន្សុំផលប៉ះពាល់ដោយជំងឺកូវីដ-១៩ រយៈពេលមធ្យម ឬវែងដល់ពលករដែលងាយរងគ្រោះបំផុត សំខាន់ស្ត្រីជាមេគ្រួសារ។ គម្រោងរួមគ្នានេះ នឹងមានបំណងសម្រេចការធ្វើទេសន្តរប្រវេសន៍ ប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងនៅតាមព្រំដែនកាន់តែប្រសើរឡើងទៀតផង៕

# តុលាការកំពូល បើកសវនាការលើសំណុំរឿងជួញដូរមនុស្សឆ្លងដែន

https://www.postkhmer.com/ គីម សារុំ | Publication date 11 August 2020 | 14:16 ICT

**ភ្នំពេញៈ** តុលាការកំពូលពីម្សិលមិញបានបើកសវនាការជំនុំជម្រះបុរសជាប់ចោទម្នាក់ក្នុងចំណោម ៣ នាក់ (២ នាក់មិនប្ដឹងសារទុក្ខ) បន្ទាប់ពីសាលាឧទ្ធរណ៍ផ្ដន្ទាទោសពី ៨ ឆ្នាំដល់ ៩ ឆ្នាំពីបទចោទជួញដូរមនុស្សឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ដែលបានប្រព្រឹត្តនៅភូមិអន្សងពង ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាបកាលពីឆ្នាំ ២០០៩។

យោងកំណត់ហេតុរបស់តុលាការកំពូលបានបង្ហាញថា សំណុំរឿងនេះមានជនជាប់ចោទឈ្មោះ ណាក់ សម្បត្តិ ហៅ កែវ ជាអ្នករត់តាក់ស៊ី, ទី ២- ឈ្មោះ ង៉ែត ផល្លា និងឈ្មោះ មឿត គា។ នៅអំឡុងឆ្នាំ ២០០៩ ក្រុមជនជាប់ចោទបានដឹកបុរសរងគ្រោះទាំង ៦ នាក់ ពីភូមិអន្សងពង ឃុំកំពង់ក្ដីទៅក្រុងប៉ោយប៉ែត។ ពេលនោះជនជាប់ចោទ ណាក់ សម្បត្តិ ដែលជាអ្នករត់តាក់ស៊ីបានដាក់ជនរងគ្រោះទាំង ៦ នាក់នៅមុខវត្តប៉ាលិលេយ្យក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ហើយក្រុមជនរងគ្រោះត្រូវបានគេនាំចូលប្រទេសថៃ ធ្វើជាកម្មករទូកនេសាទ។ កំណត់ហេតុបង្ហាញទៀតថា ក្រោយពីក្រុមជនរងគ្រោះធ្វើការនៅលើទូកនេសាទបានជាង ៦ ឆ្នាំ ដោយរងការធ្វើបាបពីសំណាក់ថៅកែទូកនេសាទថៃមក ក្រុមជនរងគ្រោះបានព្យាយាមទំនាក់ទំនងទៅស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃហើយត្រូវបានស្ថានទូតកម្ពុជារំដោះពួកគេចេញពីទូកនេសាទ និងបញ្ជូនមកប្រទេសកម្ពុជាវិញនៅអំឡុងខែឧសភា ឆ្នាំ ២០១៦។ ពេលមកដល់ស្រុកកំណើតវិញក្រុមជនរងគ្រោះបានដាក់ពាក្យបណ្ដឹងទៅតុលាការ និងសមត្ថកិច្ចនគរបាលស្រុកជីក្រែង។ បន្ទាប់មកសមត្ថកិច្ចបានស្រាវជ្រាវរកឃើញថាក្រុមជនជាប់ចោទជាអ្នករៀបចំចាត់ចែងក្នុងអំពើជួញដូរមនុស្សឆ្លងដែនមែន។ កំណត់ហេតុរបស់តុលាការកំពូលឲ្យដឹងទៀតថា ក្រោយពីតុលាការខេត្តសៀមរាបទទួលបានពាក្យបណ្ដឹងរបស់ក្រុមជនរងគ្រោះមក តុលាការខេត្តសៀមរាបបានចេញដីកាបង្គាប់ឲ្យសមត្ថកិច្ចតាមចាប់ខ្លួនជនជាប់ចោទទាំង ៣ នាក់ដែលសមត្ថកិច្ចប្រើពេលស្រាវជ្រាវរហូតដល់ខែវិច្ឆិកា ឆ្នាំ ២០១៦ ទើបចាប់ក្រុមជនជាប់ចោទបាន។

សំណុំរឿងនេះត្រូវបានសាលាដំបូងខេត្តសៀមរាបប្រកាសសាលក្រមនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៧ សម្រេចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ ណាក់ សម្បត្តិ ដាក់ពន្ធនាគារ ៨ ឆ្នាំ និងជនជាប់ចោទឈ្មោះ ង៉ែត ផល្លា និងឈ្មោះ មឿត គា ដាក់ពន្ធនាគារម្នាក់ៗ ៩ ឆ្នាំចោទបទការនាំចេញដោយមិនស្របច្បាប់សម្រាប់ការនាំឆ្លងដែនតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ នៅក្នុងបន្ទប់សវនាការជនជាប់ចោទឈ្មោះ ណាក់ សម្បត្តិ និយាយប្រាប់ចៅក្រមថា គាត់មិនបានអូសទាញក្រុមជនរងគ្រោះឲ្យទៅធ្វើការនៅប្រទេសថៃ ទេ។ ប៉ុន្តែក្រុមជនរងគ្រោះបានមកទាក់ទងគាត់ឲ្យដឹកពួកគេពីស្រុកជីក្រែងទៅក្រុងប៉ោយប៉ែតដែលក្នុងមនុស្សម្នាក់គាត់យកថ្លៃដឹក ៤ ម៉ឺនរៀល។ ជនជាប់ចោទនិយាយថា៖ «ខ្ញុំមិនស្គាល់ជនរងគ្រោះទាំង ៦ នាក់នោះទេ ប៉ុន្តែពួកគេជួលឡានខ្ញុំជិះទៅក្រុងប៉ោយប៉ែត។ ខ្ញុំសុំឲ្យតុលាការកំពូលដោះលែងខ្ញុំឲ្យមានសេរីភាពវិញ។ ព្រោះខ្ញុំមិនបានប្រព្រឹត្តទេ»។

លោក ជុំ សំបាន តំណាងមហាអយ្យការសន្និដ្ឋានថា ការសម្រេចតម្កល់សាលក្រមរបស់សាលាឧទ្ធរណ៍ត្រឹមត្រូវហើយ។ ដូច្នេះសូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាតាមច្បាប់។

លោក នូ ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ណាក់ សម្បត្តិ បានថ្លែងប្រាប់ចៅក្រមក្នុងបន្ទប់សវនាការពីម្សិលមិញថា ករណីនេះតាមអង្គហេតុឃើញថា ក្រុមជនរងគ្រោះបានជួលរថយន្តកូនក្ដីលោកជិះម្នាក់ៗថ្លៃ ៤ ម៉ឺនរៀល ហើយពេលទៅដល់ក្រុងប៉ោយប៉ែតគាត់ទម្លាក់ក្រុមជនរងគ្រោះចុះ កូនក្ដីលោកមិនបានដឹកក្រុមជនរងគ្រោះចូលក្នុងប្រទេសថៃទេ។ លោកថា៖ «ករណីនេះ ខ្ញុំសុំឲ្យតុលាការកំពូលបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ជម្រះឡើងវិញ»។

ក្រោយជំនុំជម្រះលោក ឃឹម ប៉ុណ្ណ ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានថ្លែងថា សាលដីកានេះប្រកាសនៅថ្ងៃទី ១៤ សីហា។ លោក ជា ណារ៉ា ជាមេធាវីការពារសិទ្ធិឲ្យក្រុមជនរងគ្រោះទាំង ៦ នាក់ថ្លែងថាសំណុំរឿងនេះកូនក្ដីលោកមិនបានដាក់បណ្ដឹងសារទុក្ខមកតុលាការកំពូលទេ៕

# ៦ ខែ អាជ្ញាធរខេត្តបន្ទាយមានជ័យទប់ស្កាត់ពលរដ្ឋលួចឆ្លងដែនទៅថៃបានជាង ៤០០ នាក់

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 11 August 2020 | 09:43 ICT

**បន្ទាយមានជ័យៈ** លោក ឈុន ម៉ៅ មេបញ្ជាការប្រចាំទិសទី ១ នៃខេត្តបន្ទាយមានជ័យបានឲ្យដឹងថា គិតចាប់ពីខែកុម្ភៈដល់ដើមខែសីហា ឆ្នាំ ២០២០ កម្លាំងយោធានៃយោធភូមិភាគទី៥ បានរួមគ្នាទប់ស្កាត់ប្រជាពលរដ្ឋដែលលួចឆ្លងដែនទៅប្រទេសថៃ តាមច្រករបៀងនានាក្នុងខេត្តបន្ទាយមានជ័យបានជាង ៤០០ នាក់។ លោក ឈុន ម៉ៅ បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញទៀតថា សម្រាប់តួលេខ ១ ខែ ក្នុងខែកក្កដា វិញ ចំពោះអ្នកវិលត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែនខេត្តបន្ទាយមានជ័យគឺមានជាង ៧ ០០០ នាក់ ចំណែកអ្នកលួចឆ្លងដែនដោយខុសច្បាប់ចូលទៅទឹកដីថៃដែលត្រូវបានឃាត់ខ្លួន គឺមានចំនួនតិចតួចប៉ុណ្ណោះព្រោះមានតែជាង ១០ ករណី សម្រាប់ខែកក្កដា។ លោកមេបញ្ជាការប្រចាំទិសទី១ រូបនេះបញ្ជាក់ថា មូលហេតុដែលពលរដ្ឋសម្រេចចិត្តវិលប្រឡប់ទៅប្រទេសថៃ និងវិលចូលមកកម្ពុជាវិញក៏ព្រោះបណ្ដាលមកពីកត្តាអត់ការងារធ្វើ។ លោកបន្តថា ពួកគាត់គ្មានការងារធ្វើនៅប្រទេសថៃ ហើយបានត្រឡប់មកកម្ពុជាវិញហើយរកការងារធ្វើមិនបាន ក៏សម្រេចវិលត្រឡប់ទៅប្រទេសថៃវិញ ប៉ុន្តែពលរដ្ឋភាគច្រើនដែលបានវិលត្រឡប់ទៅប្រទេសថៃ ត្រូវបានទប់ស្កាត់ទាន់ពេលវេលា។

លោកបញ្ជាក់ថា៖ «ជាង ៤០០ នាក់ទេ ចេញពីខ្មែរទៅថៃ ទៅរកការងារធ្វើ ដែលយើងចាប់បាន និងថៃគាត់ឃាត់បាន ហើយបញ្ជូនមកយើងវិញនៅតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ ការព្យាយាមចេញ និងចូលប្រទេសនៅពេលនេះគឺបង្កការលំបាកណាស់ ព្រោះយើងត្រូវចំណាយពេលបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័កនៅតាមស្រុកកំណើតរបស់ពួកគាត់វិញហើយយើងក៏ចំណាយថវិកា និងកម្លាំងដែរ»។ បើតាមលោក ឈុន ម៉ៅ ក្នុងរយៈពេលចុងក្រោយនេះចំនួនពលរដ្ឋដែលបានត្រឡប់ពីប្រទេសថៃចូលប្រទេសវិញ គឺមានចំនួនថយចុះ បើធៀបនឹងដើមឆ្នាំ ដែលមានចន្លោះពី ៤០០ ទៅ ៥០០ នាក់ មកនៅត្រឹម២០០ ឬ ៣០០ នាក់ប៉ុណ្ណោះ ក្នុង ១ ថ្ងៃ។

កាលពីថ្ងៃទី ៨ សីហា លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានឲ្យដឹងថា ក្នុងអំឡុងពេលដែលថៃបិទច្រកទ្វារព្រំដែនជាមួយកម្ពុជាចាប់តាំងពីខែមីនា មកមានប្រជាពលរដ្ឋខ្មែរប្រមាណ ១ ពាន់នាក់ បានចាញ់បោកមេខ្យល់ដោយព្យាយាមចូលទៅប្រទេសថៃ ប៉ុន្តែត្រូវបានថៃចាប់បញ្ជូនមកវិញ។

លោក យុន ថារ៉ូ អ្នកសម្របសម្រួលមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងការងារហៅកាត់ថា សង់ត្រាល់ (CENTRAL) បានលើកឡើងថា មកដល់ពេលនេះពលករចំណាកស្រុកកម្ពុជានៅតែបន្តធ្វើចំណាកស្រុកទាំងប្រថុយប្រថាននៅតាមច្រករបៀងតូចៗ បើទោះបីជាមានការបិទព្រំដែន និងមានការយាមកាមយ៉ាងតឹងរ៉ឹងពីសំណាក់កម្លាំងសមត្ថកិច្ចថៃ និងកម្ពុជា។ លោកបន្តថា ការឆ្លងដែននេះគឺធ្វើឡើងតាមរយៈមេខ្យល់ ឬតាមទំនៀមទម្លាប់នៃការធ្វើចំណាកស្រុក ដោយធ្វើឡើងតាមរយៈអ្នកស្គាល់ ឬបងប្អូន ហើយរូបភាពបែបនេះគឺនៅតែបន្តកើតឡើង គឺអត់មានភាពស្រាកស្រាន្តនោះទេ។ លោកបញ្ជាក់ថា៖ «នៅពេលគាត់ធ្វើចំណាកស្រុកគឺគាត់ត្រូវចំណាយថវិកាផ្ទាល់ខ្លួនឲ្យទៅមេខ្យល់ និងអ្នកដែលស្គាល់ហ្នឹង ដើម្បីអាចឆ្លងកាត់តាមព្រំដែនបានដោយមិនមានការធានាពីសុវត្ថិភាពរបស់ប្រជាពលរដ្ឋនោះទេ ហើយក្នុងករណីដែលអាចឆ្លងដែនបានមែន ក៏ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកវិញដែរ»។

លោក យុន ថារ៉ូ ក៏បានលើកឡើងទៀតថា ប្រជាពលរដ្ឋចំណាកស្រុកមួយចំនួនបានដឹងច្បាស់អំពីផលវិបាកនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ ១៩ ប៉ុន្តែដោយសារតែគ្មានជម្រើសអ្វីក្រៅពីនេះទើបសម្រេចចិត្តទាំងប្រថុយប្រថានក្នុងការធ្វើចំណាកស្រុកឆ្លងដែនទៅប្រទេសថៃ ព្រោះតែបញ្ហាសេដ្ឋកិច្ចគ្រួសារ។ លោកថា រដ្ឋាភិបាលត្រូវតែមានវិធានការបន្ថែមទៀតដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកនេះ។ លោកបញ្ជាក់ថា៖ «រដ្ឋាភិបាលគួរតែរក

លទ្ធភាពណាមួយក្នុងការបើកច្រកព្រំដែនក្នុងកម្រិតណាមួយ ដែលអាចឲ្យពលរដ្ឋនៅតាមបន្ទាត់ព្រំដែនអាចប្រកបអាជីវកម្មរបស់ខ្លួន ដើម្បីចិញ្ចឹមជីវិត។ ម្យ៉ាងទៀត រដ្ឋាភិបាលក៏គួរតែបង្កើតការងារនៅក្នុងប្រទេសឲ្យបានច្រើនបន្ថែមទៀត ដូចជារោងចក្រ សួនឧស្សាហកម្មនៅតាមបណ្ដាខេត្តផ្សេងៗរួមទាំងការបន្តផ្សព្វផ្សាយនូវព័ត៌មានជុំវិញការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពផងដែរ»៕

## លោក លឹង សុផុន៖ ការចំណាកស្រុកខុសច្បាប់ទាំងប្រថុយប្រថានទៅប្រទេសថៃនឹងមានការកើនឡើង

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 11/08/2020 - 12:56 ដោយ៖ញឹម សុផល

លោក លឹង សុផុន មន្ត្រីនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (Central) ទទួលបន្ទុកខាងកិច្ចការអន្តោប្រវេសន៍៖ ពលករអន្តោប្រវេសន៍ខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃតាមរយៈកិច្ចព្រមព្រៀង (MOU) រវាងកម្ពុជា-ថៃ និងពលករដែលផុតសុពលភាពលិខិតឆ្លងដែន និងលិខិតធ្វើដំណើរ រួមនឹងពលករដែលចេញ ចូលថៃវិលល្ហាច ត្រូវបានរដ្ឋាភិបាលថៃសម្រេចឲ្យបន្តសុពលភាពស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃជាបន្ត ទៅតាមកាលកំណត់ផ្សេងៗគ្នា។ លោក លឹង សុផុន មន្ត្រីទទួលបន្ទុកកិច្ចការអន្តោប្រវេសន៍នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស បានថ្លែងពីខេត្តធុនបុរី នៃប្រទេសថៃមកថា ពលករចំណាកស្រុកខ្មែរដែលបានចេញពីថៃអំឡុងពេលថៃបិទប្រទេសដោយសារកូវីដ១៩កន្លងទៅ ប្រមាណជាង១០ម៉ឺននាក់ នឹងអាចវិលទៅរកការងារដើមរបស់ខ្លួនវិញនៅក្នុងប្រទេសថៃ។

## ពលករខ្មែរចំណាកស្រុក 20នាក់ ត្រូវយោធាថៃឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១៨:២៥ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរចំណាកស្រុកចំនួន២០នាក់ទៀត បានត្រូវកម្លាំងយោធាថៃឃាត់ខ្លួនកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ នៅក្នុងស្រុកតាប្រយ៉ា ខេត្តស្រះកែវ ។ មន្ត្រីយោធាដែលឈរជើងតាមបន្ទាត់ព្រំដែនបានប្រាប់ថា ពលករខ្មែរចំណាកស្រុកដែលត្រូវទាហានថៃឃាត់ខ្លួនចំនួន២០នាក់នេះ មានប្រុស១៤នាក់ ស្រី៦នាក់ ។ ពួកគាត់បានឆ្លងដែនខុសច្បាប់ក្នុងភូមិសាស្ត្រស្រុកថ្មពួក ចូលទៅក្នុងទឹកដីថៃ ដើម្បីទៅរកការងារធ្វើនៅក្រុងបាងកកប្រទេសថៃ ហើយនៅពេលឆ្លងដែនចូលដល់កណ្ដាលព្រៃទឹកដីថៃ ក៏ត្រូវកម្លាំងយោធាថៃឃាត់ខ្លួន ។ មន្ត្រីដដែលឲ្យដឹងទៀតថា ពលករខ្មែរដែលត្រូវបានយោធាថៃឃាត់ខ្លួនតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃនោះ គ្រោងបញ្ជូនមកវិញតាមច្រកព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅ ដែលមានក្រុមគ្រូពេទ្យចត្តាឡីស័កធ្វើការត្រួតពិនិត្យ រួចហើយបញ្ជូនទៅតាមមូលដ្ឋានរបស់ខ្លួនវិញ ។

គួររំឭកថា ស្ទើរតែរៀងរាល់ថ្ងៃដែលកម្លាំងយោធាថៃឃាត់ខ្លួនពលករខ្មែរតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ហើយដឹកបញ្ជូនមកវិញតាមច្រកព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅ ។ ពលករខ្មែរភាគច្រើន ឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅទីក្រុងបាងកកប្រទេសថៃ ដែលជាការលួចឆ្លងដែនក្រោយពីជំងឺកូវីដ-១៩ កំពុងត្រូវបានរឹតបន្តឹងទាំងនៅថៃនិងកម្ពុជា ។

អភិបាលខេត្ត ឯកឧត្តម អ៊ុំ រាត្រី តែងតែដាក់វិធានការដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវមានវិធានការទប់ស្កាត់ឱ្យបាននូវពលករចំណាកស្រុកដោយខុសច្បាប់ ដើម្បីការពារសុវត្ថិភាពពួកគាត់ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅពេលដែលប្រទេសថៃកំពុងទប់ស្កាត់ដូចគ្នា ។ ជាមួយនេះ ត្រូវស្រាវជ្រាវរកមុខ

សញ្ញាមេខ្យល់ដែលឃុបឃិតគ្នានាំពលករខុសច្បាប់ចេញ គឺត្រូវចាត់វិធានការតាមច្បាប់ ។ ទោះបីជាបែបណា ពលករទាំងនេះនៅតែធ្លាយចេញរាល់ថ្ងៃ ៕

## នាយឧត្តមសេនីយ៍ នេត សាវឿន អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ និងលើកទិសដៅបន្តរបស់ គ.ជ.ប.ជ

http://ppd-news.net/ ថ្ងៃចេញផ្សាយ: August 12, 2020

**ភ្នំពេញ** ៖ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងជាប្រធានក្រុមការងារអនុវត្តច្បាប់ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នាព្រឹកថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០នេះ អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចប្រតិបត្តិការប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២០ របស់ក្រុមការងារអនុវត្តច្បាប់ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅអគ្គស្នងការដ្ឋាននគរបាលជាតិ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ២៤នាក់ បានធ្វើដំណើរតាមច្រករបៀងស្ពានឆ្វេង-ស្ពានស្តាំប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 11-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្ពានឆ្វេង-ស្ពានស្តាំចំនួន ២៤នាក់ ស្រី ១១នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៧នាក់

https://www.facebook.com/GDIOfficial 11-08-2020

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៧នាក់ ស្រី ២៤នាក់៕

# ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាម ជួយសម្របសម្រួលឱ្យស្ត្រីខ្មែរម្នាក់ដែលបាន ចាញ់បោកមេខ្យល់ ត្រលប់មកមាតុប្រទេសវិញ

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 11 ខែ សីហា ឆ្នាំ 2020 AKP

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម

## សេចក្តីជូនព័ត៌មាន

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្តហាហ្សាង វៀតណាម បានសង្គ្រោះនារីរងគ្រោះ១រូប ដែលចាញ់បោកមេខ្យល់ និងបានបញ្ជូនទៅដាក់មជ្ឈមណ្ឌលដាច់ដោយឡែករយៈពេល១៤ថ្ងៃ ព្រមទាំងបានរៀបចំបែបបទត្រឡប់ទៅកម្ពុជាវិញតាមរថភ្លើងពីទីក្រុងហាណូយ នៅថ្ងៃទី១១ ខែសីហា និងទៅដល់ទីក្រុងហូជីមិញ វេលាម៉ោង ០៥H០០ ព្រឹក ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ដែលនៅទីនោះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ ជួយសម្រួលការធ្វើដំណើរបន្តទៅដល់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត។

នារីរងគ្រោះនោះ កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ នៅស្រុកកំពង់ត្រាច ខេត្តកំពត។

ស្ថានទូតបានជួយឧបត្ថម្ភថ្លៃធ្វើដំណើរ ការស្នាក់នៅ ហូបចុក និងឧបត្ថម្ភថវិកា ៥០ ម៉ឺនដុង។

ស្ថានទូតបានផ្តាំផ្ញើដល់នារីរងគ្រោះនោះ ពេលទៅដល់មាតុប្រទេសវិញខិតខំ ប្រកបមុខរបរតាមសមត្ថភាព។៚

ថ្ងៃអង្គារ ៧រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ទីក្រុងហាណូយ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២០

71 Tran Hung Dao, Hoan Kiem District, Hanoi, Viet Nam. camemb.vnm@mfaic.gov.kh Tel: +(84-4) 39424788

# ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ អំពាវនាវពលរដ្ឋបញ្ឈប់ធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់ ជាពិសេសក្នុងវិបត្តិរាតត្បាតជំងឺកូវីដ-១៩

http://www.freshnewsasia.com/ 2020-08-13 12:11pm

**(បន្ទាយមានជ័យ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានអំពាវនាវប្រជាពលរដ្ឋ ត្រូវបញ្ឈប់សកម្មភាព ធ្វើការចំណាកស្រុកឆ្លងដែនទៅប្រទេសជិតខាង ដោយប្រថុយប្រថាន និងខុសច្បាប់ដែលអាចនឹងប្រឈមគ្រោះថ្នាក់បានគ្រប់ពេលវេលា ក្នុងវិបត្តិរាតត្បាតនៃជំងឺកូវីដ-១៩។ ការអំពាវនាវបែបនេះរបស់លោកស្រី ជូ ប៊ុនអេង បានធ្វើឡើងក្នុងឱកាសដែលលោកស្រី និងក្រុមការងារចុះជួបសំណេះសំណាល និងនាំយកអំណោយជូនប្រជាពលរដ្ឋជាពលករស្ត្រីជាង ១០០ នាក់ ដែលត្រឡប់ពីប្រទេសថៃ ក្នុងវិបត្តិរាតត្បាតនៃជំងឺកូវីដ-១៩ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០នៅភូមិចំការត្រដោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។ ស្ថិតនៅក្នុងឱកាសនោះដែរ លោកស្រី ជូ ប៊ុនអេង បានផ្តាំផ្ញើដល់ប្រជាពលរដ្ឋត្រូវរកការងារធ្វើក្នុងស្រុក និងបង្កបង្កើនផលដាំដំណាំកសិកម្ម សម្រាប់តម្រូវការទីផ្សារក្នុងស្រុក ដើម្បីផ្គត់ផ្គង់ ជីវភាពគ្រួសារ ជាការកាត់បន្ថយជួបការលំបាកក្នុងវិបត្តិរាតត្បាតកូវីដ-១៩ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជា ទប់ស្កាត់បន្លែផ្លែឈើប្រទេសជិតខាង ជាការលើកកម្ពស់ជីវភាពគ្រួសារ។

លោក វ័ន្ត ដាស៊ីណង់ អភិបាលស្រុកមង្គលបូរី បានឱ្យដឹងថា ប្រជាពលរដ្ឋជាពលករស្ត្រីដែលត្រឡប់ពីប្រទេសថៃ ក្នុងវិបត្តិរាតត្បាតជំងឺកូវីដ-១៩ ចំនួន១០០នាក់ នៅក្នុងស្រុកមង្គលបូរី ត្រូវទទួលអំណោយលោកស្រី ជូ ប៊ុនអេង ដើម្បីសម្រាលការលំបាកបានមួយគ្រាផងដែរ។ លោកបានបញ្ជាក់ថា ស្រុកមង្គលបូរី សម្រាប់គ្រួសារក្រីក្រក្នុងជុំទី១ ជុំទី២ មានចំនួន៤,៧៨៣គ្រួសារ ក្នុងនោះមានគ្រួសារក្រ១ មានចំនួន១,៧៥២គ្រួសារ ក្រ២ មានចំនួន៣,០៣១គ្រួសារ។ ប្រជាពលរដ្ឋងាយរងគ្រោះដោយជំងឺកូវីដ-១៩ ដែលទទួលគោលនយោបាយពីរាជរដ្ឋាភិបាលកម្ពុជា គឺតត្រឹមថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ដែលមានបណ្ណក្រីក្រ មានចំនួន ១៨១គ្រួសារ បណ្ណក្រីក្រ២ មានចំនួន ២៦៣គ្រួសារ៕

## នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២០ របស់ក្រុមការងារអនុវត្តច្បាប់ នៃគ.ជ.ប.ជ

https://cambodiapolice.com/policekh/ 9:49 pm 12 សីហា 2020

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០នេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងជាប្រធានក្រុមការងារអនុវត្តច្បាប់ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលកិច្ចសហប្រតិបត្តិការប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០២០ របស់ក្រុមការងារអនុវត្តច្បាប់ នៃគ.ជ.ប.ជ។ កិច្ចប្រជុំប្រារព្ធធ្វើឡើងនៅសាលប្រជុំអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន និងសមាជិក នៃគ.ជ.ប.ជ មកពីស្ថាប័នផ្សេងៗដែលពាក់ព័ន្ធចំនួន៩ផងដែរ។

មានប្រសាសន៍ក្នុងអង្គប្រជុំ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានណែនាំឲ្យបង្កើតក្រុមប្រចាំការ២៤ម៉ោង លើ២៤ម៉ោង ដើម្បីចាំទទួលការឆ្លើយតប ទទួលរបាយការណ៍ និងទទួលកិច្ចសហការដើម្បីធ្វើការសម្របសម្រួលទាន់ពេលវេលា។ ឯកឧត្តមបន្តថា ពាក់ព័ន្ធនិងក្រុមការងារអនុវត្តច្បាប់គឺជាកិច្ចការដ៏ធំមួយក្នុង

ការលើកកិត្តិយសថ្នាក់ជាតិ។ ហើយឯកឧត្តមក៏បានទទូចឲ្យមានការត្រួតពិនិត្យរបាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស និងឆមាស ដែលក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងនាមជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សទាំងអស់ជាអ្នកអនុវត្តច្បាប់ចូលរួមទាំងអស់គ្នា ដើម្បីសហការទទួលបានជោគជ័យ។ ឯកឧត្តមអគ្គស្នងការនគរបាលជាតិ ក៏បានដាក់ទិសដៅចំនួន៥ សម្រាប់អង្គប្រជុំយកមកធ្វើការអនុវត្តដែលក្នុងនោះរួមមានៈ

ទី១-ត្រូវបង្កើនការផ្សព្វផ្សាយអប់រំឲ្យបានចំគោលដៅ និងចំទីតាំង ត្រូវជូនខ្លឹមសារដល់ប្រជាពលរដ្ឋក្នុងសហគមន៍ឲ្យមានការយល់ដឹងសំដៅធ្វើយ៉ាងណាកុំឲ្យពួកគាត់ចាញ់បោកការលួងលោមរបស់ក្រុមមេខ្យល់។

ទី២-ត្រូវបង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ដោយកៀងគរឲ្យមានការបណ្តុះបណ្តាលធនធានមន្ត្រី គ្រូបង្គោលនៅនិងកន្លែង។

ទី៣-ត្រូវបង្កើនគំនិតបច្ចេកទេសស៊ើបអង្កេតដល់នគរបាលយុត្តិធម៌ និងមន្ត្រីអាវុធហត្ថ ដែលជារឿងមួយសំខាន់សម្រាប់ការផ្តន្ទាទោស និងកាត់ក្តីឲ្យចំអ្នកប្រព្រឹត្តបទល្មើស។

ទី៤-ត្រូវជំរុញកិច្ចសហការទាំងការសហការផ្ទៃក្នុងរវាងនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថ សហការជាមួយស្ថាប័នច្បាប់ និងសហការជាមួយស្ថាប័នបរទេសរួមទាំង NGO ផងដែរ។

ទី៥-ជំរុញឲ្យមានការបើកសហប្រតិបត្តការ បើកការស៊ើបអង្កេត ការកាត់ក្តីឲ្យបានច្រើន ដើម្បីកាត់បន្ថយការកកស្ទះសំនុំរឿង នៅមានជនជាប់ឃុំជាច្រើនដែលមិនទាន់កាត់ក្តីនៅឡើយ។

ជាចុងក្រោយ ឯកឧត្តមអគ្គស្នងការនគរបាលជាតិ បានសំណូមពរយ៉ាងទទូចឲ្យសមាសភាពក្រុមការងារអនុវត្តច្បាប់ ដែលបានតែងតាំង សូមឲ្យចូលរួមបំពេញការងារ ក៏ដូចជាការចូលរួមប្រជុំឲ្យបានទៀងទាត់ ប្រសិនបើមានការរវល់ចាំបាច់មិនបានចូលរួម សូមឲ្យមានការរៀបចំមន្ត្រីដើម្បីទទួលបន្ទុកការងារ ដើម្បីកុំឲ្យដាច់ចរន្តនៃការងារ។

របាយការណ៍បូកសរុបសភាពការណ៍ និងលទ្ធផលឆមាសទី១ គិតត្រឹមថ្ងៃទី១៩ ឧសភា ឆ្នាំ២០២០ របស់ក្រុមការងារអនុវត្តច្បាប់ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ ជ ប ជ) បានឲ្យដឹងថា ពលករចំណាកស្រុកទៅក្រៅប្រទេសមានចំនួន៣១ម៉ឺន៩ពាន់៥០៦នាក់ (ស្ត្រីចំនួន១៩ម៉ឺន១ពាន់៦១៣នាក់) អនីតិជនមានចំនួន៥២៣៨នាក់ (ស្រី២០៥៧នាក់) ដែលក្នុងនោះ ពលករស្របច្បាប់មានចំនួន២១ម៉ឺន៩ពាន់១៤២នាក់(ស្ត្រី១៤ម៉ឺន២ពាន់៩៩៣នាក់) អនីតិជន ៧០១នាក់(ស្រី២៧៩នាក់) និងពលករចំណាកស្រុកមិនស្របច្បាប់មានចំនួន ១០ម៉ឺន៣៦៤នាក់(ស្ត្រី៤ម៉ឺន ៨ពាន់៦២០នាក់) មានអនីតិជន៤៥៣៧នាក់(ស្រី១៧៧៨នាក់)។ ដោយឡែករយៈពេល២ខែចុងក្រោយនេះ ស្នងការនគរបាលរាជធានី-ខេត្ត បានប្រមូលទិន្នន័យពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញទាំងស្របច្បាប់ និងមិនស្របច្បាប់ចំនួន១៥ម៉ឺន៨ពាន់៨៩នាក់ (ស្ត្រី៦ម៉ឺន ៨ពាន់១៩១នាក់) អនីតិជន៣០៥៥នាក់៕

## ពលករខ្មែរ ឈ្មោះ វ៉ាន់ ឡុន ជួបឧបទ្ទវហេតុផ្ទុះធុងហ្គាស លើទូកនេសាទ បណ្តាលឲ្យលិចក្នុងសមុទ្រ បច្ចុប្បន្ន មានសុខភាពល្អធម្មតា

https://dap-news.com/national/ BySS107 Posted on August 12, 2020

ភ្នំពេញ ៖ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានឲ្យដឹងថា ពលករខ្មែរម្នាក់ឈ្មោះ វ៉ាន់ ឡុន ដែលបានជួបឧបទ្ទវហេតុផ្ទុះធុងហ្គាសនៅលើទូកនេសាទ បណ្តាលឱ្យលិចក្នុងសមុទ្រ ទទួលបានការជួយសង្គ្រោះ និងការយកចិត្តទុកដាក់ពីស្ថានទូត ហើយបច្ចុប្បន្ន គាត់មានសុខភាពល្អធម្មតា។ យោងតាម គេហទំព័រ ហ្វេសប៊ុក ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ នៅថ្ងៃពុធទី១២ ខែសីហា ឆ្នាំ២០២០ បានបញ្ជាក់ថា ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកស្រុកមឿង ខេត្តរ៉ាក់យ៉ង ដើម្បីជួបសួរសុខទុក្ខពលករខ្មែរឈ្មោះ វ៉ាន់ ឡុន ភេទប្រុស អាយុ២៥ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង ដែលបានជួបឧបទ្ទវហេតុផ្ទុះធុងហ្គាសនៅលើទូកនេសាទបណ្តាលឱ្យលិច ក្នុងសមុទ្រ

កាលពី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០ កន្លងទៅ។ ប្រភព ដដែល បន្តថា គាត់បានបណ្តែតខ្លួននៅលើសមុទ្ររយៈពេល ៤ថ្ងៃ ដោយប្រើប្រាស់គម្របធុងក្លាសេទឹកក ដែលបានយកជាប់ខ្លួន បន្ទាប់មកត្រូវបានជួយសង្គ្រោះនិងបញ្ជូនទៅកាន់មន្ទីរពេទ្យនៅ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ដោយនៅលើជើងខ្លួន មានស្នាមរបួស ដោយសារភ្លើងរលាកនិងត្រីខាំ ជាច្រើនកន្លែង។ ទន្ទឹមនេះ ស្ថានទូត បានពាំនាំគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន ឧបត្ថម្ភដល់រូបគាត់ ព្រមទាំងទាមទារអត្ថប្រយោជន៍ផ្សេងៗ ពីនិយោជកដល់រូបគាត់ផងដែរ៕ដោយៈ អេង ប៊ូធេង

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 12-08-2020

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃបានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន១០២នាក់ ស្រី៤៤នាក់៕

## ប្រជាពលរដ្ឋខ្មែរ ចំនួន ៤៣នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 12-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៣នាក់ ស្រី ២៣នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៧នាក់ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 12-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៧នាក់ ស្រី ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ និងស្ថានឯកអគ្គរាជទូតកម្ពុជា នៅទីក្រុងហាណូយ បានទៅទទួលនារីខ្មែរ ដែលរងគ្រោះដោយការជួញដូរ ពីអាជ្ញាធរវៀតណាម

https://www.facebook.com/tvkchannel7/ ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 13-08-2020

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងហូជីមិញ សហការជាមួយស្ថានឯកអគ្គរាជទូតកម្ពុជា នៅទីក្រុងហាណូយ និងអាជ្ញាធរវៀតណាម បានទៅទទួលនារីខ្មែរ ០១រូប ដែលរងគ្រោះដោយការជួញដូរ នៅស្ថានីយ៍រថភ្លើង ទីក្រុងហូជីមិញ នៅម៉ោង ៥៖០០នាទីព្រឹក ហើយបន្តដំណើរទៅច្រកទ្វារ ព្រំដែនអន្តរជាតិម៉ុកបាយ-បាវិត និងបានប្រគល់ជូនអាជ្ញាធរកម្ពុជា មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនិតិសម្បទា ខេត្តស្វាយរៀង ដើម្បីសម្របសម្រួលបន្ត។ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាប្រុងប្រយ័ត្នខ្ពស់ ពិចារណាឲ្យបានល្អិតល្អន់ ដើម្បីកុំចាញ់បោកមេខ្យល់ឃោសនា ដែលងាយរងគ្រោះ ដោយគេអាចនាំយកទៅជួញដូរ។

# ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

## អំពាវនាវពលរដ្ឋបញ្ឈប់ធ្វើចំណាកស្រុកឆ្លងដែនដោយប្រថុយប្រថាន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១៩:២៥ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ត្រូវបញ្ឈប់សកម្មភាពធ្វើចំណាកស្រុកឆ្លងដែនទៅប្រទេសជិតខាងដោយប្រថុយប្រថាននិងខុសច្បាប់ ដែលអាចប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេលវេលា ក្នុងវិបត្តិរាតត្បាតនៃជំងឺកូវីដ-១៩ ដែលកំពុងឃាយឃីនៅគ្រប់ប្រទេស ។ លោកជំទាវរដ្ឋលេខាធិការ ជូ ប៊ុនអេង បានអំពាវនាវបែបនេះ ក្នុងឱកាសដែលលោកជំទាវ និងក្រុមការងារចុះជួបសំណេះសំណាល និងនាំយកអំណោយទៅជូនពលករិនីជាង១០០នាក់ ដែលត្រឡប់ពីប្រទេសថៃ ក្នុងវិបត្តិរាតត្បាតនៃជំងឺកូវីដ-១៩ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ នៅភូមិចម្ការត្រដោក ឃុំឫស្សីក្រោកស្រុកមង្គលបុរី ។ នៅក្នុងឱកាសនោះ លោកជំទាវរដ្ឋលេខាធិការ បានផ្ដាំផ្ញើដល់បងប្អូនទាំងអស់ត្រូវរកការងារធ្វើក្នុងស្រុក និងបង្កបង្កើនផលដាំដំណាំកសិកម្មសម្រាប់តម្រូវការទីផ្សារក្នុងស្រុក ដើម្បីផ្គត់ផ្គង់ជីវិភាពគ្រួសារ ជាការកាត់បន្ថយការលំបាកក្នុងពេលមានវិបត្តិរាតត្បាតកូវីដ-១៩ នៅពេលរាជរដ្ឋាភិបាលកម្ពុជាទប់ស្កាត់បន្លែផ្លែឈើពីប្រទេសជិតខាង ដែលនេះជាការលើកកម្ពស់ជីវិភាពគ្រួសារ ។

លោក រ័ត្ន ដាស៊ីណង់ អភិបាលស្រុកមង្គលបុរី បានឱ្យដឹងថា ពលការិនីដែលត្រឡប់ពីប្រទេសថៃក្នុងពេលមានវិបត្តិរាតត្បាតជំងឺកូវីដ-១៩ ចំនួន១០០នាក់ នៅក្នុងស្រុកមង្គលបុរីនេះ បានទទួលអំណោយពីលោកជំទាវ ជូ ប៊ុនអេង ដើម្បីសម្រាលការលំបាកបានមួយគ្រាផងដែរ ។

ពលករខ្មែរចំណាកស្រុកចំនួន២០នាក់ ត្រូវយោធាថៃឃាត់ខ្លួនពលករខ្មែរចំណាកស្រុកចំនួន២០នាក់ទៀត បានត្រូវកម្លាំងយោធាថៃឃាត់ខ្លួន កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ នៅក្នុងស្រុកតាប្រយ៉ា ខេត្តស្រះកែវ ។ មន្ត្រីយោធាដែលឈរជើងតាមបន្ទាត់ព្រំដែនបានប្រាប់ថា ពលករខ្មែរចំណាកស្រុកដែលត្រូវទាហានថៃឃាត់ខ្លួនចំនួន ២០នាក់នេះ មានប្រុស១៤នាក់ ស្រី៦នាក់ ។ ពួកគាត់បានឆ្លងដែនខុសច្បាប់ក្នុងភូមិសាស្ត្រស្រុកថ្មពួក ចូលទៅក្នុងទឹកដីថៃ ដើម្បីទៅរកការងារធ្វើនៅក្រុងបាងកក ហើយនៅពេលឆ្លងដែនចូលដល់កណ្ដាលព្រៃទឹកដីថៃ ក៏ត្រូវកម្លាំងយោធាថៃឃាត់ខ្លួន ។ មន្ត្រីដដែលឲ្យដឹងទៀតថា ពលករខ្មែរដែលត្រូវបានយោធាថៃឃាត់ខ្លួនតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃនោះ គ្រោងបញ្ជូនមកវិញតាមច្រកព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅ ដែលមានក្រុមគ្រូពេទ្យចត្តាឡីស័កធ្វើការត្រួតពិនិត្យ រួចហើយបញ្ជូនទៅតាមមូលដ្ឋានរបស់ខ្លួនវិញ ។

គួររំឭកថា ស្ទើរតែរៀងរាល់ថ្ងៃដែលកម្លាំងយោធាថៃឃាត់ខ្លួនពលករខ្មែរតាមបន្ទាត់ព្រំដែនក្នុងទឹកដីថៃ ហើយដឹកបញ្ជូនមកវិញតាមច្រកព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅ ។ ពលករខ្មែរភាគច្រើន ឆ្លងដែនដោយខុសច្បាប់ ទៅរកការងារធ្វើនៅទីក្រុងបាងកក ដែលជាការលួចឆ្លងដែនក្រោយពីជំងឺកូវីដ-១៩ កំពុងត្រូវបានរឹតបន្តឹងទាំងនៅថៃនិងនៅកម្ពុជា ។

អភិបាលខេត្ត ឯកឧត្តម អ៊ុំ រាត្រី តែងតែដាក់វិធានការដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវមានវិធានការទប់ស្កាត់ឱ្យបាននូវពលករចំណាកស្រុកដោយខុសច្បាប់ ដើម្បីការពារសុវត្ថិភាពពួកគាត់ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅពេលដែលប្រទេសថៃកំពុងទប់ស្កាត់ដូចគ្នា ។ ជាមួយនេះ ត្រូវស្រាវជ្រាវរកមុខសញ្ញាមេខ្យល់ដែលឃុបឃិតគ្នានាំពលករខុសច្បាប់ចេញ គឺត្រូវចាត់វិធានការតាមច្បាប់ ។ ទោះបីជាបែបណា ពលករទាំងនេះនៅតែធ្លាយចេញរាល់ថ្ងៃ ៕

## ផ្សព្វផ្សាយច្បាប់ និងវិធីសាស្ត្រស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ច្បាប់ការទប់ស្កាត់អំពើជួញដូរមនុស្ស

http://ppd-news.net/ ថ្ងៃចេញផ្សាយ: August 14, 2020

ខេត្តក្រចេះ ៖ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តក្រចេះបានបើកវគ្គផ្សព្វផ្សាយច្បាប់មួយចំនួនស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ការទប់ស្កាត់ អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទរួមនិងច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ កិច្ចការពារជនរងគ្រោះ និងអន្តរាគមន៍ជួយជនរងគ្រោះស្ត្រីនិងកុមារដោយការបំពានផ្លូវភេទ។ ពិធីរៀបចំឡើងដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តក្រចេះនៅវត្ត (កាបី) ស្ថិតនៅភូមិ ឃុំគ្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ នាព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រោមវត្តមានលោកជំទាវ ខាំ សុភាព អភិបាលរងខេត្តក្រចេះ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត និងមានការអញ្ជើញចូលរួមពីលោក លោក ស្រីជាអភិបាលរងស្រុកស្នួល សមាជិកក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត មន្ត្រីរាជការរដ្ឋបាលស្រុក កងកម្លាំងប្រដាប់អាវុធ លោកមេឃុំ និងប្រជាពលរដ្ឋជាច្រើននាក់ផងដែរ។

ក្នុងអង្គពីធីនេះដែរ លោកស្រី កុយ សំបូរ អភិបាលរងស្រុកស្នួល និងជាសមាជិកគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តក្រចេះ មានប្រសាសន៍ស្វាគមន៍ និងរាយការណ៍ពីវឌ្ឍនភាពនៅក្នុងស្រុកស្នួល ខេត្តក្រចេះ ពិសេសការរីកចំរើនលើវិស័យកិច្ចការនារី ដែលបានអនុវត្តភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន តាមផែនការយុទ្ធសាស្ត្រចតុកោណរបស់ប្រមុខរាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងសូមបងប្អូនប្រជាពលរដ្ឋយកចិត្តទុកដាក់ស្តាប់នូវការផ្សព្វផ្សាយច្បាប់ទាំងនេះ ព្រោះវាមានសារៈសំខាន់ណាស់ចំពោះយើងទាំងអស់គ្នា។

លោកជំទាវ ខាំ សុភាព អភិបាលរងខេត្តក្រចេះបានមានប្រសាសន៍លើកឡើងថា កម្មវិធីផ្សព្វផ្សាយច្បាប់ថ្ងៃនេះមានសារៈសំខាន់ណាស់ចំពោះយើងទាំងអស់គ្នា ហើយនេះជាគោលបំណងដើម្បីកសាងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ គោលដៅឲ្យមានការយល់ដឹងក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា គ្រប់រូបភាព និងកាត់បន្ថយការធ្វើចំណាកស្រុកប្រកបដោយប្រថុយប្រថាន។ លោកជំទាវថា ប្រជាពលរដ្ឋសព្វថ្ងៃនេះធ្វើការចំណាកស្រុកជាច្រើនដោយមិនស្របច្បាប់ តាមរយៈមេខ្យល់ ធ្វើឲ្យបងប្អូនពិបាកក្នុងការឆ្លងដែន និងរកទីកន្លែងធ្វើការ ក៏ដូចជាកន្លែងស្នាក់នៅជាដើម។ ដូច្នេះប្រសិនបើបងប្អូនចង់ទៅធ្វើការនៅក្រៅប្រទេស គឺត្រូវទៅដោយស្របច្បាប់ រកក្រុមហ៊ុនឲ្យបានត្រឹមត្រូវ និងច្បាស់លាស់។ ជាមួយគ្នានោះ លោកជំទាវក៏

បានផ្ដាំផ្ញើដល់ប្រជាពលរដ្ឋត្រូវចេះពិចារណាឲ្យបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយ មុននឹងសម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារនៅក្រៅស្រុក ឬក្រៅប្រទេស ហើយត្រូវមានការផ្ដល់កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានរបស់ខ្លួន។

ម្យ៉ាងវិញទៀតសូមបងប្អូនត្រូវបន្តចូលរួមធ្វើអនាម័យឲ្យបានល្អជាប្រចាំ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលឲ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់នូវវិធានការបង្ការ ការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-១៩ នៅក្នុងមូលដ្ឋានរបស់ខ្លួន។ ត្រូវបន្តចូលរួមរិតបន្តឹងបញ្ហាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈនៅតាម សហគមន៍ ហើយគ្មានល្បែងស៊ីសង បងធំ បងប្អូន និងក្រុមក្មេងទំនើង។ លើសពីនេះ លោកជំទាវអភិបាលរងខេត្ត បានក្រើនរំលឹកដល់អាជ្ញាធរមានសមត្ថកិច្ចបន្តខិតខំលុបបំបាត់បញ្ហាគ្រឿងញៀនឲ្យខានតែបាន និងទប់ស្កាត់នូវបទល្មើសគ្រប់រូបភាព ហើយបន្តគោរពច្បាប់ចរាចរណ៍ឲ្យខ្ជាប់ខ្ជួនគ្រប់ៗគ្នា ដើម្បីឲ្យសមតាមពាក្យស្លោករបស់រាជរដ្ឋាភិបាលយើងថា៖ «ថ្ងៃនេះ ថ្ងៃស្អែកសូមកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍»៕ ដោយ ៖ ស៊ាន ចន្ទ័ដា

## ពលករខ្មែរកាប់សម្លាប់គ្នានៅកន្លែងសិប្បកម្មមួយនៅប្រទេសកូរ៉េ, ទូតខ្មែរសម្ដែងការសោកស្ដាយ និងអំពាវនាវពលករខ្មែរចេះស្រឡាញ់គ្នា គោរពកិត្តិយសជាតិខ្មែរ

http://www.freshnewsasia.com/index.php/ 2020-08-14 11:22am

**(ភ្នំពេញ)៖** ពលករខ្មែរម្នាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងរោងចក្រពេលកំពុងបំពេញការងារ ព្រោះតែពលករខ្មែរម្នាក់ទៀត ដែលធ្វើការជាមួយនោះបានលបសម្លាប់។ ករណីឃាតកម្មជារឿងមួយដ៏អាណោចអាធម និងមានការភ្ញាក់ផ្អើលខ្លាំង ដែលនាំឱ្យស្ថានទូតខ្មែរនៅប្រទេសកូរ៉េខាងត្បូងសោកស្ដាយជាទីបំផុត។ ហេតការណ៍ឃាតកម្មកាប់សម្លាប់គ្នារវាងពលករខ្មែរដូចគ្នានេះ បានកើតឡើងនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ នៅក្នុងរោងចក្រសិប្បកម្មមួយកន្លែងក្នុងទីក្រុងណាំយ៉ាងជូ ខេត្តខ្យង់គីដូ។ ជនរងគ្រោះមានឈ្មោះ ស៊ុ អួញ អាយុ ៣០ឆ្នាំ មានស្រុកកំណើតនៅឃុំអណ្ដូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

យោងតាមមនុស្សដែលស្គាល់គ្នាជាមួយជនរងគ្រោះ បានឱ្យដឹងថា ជនរងគ្រោះបានធ្វើការនៅប្រទេសកូរ៉េនេះពីរអាណត្តិហើយ ហើយនៅសល់ពេលតែប៉ុន្មានខែទៀតប៉ុណ្ណោះ នឹងត្រូវបញ្ចប់អាណត្តិការងាររបស់ខ្លួន។ ជនរងគ្រោះត្រូវបានគេស្គាល់ថា ជាមនុស្សស្លូតបូត ចិត្តល្អ មិនសូវជាមានបញ្ហាជាមួយអ្នកដទៃនោះទេ ហើយប្រឹងប្រែងធ្វើ និងទទួលបានការស្រឡាញ់ចូលចិត្តពីថៅកែផងដែរ រហូតដល់ពេលមកលេងស្រុកម្ដងៗត្រូវថៅកែចេញសំបុត្រឱ្យថែមទៀតផង។ ព័ត៌មានបានឱ្យដឹងថា ជនរងគ្រោះមានភរិយាជាអ្នកទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងផងដែរ ហើយទើបសម្រាលកូនបាន ៨ខែប៉ុណ្ណោះ។ ការឈានដល់ឃាតកម្មកាប់សម្លាប់គ្នា អ្នកដែលដឹងរឿងបានអះអាងថា កើតចេញពីចងគំនុំរបស់ឃាតកមកលើជនរងគ្រោះ ដែលទទួលបានការស្រឡាញ់ចូលចិត្តពីថៅកែច្រើនជាងខ្លួន ហើយធ្លាប់មានការចំអន់គ្នាលើរឿងនេះផងដែរពេលមានកម្មវិធីផឹកស៊ីជុំគ្នា។ ព័ត៌មានក៏បានឱ្យដឹងថា ជនសង្ស័យជាឃាតកក្នុងឃាតកម្មនេះ ត្រូវបានសមត្ថកិច្ចរបស់កូរ៉េខាងត្បូងឃាត់ខ្លួនបានហើយ ហើយបាននិងកំពុងសួរចម្លើយចាត់ចែងកាត់ទោសទៅតាមច្បាប់ផងដែរ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង បានប្រាប់អង្គភាពព័ត៌មាន Fresh News ឱ្យដឹងថា បន្ទាប់ពីទទួលបានព័ត៌មានស្ថានទូតក៏បានចុះទៅតាមដាន និងចាត់ចែងសម្របសម្រួលបញ្ហា ហើយចេញលិខិតអនុញ្ញាតឱ្យមានការបូជាសពជនរងគ្រោះនៅថ្ងៃសុក្រ ទី១៤ ខែសីហា នេះហើយ។ លោកឯកអគ្គរាជទូត បានឱ្យដឹងទៀតថា ធាតុរបស់ជនរងគ្រោះ នឹងត្រូវភរិយានាំត្រឡប់មកកាន់ប្រទេសកម្ពុជានៅថ្ងៃចន្ទ សប្ដាហ៍ក្រោយ។ លោកឯកអគ្គរាជទូត ក៏បានឱ្យដឹងផងដែរថា ដោយសារតែករណីគ្រោះថ្នាក់នេះមិនមែនជាករណីគ្រោះថ្នាក់ការងារដូច្នេះជនរងគ្រោះមិនទទួលបានសំណងអ្វីពីថៅកែនោះទេ។ ប៉ុន្តែដោយសារមនោសញ្ចេតនាក្ដីអាណិតស្រឡាញ់របស់ថៅកែនោះ ថៅកែបានចេញថវិកាសម្រាប់ធ្វើបុណ្យ និងចេញថវិកាថ្លៃធ្វើដំណើររបស់ភរិយាក្នុងការ

យកជាតុត្រឡប់មកស្រុកកំណើតវិញផងដែរ។ លោក ឡុង ឌីម៉ង់ បានឱ្យដឹងថា ករណីឃាតកម្មរបស់ពលករខ្មែរនៅប្រទេសកូរ៉េខាងត្បូងធ្លាប់កើតមានផងដែរនាពេលកន្លងទៅ តែនៅកន្លែងជួបជុំផឹកស៊ីផ្សេងៗ តែមិនធ្លាប់កើតមាននៅកន្លែងធ្វើការបែបនេះឡើយ។ បើតាមលោក ឡុង ឌីម៉ង់ ករណីឃាតកម្មនេះនាំឱ្យមានការចាប់អារម្មណ៍ និងភ្ញាក់ផ្អើលនៅក្នុងសហគមន៍របស់កូរ៉េផងដែរ។ ក្នុងនាមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសកូរ៉េខាងត្បូងនោះ លោក ឡុង ឌីម៉ង់ ក៏បានសម្តែងការសោកស្តាយជាខ្លាំងចំពោះករណីឃាតកម្មនេះ។ លោកបានថ្លែងថា ករណីឃាតកម្មនេះក៏នាំប៉ះពាល់ដល់កិត្តិយសរបស់ពលករខ្មែរ ដែលរាជរដ្ឋាភិបាលកម្ពុជាតែងតែប្រឹងប្រែងរក្សាដើម្បីធានាបាននូវការងារក្នុងប្រទេសកូរ៉េខាងត្បូងជូនពលករខ្មែរនោះ។

លោក ឡុង ឌីម៉ង់ បានថ្លែងបញ្ជាក់ដូច្នេះ «មិនគួរណាខ្មែរ និងខ្មែរគ្នាឯងសម្លាប់គ្នានៅលើទឹកដីគេមួយ ដែលរាជរដ្ឋាភិបាល បានខិតខំធ្វើគោលនយោបាយ ក្នុងការបញ្ជូនពលករមកក្រៅប្រទេសនេះ ដើម្បីមកសិក្សារៀនសូត្រក្រេបជញ្ជក់នូវចំណេះវិជ្ជា និងបទពិសោធន៍បំពាក់បំប៉នជំនាញ ដើម្បីវិលទៅស្រុកវិញប្រទេសយើង មានធនធានមនុស្សមានជំនាញ ហើយគាត់មកកសាងជីវភាពចម្រើនដល់គ្រួសារគាត់ ដល់ខ្លួនគាត់ និងសង្គមជាតិផង។ ការដែលគាត់មកធ្វើបែបនេះ មិនត្រឹមតែបំផ្លាញនូវជីវិតរបស់គេមួយ គាត់បំផ្លាញអនាគតរបស់គាត់ខ្លួនឯងដែរ ហើយគាត់ចូលរួមបំផ្លាញនូវកេត្យានុភាពជាតិ ជាតិសាសន៍យើង ដែលកន្លងមកយើងតែងផ្សព្វផ្សាយអប់រំឱ្យមានការសាមគ្គីគ្នា ចេះជួយគ្នា ចេះស្រឡាញ់គ្នា ចេះការពារគ្នា ប៉ុន្តែនេះបែរជាសម្លាប់គ្នា»។ លោកឯកអគ្គរាជទូតក៏បានអំពាវនាវដល់ពលករខ្មែរនៅកូរ៉េខាងត្បូងផងដែរ កុំឱ្យមានការគុំកួនគ្នារហូតឈានទៅការកាប់សម្លាប់គ្នាបែបនេះ។ បើសិនជាតូចចិត្តរឿងថៅកែស្រឡាញ់អ្នកនេះជាងខ្លួនដូចករណីខាងលើ គឺត្រូវប្រឹងប្រែងពង្រឹងសមត្ថភាព ប្រឹងប្រែងធ្វើការ និងកសាងជីវភាពឱ្យកាន់តែប្រសើរ ដោយមិនគួរជ្រើសយកវិធីកាប់សម្លាប់គ្នាបំផ្លាញជីវិតគេ បំផ្លាញអនាគតខ្លួនឯង និងបំផ្លាញកិត្តិយសរបស់ជាតិខ្មែរនោះទេ។

លោក ឌីម៉ង់ បានអំពាវនាវដូច្នេះ **«សូមបងប្អូនទាំងអស់មេត្តាកុំយកតម្រាប់តាម។ ផ្ទុយទៅវិញឃើញករណីនេះកើតហើយ ត្រូវតែបន្ថែមនូវទឹកចិត្តស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាជាតិសាសន៍ខ្មែរដូចគ្នាទៅវិញទៅមក និងការពារគ្នាទៅវិញទៅមកឱ្យរឹតតែរឹងមាំទៅមុខទៀត។ សូមឱ្យខិតខំ បើមានការឈឺចាប់ ការមិនសប្បាយចិត្តនៅកន្លែងធ្វើការ ត្រូវខិតខំយកការតូចចិត្តតូចថ្លើមហ្នឹងឱ្យទៅជាការខិតខំប្រឹងប្រែង ធ្វើខ្លួនឱ្យទៅជាមនុស្សល្អ កសាងសមត្ថភាពខ្លួនឯងឱ្យកាន់តែល្អ ពង្រឹងជីវភាព អភិវឌ្ឍន៍ជីវភាពខ្លួនឯងឱ្យកាន់តែល្អ ឱ្យឈ្នះអ្នកដែលខ្លួនបានច្រណែនហ្នឹងទៅ។ នេះជាភាពជោគជ័យខ្លួន មិនធ្វើឱ្យខូចកេត្យានុភាពជាតិ បំផ្លាញជីវិតគេ និងបំផ្លាញខ្លួនឯង»។**

## ចម្លែក! ថៃចាប់ថៃ លួចឆ្លងចេញពីកម្ពុជា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១២:០១ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ជនជាតិថៃចំនួន៦នាក់ត្រូវបានសមត្ថកិច្ចចម្រុះថៃដូចគ្នាចាប់ខ្លួនចោទថា ឆ្លងដែនពីកម្ពុជាចូលទឹកដីថៃដោយខុសច្បាប់ កាលពីរសៀលថ្ងៃទី១២ សីហា ២០២០ នៅចំណុចភូមិណងយ៉ាកែវ ឃុំគោកធ្យូង ស្រុកគោកធ្យូង ខេត្តស្រះកែវ ឈមទឹកដីកម្ពុជាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ ជនជាតិថៃទាំង៦នាក់ (ស្រី២) ពួកគេជាក្រុមអ៊ែតមីន ផ្នែករ៉េបសាយអនឡាញនៅក្រុងប៉ោយប៉ែត ។ តាមប្រភពព័ត៌មានថា ជនជាតិថៃទាំង៦នាក់ខាងលើចំណាយប្រាក់ម្នាក់ៗ៤០០០បាត ឲ្យអ្នកនាំផ្លូវចេញពីក្រុងប៉ោយប៉ែតទៅច្រករបៀង។ គួរបញ្ជាក់ថាប៉ុន្មានខែចុងក្រោយ ពេលក្នុងសម័យកូវីដ១៩មានជនជាតិថៃ-ចិនបានឆ្លងព្រំដែនចេញពីកម្ពុជាតាមច្រករបៀងមួយចំនួន តាមបន្ទាត់ព្រំដែនពីខេត្តបន្ទាយមានជ័យចូលទៅខេត្តស្រះកែវថៃ ហើយក៏ត្រូវសមត្ថកិច្ចថៃ

ចាប់បានជាបន្តបន្ទាប់ដែលប្រកពថាអ្នកដឹក ឬជូនជនបរទេសឆ្លងដែនខុសច្បាប់នេះសង្ស័យជាក្រុមអ្នកមានខ្សែ ទើបអាចកើតមានយ៉ាងរលូនបែបនេះ។ (កែសម្រួលដោយ ៖ ធីតា)

## ប្រជាពលរដ្ឋខ្មែរចំនួន ១៤នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 13-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១៤នាក់ ស្រី ០៧នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៨នាក់

https://www.facebook.com/GDIOfficial 13-08-2020

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៨នាក់ ស្រី ៣៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០២នាក់ ស្រី ០២នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព។

## មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលពលរដ្ឋខ្មែរ ១១នាក់ ពីមន្ទីរសង្គមកិច្ចក្រុងហូជីមិញ ប្រទេសវៀតណាម

https://www.facebook.com/GDIOfficial 13-08-2020

នៅថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត បានពិនិត្យឃើញ តំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលពលរដ្ឋខ្មែរ ១១នាក់ ពីមន្ទីរសង្គមកិច្ចក្រុងហូជីមិញ ប្រទេសវៀតណាម ដែលបានទៅប្រកបរបររកស៊ី មិនស្របច្បាប់នៅខាងវៀតណាម។ តំណាងមន្ទីរសង្គមកិច្ចខេត្តស្នើសុំស្ថាប័នចត្តាឡីស័ក នាំពលរដ្ឋខាងលើទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសាលារៀនបាវិត ខេត្តស្វាយរៀង។

# ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០
# កម្លាំងនគរបាលស្រុកក្រឡាញ់ ឃាត់មេខ្យល់ម្នាក់ ពាក់ព័ន្ធករណីនាំពលករទៅធ្វើការនៅប្រទេសថៃ

http://cambodiapolice.com/policekh/ 10:13 pm 23 សីហា 2020

**សៀមរាប៖** កម្លាំងនគរបាលស្រុកក្រឡាញ់ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ឃាត់មេខ្យល់ម្នាក់ ពាក់ព័ន្ធករណីនាំពលករទៅធ្វើការនៅប្រទេសថៃ។ ប្រតិបត្តិការខាងធ្វើឡើងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង២០និង៣០នាទី។ នគរបាលខេត្តសៀមរាប បានឲ្យដឹងថាមានរថយន្តតាក់ស៊ីមួយគ្រឿងម៉ាកកាម៉ារីបាំងឡែនពាក់ស្លាកលេខភ្នំពេញ 2M-2662 បានមកដឹកពលករនៅភូមិសង្កែ ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប ហើយបានជួបនិងនគរបាលប៉ុស្តិ៍ដើរល្បាត ក៏បាននាំយកមកអធិការដ្ឋាននគរបាលស្រុកក្រឡាញ់។ តាមការសាកសួរពលករទាំង ០៩នាក់បានឆ្លើយថា ពួកគេទៅធ្វើពលករនៅថៃ ហើយហៅតាក់ស៊ីខាងលើមកយកដោយគេយកឈ្នួលក្នុងមួយនាក់ 30000រៀលនិងប្រាក់សម្រាប់នាំឆ្លងដែនក្នុងមួយនាក់ ៣៣០០បាត ហើយទើបតែនាំគ្នាឡើងរថយន្តតាក់ស៊ីត្រូវប៉ូលិសចាប់បាន។

ផ្អែកតាមការសាកសួរចម្លើយឈ្មោះ ញ៉េប ថា ភេទប្រុស អាយុ ៥២ឆ្នាំ រស់នៅភូមិដូងឃុំ បឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ជាអ្នករត់តាក់ស៊ីនិងជាមេខ្យល់ បានឆ្លើយសារភាពថាខ្លួនពិតជាប្រមូលពលករពីស្រុកក្រឡាញ់ដឹកទៅច្រកខ្សែម ដោយយកឈ្នួលតាក់ស៊ីម្នាក់ ៣០០០០រៀល ហើយពលករទាំងអស់ ខ្លួនយកទៅប្រគល់ឲ្យមេខ្យល់បន្ត មេខ្យល់ឱ្យប្រាក់ក្នុងម្នាក់ ២០០បាតថែមទៀត។ ជនសង្ស័យឈ្មោះ ញ៉េប ថា បានឃាត់ខ្លួនតាមបញ្ជាឯកឧត្តម កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាបនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោ២១៖០០នាទី។ ចំណែកពលករទាំង ៩នាក់ ត្រូវបានសមត្ថកិច្ចយកមកអប់រំ មុនអនុញ្ញាតត្រឡប់ទៅលំនៅដ្ឋានវិញ ៕

## មិនដល់2ខែផង ពលករខ្មែរបញ្ជូនពីថៃជាង១ម៉ឺននាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ២០:៤០ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ រយៈពេលមិនដល់២ខែផង ពលករខ្មែរជាង១ម៉ឺននាក់ បានត្រូវអាជ្ញាធរថៃបញ្ជូនឲ្យអាជ្ញាធរកម្ពុជាតាមច្រកកិច្ចព្រមព្រៀង(អូរបីជាន់) ច្រកអន្តរជាតិប៉ោយប៉ែត និងច្រកតំបន់ ក្នុងខេត្តបន្ទាយមានជ័យ ។ នេះបើតាមក្រុមមន្ត្រីឲ្យដឹង ។ ពលករដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជា ចាប់ពីដើមខែកក្កដាដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ មានចំនួន១៥.០៤៤នាក់ ក្នុងនោះស្រី៦.១៥៤នាក់ និងកុមារ១.៥២៤នាក់ ។

លោកវរសេនីយ៍ទោ ជា លាងហួរ នាយរងការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានប្រាប់តាមទូរស័ព្ទថា ពលករទាំងនេះភាគច្រើនបញ្ជូនពីថៃតាមច្រកកិច្ចព្រមព្រៀងរវាងខេត្តបន្ទាយមានជ័យ-កម្ពុជា និងខេត្តស្រះកែវ-ថៃ(ច្រករបៀងអូរបីជាន់) និងមួយចំនួនតូចបញ្ជូនពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកតំបន់ម៉ាឡៃ ។ ដោយឡែក បើគិតតែក្នុងរយៈពេល៥ថ្ងៃនៃការឈប់សម្រាកក្នុងប្រទេស ចាប់ពីថ្ងៃ១៧ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ ពលករបញ្ជូនពីថៃមានចំនួន១.០៤៦នាក់ ក្នុងនោះស្ត្រី៤១២នាក់ និងកុមារ៩៨នាក់ ។

បើទោះជាប៉ុន្មានខែចុងក្រោយនេះ ដោយសារការកើតមានជំងឺកូវីដ-១៩ ហើយប្រទេសថៃបានបិទព្រំដែនដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគនេះ និងបានដាក់ប្រទេសក្នុងគ្រាអាសន្នក្តី ក៏ពលករខ្មែរនៅតែបន្តលួចឆ្លងដែនចូលទៅដីថៃ ហើយត្រូវអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកវិញស្ទើររាល់ថ្ងៃ ដោយដឹកតាមរថយន្តទ្រុងត្រឡប់មកប្រទេសកំណើតប្រៀបដូចសត្វជាតុ ៕

## ពលករខ្មែរឆ្លងដែនជាច្រើននាក់ ត្រូវទាហានថៃចាប់ឲ្យក្រាបលុតជង្គង់សំពះដល់ដី ឃើញហើយស្លុតចិត្ត! ដោយឡែកមេខ្យល់រត់ចូលព្រៃបាត់ស្រមោល!

https://www.cen.com.kh/ August 22, 2020

មានរឿងដ៏ភ្ញាក់ផ្អើល និងគួរឲ្យស្រណោះទៀតហើយ បន្ទាប់ពីបានដឹងថាពលករខ្មែរចំនួន ១១ នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ឃាត់ខ្លួន ដោយឲ្យលុតជង្គង់ក្រាបលើដីដូចអ្នកទោសអ៊ីចឹង។ យោងតាមកាសែតភាសាថៃ 77kaoded បានចុះផ្សាយឲ្យដឹងថា កងកម្លាំងប៉ូលីសថៃ និងមន្ត្រីត្រួតពិនិត្យប្រចាំតំបន់ នៅព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ បានចុះបង្ក្រាបសកម្មភាពឆ្លងដែនខុសច្បាប់ពីប្រទេសជិតខាង ពិសេសគឺពលករចំណាកស្រុកមកពីកម្ពុជា ដែលបានលួចចូលទីក្រុងដោយខុសច្បាប់ ក្នុងអំឡុងពេលនៃការរាតត្បាតវីរុសកូវីដ១៩ ស្ថិតតាមបណ្តោយផ្លូវលេខ ៣១៩៧ ក្នុងស្រុកវ៉ាតថាណា ណាកន ខេត្តស្រះកែវ។ កាសែតខាងលើនេះបានបន្តឲ្យដឹងថា នៅវេលាម៉ោង ៦ និង ២០ នាទីព្រឹក កម្លាំងសមត្ថកិច្ចថៃ បានធ្វើការត្រួតពិនិត្យផ្តោតទៅលើរថយន្តឆ្លងកាត់តាមបណ្តោយផ្លូវ ៣១៩៧ និងបានធ្វើការឃាត់រថយន្ត២គ្រឿង ។ ប៉ុន្តែ ភ្លាមៗនោះ អ្នកបើកបរ និងកម្មករមួយចំនួន បានរត់គេចខ្លួនចូលព្រៃតែម្តង។ ដោយឡែកមេខ្យល់រត់ចូលព្រៃបាត់ស្រមោល។

ទោះយ៉ាងណា ពលករខ្មែរចំនួន ១១ នាក់ (ប្រុស ១០ នាក់ និងស្រី១នាក់) ត្រូវបានចាប់ខ្លួន។ ចំណែករថយន្ត Nissan ពណ៌ស១គ្រឿង ពាក់ផ្លាកលេខ 1TW-4541 Bangkok និងរថយន្ត Toyota ១គ្រឿងទៀត ពាក់ផ្លាកលេខ 2T-1972 Bangkok ក៏ត្រូវបានសមត្ថកិច្ចថៃ នាំយកទៅប៉ុស្តិ៍ប៉ូលិសវ៉ាតថាណា ណាកន ដើម្បីធ្វើការស៊ើបអង្កេត និងចាត់ការទៅតាមផ្លូវច្បាប់៕ **ដោយៈ លឹម ហុង**

## ស្ត្រីខ្មែរភេទទី៣ ម្នាក់ជាមេខ្យល់ជួញដូរសេវាផ្លូវភេទ និងអ្នកជារៀបចំកម្មវិធីជប់លៀងផ្លូវភេទដ៏សកម្មមួយនៅក្នុងប្រទេសថៃ ត្រូវប៉ូលិសឃាត់ខ្លួន

http://nokorwatnews.com/ 15-08-2020

អន្តរជាតិៈ ប៉ូលិសថៃ នៅខេត្តស្រះកែវ ដែលជាតំបន់ព្រំប្រទល់ថៃ–កម្ពុជា បានស្រាវជ្រាវរហូតឃាត់ខ្លួនស្ត្រីខ្មែរភេទទី៣ ម្នាក់ដែលជាមេខ្យល់នាំក្មេងស្រីអាយុក្រោម១៨ឆ្នាំ ចំនួន៣នាក់ទៅរួមភេទជាមួយភ្ញៀវ និងជាអ្នករៀបចំកម្មពិធីជប់លៀងផ្លូវភេទ (ជាកម្មវិធីដែលមានសេវាផឹកស៊ីកំសាន្ត និងផ្តល់សេវារួមភេទជាក្រុមដោយសេរីក្នុងកញ្ចប់តែមួយ) ដ៏សកម្មផងដែរ ។នេះបើតាមការចេញផ្សាយរបស់ទីភ្នាក់ងារកាសែតបាងកកប៉ុស្តិ៍ ។ ទីភ្នាក់ងារកាសែតបាងកកប៉ុស្តិ៍ បានរាយការណ៍ថា ប៉ូលិសថៃ បានឃាត់ខ្លួនជនសង្ស័យខាងលើ កាលពីរំលងអធ្រាត្រឈានចូលថ្ងៃសុក្រទី១៤ ខែសីហាម្សិលមុិញនេះនៅក្នុងរមណីយដ្ឋាន Le Min ក្នុងខេត្តស្រះកែវ នៃប្រទេសថៃ។

ជនសង្ស័យរូបនេះ ជាស្ត្រីខ្មែរ ចរិតប្រុស មានអាយុ ២៩ឆ្នាំ និងបានប្រើឈ្មោះគណនីបណ្តាញសង្គមថា Wan Jo សម្រាប់ទាក់ទងភ្ញៀវតាមរយៈបណ្តាញសង្គម Twitter ហើយកន្លងមកទីកន្លែងដែលមេខ្យល់រូបនេះមានបណ្តាញច្រើននិងធ្លាប់រកស៊ីបាននៅទីតាំងដូចជាៈ ក្រុងបាងកក ខេត្តចាន់បូរីនិងខេត្តស្រះកែវនេះផ្ទាល់តែម្តង។

ដោយឡែកបើតាមប៉ូលិសថៃវិញ បានបញ្ជាក់ថា ក្មេងស្រីរងគ្រោះទាំង៣នាក់ ក្នុងករណីនេះសុទ្ធតែជនជាតិថៃ ហើយដើម្បីបង្ក្រាបករណីនេះ គឺប៉ូលិសបានប្រើប្រាស់ជនបង្កប់ម្នាក់ឲ្យមកស្វែងរកកញ្ចប់សេវាផ្លូវភេទ ពីមេខ្យល់ ហើយក្រោយមកជនបង្កប់រូបនោះបានលួចរាយការណ៍ជូនអាជ្ញាធរដើម្បីធ្វើការបង្ក្រាបតែម្តង។ ក្រោយឃាត់ខ្លួនជនពាក់ព័ន្ធក្នុងករណីនេះ ត្រូវបានប៉ូលិសថៃឃាត់ខ្លួនទាំងអស់ និងត្រូវប្រឈមនឹងការទទួលទោសតាមផ្លូវច្បាប់ជាធរមានផងដែរ៕**ដោយៈស** តារា

## ភាគីថៃចាប់បញ្ជូនពលរដ្ឋខ្មែរចំនួន ១១នាក់ មកឲ្យប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខេត្តកោះកុង ពីបទឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.facebook.com/GDIOfficial 15-08-2020

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ នៅវេលាម៉ោង ១៦និង០០នាទី ភាគីថៃចាប់បញ្ជូនពលរដ្ឋខ្មែរចំនួន ១១នាក់ មកឲ្យប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខេត្តកោះកុង ពីបទឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ១១នាក់ មាន ១-ឈ្មោះ ថន ហៃ ភេទ ប្រុស អាយុ ៣៦ឆ្នាំ, ២-ឈ្មោះ ងិន រាំ ភេទ ប្រុស អាយុ ៣៥ឆ្នាំ, ៣-ឈ្មោះ ម៉េង អូន ភេទ ប្រុស អាយុ ៤០ឆ្នាំ មានទីលំនៅភូមិរាប ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង, ៤-ឈ្មោះ បុណ ថន ភេទប្រុស អាយុ ៥០ឆ្នាំ, ៥-ឈ្មោះ សាប ដា ភេទប្រុស អាយុ ៥៤ឆ្នាំ, ៦-ឈ្មោះ មិញ សេងលី ភេទប្រុស អាយុ ៣៨ឆ្នាំ, ៧-ឈ្មោះ នាង នេត ភេទប្រុស អាយុ ៣៦ឆ្នាំ, មានទីលំនៅភូមិបុស្សជុគ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង, ៨-ឈ្មោះ សង វណ្ណា ភេទប្រុស អាយុ ២៥ឆ្នាំ, ៩-ឈ្មោះ សឿ ដា ភេទប្រុស អាយុ ២២ឆ្នាំ, ១០-ឈ្មោះ នាង អូន ភេទប្រុស អាយុ ៣៥ឆ្នាំ មានទីលំនៅភូមិព្រៃក្រឡាញ់ ឃុំព្រៃស្រលិត ស្រុក ពសរាំង ខេត្តព្រៃវែង និង១១-ឈ្មោះ យូវ ខាន់ ភេទប្រុស អាយុ ២២ឆ្នាំ មានទីលំនៅភូមិតាំងស្វាយ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសាកសួរអប់រំណែនាំ រួចប្រគល់ឲ្យមន្ត្រីចត្តាឡីស័កប្រចាំការមាត់ច្រក ដើម្បីអនុវត្តន៍នីតិវិធី នូវវិធានការរបស់ក្រសួងសុខាភិបាល៕

## ប្រជាពលរដ្ឋខ្មែរចំនួន ០៣នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 15-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ០៣នាក់ ស្រី ០១នាក់ និងកុមារ ០០នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៦នាក់

https://www.facebook.com/GDIOfficial 15-08-2020

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៦នាក់ ស្រី ១១នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០០នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៥០នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀង ស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 14-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥០នាក់ ស្រី ២៨នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦០នាក់

https://www.facebook.com/GDIOfficial 14-08-2020

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦០នាក់ ស្រី ៣១នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៣៧នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 14-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៧នាក់ ស្រី ០៩នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

# ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០

## អភិបាលខេត្តកំពង់ចាម៖ អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរ ត្រូវរួមគ្នាទប់ស្កាត់

https://dap-news.com/national/ ByKD102 Posted on August 25, 2020

កំពង់ចាម៖ អភិបាលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្ត លោក អ៊ុន ចាន់ដា បានចាត់ទុក អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរ ដែលសមត្ថកិច្ចជំនាញ ត្រូវសហការជាមួយអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ដោយបង្កើនការទប់ស្កាត់ និងបង្ក្រាបកាន់តែម៉ឹងម៉ាត់បំផុត។ លោកអភិបាលខេត្ត បានលើកឡើងដូច្នេះ នាព្រឹកថ្ងៃទី២៥ ខែសីហាឆ្នាំ ២០២០ នៅសណ្ឋាគារភ្នំប្រុសខេត្តកំពង់ចាម ក្នុងសិក្ខាសាលាស្តីអំពី កិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងសំណុំរឿងជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ស្ថិតក្នុងឱកាសនោះ ព្រះរាជអាជ្ញាអមអយ្យការសាលាដំបូង ខេត្តកំពង់ចាមលោក វង្ស ប៊ុនវិសុទ្ធ បានថ្លែងថា បញ្ហាជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនមែនជាបញ្ហាផ្តាច់មុខ របស់ស្ថាប័នអយ្យការ ឬស្ថាប័នអនុវត្តច្បាប់ ស្នងការដ្ឋាន បញ្ជាការដ្ឋានគណៈកម្មា ធិការ ឬរដ្ឋបាលខេត្តតែឯងនោះទេ ប៉ុន្តែវាជាបញ្ហារួមរបស់យើងទាំងអស់គ្នា ហើយវាទាមទារការចូលរួម ឱ្យកាន់តែសកម្មពីគ្រប់ភាគី និងតួអង្គដែលពាក់ព័ន្ធ ក្នុងគោលដៅការពារប្រជាពលរដ្ឋ នៅក្នុងខេត្តរបស់យើង ហើយជាពិសេសជាងនេះទៅទៀត គឺការពារស្ត្រី និងកុមារដែលពួក គេជាជនដែលងាយរងគ្រោះ និងងាយធ្លាក់ក្នុងអន្ទាក់របស់ពួកមេខ្យល់ និងជនល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ លោកព្រះរាជអាជ្ញាបន្តថា ត្បិតបញ្ហានេះ ជាបញ្ហារួម ប៉ុន្តែទ័ពជួរមុខដែលមានមុខងារ សំខាន់ជាងគេក្នុងវិធានការបង្ក្រាបនោះ គឺកងកម្លាំងរបស់យើងទាំងពីរ ស្នងការដ្ឋាន និងបញ្ជាការដ្ឋាន។ «ហេតុនេះហើយទើបក្នុងនាមខ្ញុំជាព្រះរាជអាជ្ញានៃ អយ្យការអមសាលាដំបូងខេត្តកំពង់ចាម សម្រេចក្នុងការផ្តួចផ្តើមរៀបចំ សិក្ខាសាលានេះឡើងដើម្បីបំពាក់បំប៉ន ទាំងបច្ចេកទេសផ្នែកច្បាប់ និងស្មារតី ដល់កងកម្លាំងរបស់យើងដែល ជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមុននេះខ្ញុំហៅពួកគាត់ថា ជា កងទ័ពជួរមុខ» ។ ជាមួយគ្នានោះដែរ លោកព្រះរាជអាជ្ញាបាន គូសបញ្ជាក់ថា សំណុំរឿងនៃករណីជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទភាគច្រើន គឺជនរងគ្រោះ និងជនសង្ស័យជាបុគ្គល ដែលជាប់ខ្សែស្រឡាយគ្នា ឬជាអ្នករស់នៅភូមិ ឃុំជាមួយគ្នា ហើយស្រុកចំនួន ៣ ដែលតែងតែប្រឈមនឹងករណីជួញដូរនេះ គឺស្រុកចំការលើ ស្រុកស្ទឹងត្រង់ និងស្រុកកងមាស។

ក្នុងឱកាសនោះដែរ លោក អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្ត បានថ្លែងប្រកាន់ជំហរដាច់ខាត ដោយសហការជាមួយ អយ្យការអមសាលាដំបូងខេត្តកំពង់ចាម និងក្រុមការងារជំនាញ នៃលេខាធិការដ្ឋានប្រយុទ្ធ ប្រឆាំងការជួញដូរមនុស្ស ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយបង្កើនការទប់ស្កាត់ និងស្វែងរកបទល្មើស និងបង្ក្រាបកាន់តែម៉ឹងម៉ាត់ និងប្រុងប្រយ័ត្នជានិច្ច មិនអនុញ្ញាតឱ្យជនល្មើស អន្តរការី (មេខ្យល់)ទាំងឡាយណា មានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋយើង។ ជាមួយគ្នានេះ លោក អ៊ុន ចាន់ដា បានអំពាវនាវឱ្យកងកម្លាំងប្រដាប់អាវុធ គ្រប់លំដាប់ថ្នាក់ក្នុងខេត្ត ក៏ដូចជាអាជ្ញាធរក្រុង-ស្រុក សូមមេត្តាអង្កេត និងធ្វើការកត់សម្គាល់នូវទំនោរ នៃទម្រង់ក្នុងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក្នុងសម័យបច្ចេកវិទ្យាដែលមេខ្យល់ ជនរង គ្រោះ អាណាព្យាបាលរបស់ជនរងគ្រោះ និងជនល្មើស បានធ្វើការទាក់ទងគ្នាតាមប្រព័ន្ធសង្គម ឬក្នុងទម្រង់ផ្សេងៗទៀត ដែលបញ្ចៀសពីការតាមដាន ឬក្រសែ ភ្នែករបស់អាជ្ញាធរយើង។ លោកអភិបាលខេត្ត ក៏បានបញ្ជាក់ផងដែរថា «

អំពើជួញដូរមនុស្ស និងអំពើរធ្វើអាជីវ កម្មផ្លូវភេទ គឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរ ពោលគឺជនរងគ្រោះមួយចំនួន ដែលធ្លាក់ចូលក្នុងអន្ទាក់នៃឧក្រិដ្ឋកម្មនេះ គឺអាចប្រឈមនឹងការបាត់បង់សតិ ញៀនគ្រឿងញៀន ក្លាយជាស្ត្រីបម្រើសេវាផ្លូវភេទ និងកាន់តែអាក្រក់ជាងនេះទៅទៀត គឺការបាត់បង់អាយុជីវិតតែម្តង» ៕

## កុមារកម្ពុជាកំពុងរងការកេងប្រវញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 24 ខែ សីហា ឆ្នាំ 2020

MC: ក្រុមអ្នកជំនាញ លើកឡើងថា កុមារកម្ពុជាកំពុងត្រូវបានគេកេងប្រវញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលទាមទារនូវវិធានការទប់ស្កាត់ជាបន្ទាន់។ លោកស្រី ហ្សូអេ ដេ ម៉េឡូ(Zoe de Melo) ប្រធានស្តីទីអង្គការដែនដីមនុស្សនៃប្រទេសហូឡង់ ដែលធ្វើការងារលើផ្នែកការពារកុមារនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៧ បានឱ្យដឹងថា នៅកម្ពុជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កើតមានឡើងគួរឱ្យព្រួយបារម្ភ និងទាមទារឱ្យមានការដោះស្រាយជាបន្ទាន់ មុនពេលវាកើតឡើងបន្ថែមទៀត។ លោកស្រី បញ្ជាក់ថា កុមារនៅកម្ពុជា ក៏ដូចជានៅលើសកលលោក បាននិងកំពុងរងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរស័ព្ទដៃវៃឆ្លាតនានា។ លោកស្រី បន្តថា តាមលទ្ធផលវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានបង្ហាញថា កុមារ៨០ភាគរយ បានរាយការណ៍ថា ពួកគេមិនមានអារម្មណ៍សុវត្ថិភាពទាំងស្រុងនៅលើប្រព័ន្ធអនឡាញ ក្នុងនោះ៦០ភាគរយនៃកុមារ បានចែករំលែកថា ពួកគេបានឃើញនូវសម្ភារសិចនិងសកម្មភាពសិចនានា។

លោកជំទាវ ញេប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ មានប្រសាសន៍ថា ស្របពេលដែលបច្ចេកវិទ្យាកាន់តែមានភាពរីកចម្រើន និងការប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតមានការពេញនិយមនោះ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានក្លាយជាក្តីបារម្ភថ្មីមួយទៀត ដែលទាមទារឱ្យភាគីពាក់ព័ន្ធចាំបាច់ធ្វើការរួមគ្នាដើម្បីទប់ស្កាត់ និងការពារការរំលោភបំពាននេះ។ លោកជំទាវ បានសង្កត់ធ្ងន់ថា « បញ្ហានេះ ជាបញ្ហាអន្តរវិស័យ និងប្រទាក់ក្រឡាគ្នាដែលត្រូវរួមគ្នាដោះស្រាយ ដោយមិនអាចមានតែក្រសួងស្ថាប័នណាមួយដោះស្រាយតែម្នាក់ឯងបាននោះទេ»៕

## ក្រសួងអនុញ្ញាតឲ្យសហគ្រាស ស្នើសុំប្រើកម្មករបរទេស លើសពី ១០%

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 24 August 2020 | 09:11 ICT

**ភ្នំពេញៈ** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុញ្ញាតឲ្យសហគ្រាស ដែលស្ថិតក្រោមវិសាលភាពនៃច្បាប់ការងារអាចស្នើសុំប្រើប្រាស់កម្មករនិយោជិតបរទេសជាលក្ខណពិសេសលើសពី ១០ ភាគរយនៃចំនួនកម្មករខ្មែរសរុបក្នុងករណីដែលមិនអាចស្វែងរក ឬមិនមានកម្មករនិយោជិតខ្មែរគ្រប់គ្រាន់។ ប្រកាសចុះហត្ថលេខាដោយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ កាលពីពាក់កណ្តាលខែសីហាឲ្យដឹងថា ម្ចាស់ ឬសហគ្រាសទាំងឡាយដែលស្ថិតនៅក្រោមវិសាលភាពមាត្រា ១ នៃច្បាប់ស្តីការងារ ដែលមានតម្រូវការប្រើប្រាស់កម្លាំងពលកម្មគឺអាចស្នើសុំប្រើប្រាស់កម្មករនិយោជិតបរទេសជាលក្ខណពិសេសលើសពី ១០ ភាគរយនៃចំនួនសរុបកម្មករនិយោជិតខ្មែរ។ ប្រកាសបន្តថា ក្នុងករណីដែលអាចប្រើប្រាស់កម្លាំងកម្មករបរទេសលើសពី ១០ ភាគរយនេះ លុះត្រាតែសហគ្រាសទាំងនោះមិនអាចស្វែងរក ឬមិនមានកម្មករនិយោជិតខ្មែរគ្រប់គ្រាន់ សម្រាប់ចូលបម្រើការងារនៅកន្លែងណាមួយ ឬប្រភេទណាមួយ ឬតាមវេនការងារណាមួយ។ ប្រកាសរបស់ក្រសួងបញ្ជាក់ថាៈ «ដើម្បីប្រើប្រាស់កម្មករនិយោជិតបរទេសនេះ គឺម្ចាស់ ឬនាយកសហគ្រាសត្រូវធ្វើលិខិតសុំការអនុញ្ញាតដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាការងារជា

លាយលក្ខណ៍អក្សររបស់ជនបរទេសនីមួយៗ។ ម្ចាស់ ឬនាយកសហគ្រាស ឬជនទាំងឡាយ ដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវផ្តន្ទាទោសតាមជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃអាទិត្យថា ការសម្រេចរបស់ក្រសួងបែបនេះគឺដើម្បីបំពេញតម្រូវការចង្វាក់ផលិតកម្មពេញ ២៤ ម៉ោង លើ ២៤ ម៉ោងខណៈដែលតម្រូវការកម្លាំងពលកម្មក្នុងវិស័យមួយចំនួនដូចជាការងារវេនយប់ កសិកម្ម និងសំណង់គឺនៅមានការខ្វះខាតនៅឡើយ។ បន្ថែមពីនេះ លោក បញ្ជាក់ថា ករណីដែលក្រសួង អនុញ្ញាតឲ្យសហគ្រាសអាចស្នើប្រើប្រាស់កម្លាំងកម្មករបរទេសលើសពី ១០ ភាគរយនេះគឺលុះត្រាតែការងារទាំងនោះមិនអាចស្វែងរកកម្លាំងកម្មករខ្មែរបាន។ លោកបញ្ជាក់ថា៖ «បើគ្រប់លក្ខខណ្ឌក្នុងប្រការ ១ នៃប្រកាសថ្មីនេះគឺមិនកំណត់កូតាទេ។ បើរកមិនបាន ឬពិបាករក (កម្លាំងពលកម្ម) គឺសហគ្រាសអាចរើសបាន។ យើងត្រូវការចង្វាក់ផលិតកម្ម ២៤ ម៉ោងលើ ២៤ ម៉ោង។ បើមានការងារ តែពិបាករកកម្លាំង គឺយើងត្រូវបើកចំហ»។

យោងតាមប្រកាសស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេសរបស់ក្រសួងការងារកាលពីខែសីហា ឆ្នាំ ២០១៤ បានចែងថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយនៅពេលត្រូវការជ្រើសរើសកម្មករនិយោជិតត្រូវធ្វើការជ្រើសប្រជាពលរដ្ឋខ្មែរជាអាទិភាព។ ការប្រើប្រាស់ហត្ថពលកម្មបរទេសមិនឲ្យលើសពី ១០ ភាគរយនៃចំនួនកម្មករនិយោជិតខ្មែរសរុបទេ ដោយអត្រាកំណត់អតិបរមា ១០ ភាគរយនេះត្រូវកំណត់បែងចែកនិយោជិតបរទេស ដែលធ្វើការក្នុងការិយាល័យចំនួន ៣ ភាគរយ និយោជិត ឬកម្មករឯកទេស ៦ ភាគរយ និងនិយោជិត ឬកម្មករគ្មានឯកទេស ១ ភាគរយ។

លោក មឿន តុលា នាយកប្រតិបត្តិសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សបានសម្តែងភាពភ្ញាក់ផ្អើលដែលក្រសួងការងារសម្រេចឲ្យសហគ្រាសអាចប្រើប្រាស់កម្មករបរទេសលើសពី ១០ ភាគរយ។ លោកបន្តថា ស្ថិតក្នុងដំណាក់កាលនេះ ក្រសួងមិនគួរណាសម្រេចដូច្នេះនោះទេ ព្រោះបច្ចុប្បន្នពលរដ្ឋខ្មែរដែលបានវិលត្រឡប់ពីបរទេសកំពុងតែប្រឈមការគ្មានការងារធ្វើ។ លោកថា៖ «របាយការណ៍របស់ក្រសួងមហាផ្ទៃបញ្ជាក់ហើយថា ពលរដ្ឋដែលត្រឡប់មកពីប្រទេសថៃវិញហ្នឹងមិនតិចជាង ១៣ ម៉ឺននាក់ទេ។ អ៊ីចឹង មនុស្ស ១២ ទៅ ១៣ ម៉ឺននាក់ហ្នឹង តើពួកគាត់មានការងារធ្វើឬទេ? ខណៈដែលរឿងសំខាន់របស់ពួកគាត់ គឺរឿងបំណុល។ ខ្ញុំគិតថា ការឲ្យពលរដ្ឋបរទេសមានសិទ្ធិធ្វើការលើសពី ១០ ភាគរយនេះគឺហាក់បើកឱកាសឲ្យមានការប្រកួតប្រជែងគ្នារវាងកម្មករបរទេស និងកម្មករខ្មែរ»។ ម្យ៉ាងទៀតលោកសង្កេតឃើញថា បើទោះបីជាកម្ពុជាមិនទាន់មានច្បាប់ដែលអនុញ្ញាតឲ្យសហគ្រាសអាចប្រើប្រាស់កម្មករបរទេសលើសពី ១០ ភាគរយក៏កន្លងទៅមានសហគ្រាសមួយចំនួន ជាពិសេសក្នុងវិស័យកសិកម្មបានប្រើប្រាស់កម្លាំងពលកម្មបរទេស ច្រើនលើសលប់រួចទៅហើយ ហើយចំពោះការសម្រេចបើកឱកាសតាមផ្លូវច្បាប់បែបនេះ លោក បារម្ភថាកម្ពុជាអាចនឹងក្លាយទៅជាគោលដៅនៃការជួញដូរមនុស្ស៕

## ថៃបញ្ជូនអ្នកទោសខ្មែរ២នាក់ ត្រឡប់មកវិញតាមច្រកអន្តរជាតិអូរស្មាច់ ក្រោយជាប់ទោសជិត៣ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2020-08-24 07:22pm

**(ឧត្តរមានជ័យ)៖** អ្នកទោសខ្មែរចំនួន២នាក់ទៀត ត្រូវបានអាជ្ញាធរប្រទេសថៃ បញ្ជូនខ្លួនត្រឡប់មកវិញក្រោយជាប់ទោសចំនួន ២ឆ្នាំ ៩ខែក្នុងទឹកដីថៃ ពីបទឆ្លងដែនខុសច្បាប់។ សមត្ថកិច្ចប្រចាំច្រកអន្តរជាតិអូរស្មាច់បានបញ្ជាក់នៅព្រលប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ថា ថា នៅល្ងាចនេះ អាជ្ញាធរប្រទេសថៃ បានបញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរចំនួន២នាក់ តាមច្រកអន្តរជាតិអូរស្មាច់ ស្ថិតក្នុងសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលត្រូវទាហានថៃ ចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើគ្រញូង និងបាននាំទៅឃុំខ្លួន នៅខេត្តនគររាជសីម៉ា

ប្រទេសថៃ បើគិតដល់ថ្ងៃនេះគឺជាប់ទោសរយៈពេល២ឆ្នាំ៩ខែ។ ប្រជាពលរដ្ឋខ្មែរទាំង២នេះរួមមានទី១៖ ឈ្មោះវន់ គួយ ភេទប្រុស អាយុ២២ឆ្នាំ រស់នៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យនិងទី២៖ ឈ្មោះ កា ឡាភេទប្រុសអាយុ៣៧ឆ្នាំ រស់នៅភូមិថ្លាត ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ បន្ទាប់ពីបានស្វែនកម្តៅរកមេរោគកូវីដ-១៩ និងលាងសម្អាតខ្លួនប្រាណដោយទឹកអាល់កុល ពីមន្ត្រីចត្តាឡីស័កប្រចាំច្រកព្រំដែនរួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំឱ្យបញ្ឈប់ សកម្មភាពឆ្លងដែនខុសច្បាប់តទៅទៀត និងបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន៕

## ពលករខ្មែរធ្វើការនៅលើទូកនេសាទថៃម្នាក់រៀបរាប់ពីទុក្ខលំបាកពេលគ្រោះថ្នាក់លិចទូកនៅកណ្ដាលសមុទ្រថៃ

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2020-08-24

ពលករខ្មែរធ្វើការនៅលើទូកនេសាទថៃជាង ១០ឆ្នាំម្នាក់ ដែលផ្ទុះធុងហ្គាសលិចទូកស្ទើរស្លាប់នៅកណ្ដាលសមុទ្រកាលពីថ្ងៃទីចុងខែកក្កដា បានសម្រេចចិត្តវិលត្រឡប់ទៅស្រុកកំណើតវិញ ដោយឈប់ទៅធ្វើការនៅប្រទេសថៃទៀតហើយ។ ពលកររូបនេះបញ្ជាក់ថា មូលហេតុដែលលោកត្រឡប់ទៅផ្ទះវិញ គឺដោយសារស្ថានភាពរបួសធ្ងន់ធ្ងរមិនទាន់ជាសះស្បើយ មិនអាចការងារបាន និងការភ័យតក់ស្លុតក្នុងហេតុការណ៍គ្រោះថ្នាក់ពេលធ្វើការនៅក្រៅប្រទេស។ តើពលករខ្មែររូបនេះជួបគ្រោះថ្នាក់បែបណាបានជាលោកសម្រេចបោះបង់ចោលការងារនៅប្រទេសថៃ? បុរសសម្បុរស្រអែម មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង គឺលោក វ៉ាន់ ឡុន រៀបរាប់ថា លោកបានរួចផុតពីការស្លាប់ គឺជាសំណាងមួយដ៏ធំនៅក្នុងជីវិត ពីព្រោះលោកបានឆ្លងកាត់ស្ថានភាពដ៏អាក្រក់នៅកណ្ដាលទឹកសមុទ្រតែម្នាក់ឯងចំនួន ៤ថ្ងៃ ដោយពុំមានអាហារហូបចុកឡើយ។ លោកឱ្យដឹងថា កាលពីចុងខែកក្កដា លោកជួបគ្រោះថ្នាក់ដោយផ្ទុះធុងហ្គាសដាំបាយ បណ្ដាលឱ្យឆេះទូកលិចនៅកណ្ដាលសមុទ្រតែម្នាក់ឯង នៅក្នុងខេត្តរ៉ាក់យ៉ង (Rayong) ប្រទេសថៃ ដោយពុំមានអ្នកណាម្នាក់បានដឹងឡើយ ព្រោះទូកនេសាទនោះលោកធ្វើដំណើរម្នាក់ឯងដឹកឧបករណ៍បំភ្លឺភ្លើងសម្រាប់នេសាទត្រីយកទៅឱ្យក្រុមការងាររបស់លោក ដែលកំពុងនេសាទនៅកណ្ដាលសមុទ្រប្រទេសថៃ។ លោកបន្ថែមថា នៅមុនពេលទូកលិចប្រមាណ ១០នាទី លោកប្រមូលបានទូរស័ព្ទមួយគ្រឿង និងលិខិតឆ្លងដែនមួយក្បាលច្រកថង់ ដោយចងជាប់នឹងគម្របធុងទឹកកក ទំហំទទឹងជាងកន្លះម៉ែត្រ និងបណ្ដោយប្រហែល ១ម៉ែត្រ សម្រាប់តោងហែល ដើម្បីកុំលង់ទឹកស្លាប់។ លោកបន្តថា នៅពេលនោះលោកបានថតវីដេឃ្លីបប្រមាណ ១០នាទី ទុកនៅក្នុងទូរស័ព្ទរបស់លោក ដើម្បីឱ្យសាច់ញាតិមើលនៅដង្ហើមចុងក្រោយ ដែលលោកជួបគ្រោះថ្នាក់នៅលើទឹកសមុទ្រ។ បុរសវ័យ ២៥ឆ្នាំរូបនេះឱ្យដឹងថា នៅពេលនោះលោកមិនសង្ឃឹមថានឹងមានជីវិតបានត្រឡប់ទៅជួបប្រពន្ធកូននៅស្រុកខ្មែរវិញទេ ពីព្រោះចំងាយប្រមាណ ៥០គីឡូម៉ែត្រនៅជុំវិញលោកពុំមានទូកឬអ្នកនេសាទណាម្នាក់ឡើយ៖ «និយាយទៅឈឺចុកចាប់ពេញខ្លួន ត្រូវទឹកព្រៃក៏វាក្រហាយដូចគេយកម្ទេសមកប្រឡាក់ខ្លួនអីចឹង។គិតថា ខ្លួនឯងដូចសាកសពមួយអណ្ដែតទឹកហើយ ព្រោះយើងឆេះខ្លួនលែងយល់ មានកូនត្រីតូចវាមកចឹកស៊ី ព្រោះយើងឆេះពេញខ្លួន ពេលយប់យើងមើលមិនវាឃើញវាមកកាន់តែ វាស៊ីដំបៅក្រហូងសាច់អស់ហើយ។ ពេលខ្លះយើងដឹងទៅក៏យើងបង្អើលៗវាចេញទៅ ពេលខ្លះអត់ដឹងវាមកស៊ីតាមចិត្តភាគច្រើនជើង ព្រោះជើងយើងនៅក្នុងទឹកហូត»។

នៅក្នុងវីដេអូឃ្លិបដែលលោកបានចែកចាយតាមបណ្ដាញសង្គមហ្វេសប៊ុក (Facebook) បុរសម្នាក់នេះត្រូវភ្លើងឆេះពេលពេញមុខ និងដងខ្លួន ដែលលោកបានរៀបរាប់ទាំងទឹកភ្នែកហៅគេឯងឱ្យទៅជួយសង្គ្រោះជីវិតលោកនៅកណ្ដាលសមុទ្រថៃ។ លោក វ៉ាន់ ឡុន ប្រាប់ថា ទីតាំងដែលទូករបស់លោកលិចនោះចំងាយពីដីគោកក្នុងខេត្តរ៉ាក់យ៉ង (Rayong) ប្រមាណ ២០០គីឡូម៉ែត្រ ដែលលោកផឹកទឹកសមុទ្រចំនួន ៤ថ្ងៃដោយពុំបានហូបអាហារអ្វី

ឡើយ។ លោកថា នៅពេលមានខ្យល់បក់ខ្លាំងម្តងៗ រលកទឹកសមុទ្របានរុញច្រានលោករបូតដៃចេញពីគម្របធុងទឹកកក ដែលលោកតោងហែលទឹក ចំងាយប្រមាណ ៥ម៉ែត្រ ក៏ប៉ុន្តែលោកថា លោកខំប្រឹងហែលទឹកតាមរកគម្របធុងទឹកកកមកវិញ ដើម្បីតោងកុំឱ្យលង់ទឹកស្លាប់៖ «យើងមិនសូវមានកម្លាំងទេ យើងចេះតែប្រឹងអោបខ្លាចវារបូតទៅយើងអត់មានអីតោង បើយើងមានគម្របទូទឹកកកយើងអាចជួយបណ្តែតខ្លួនបានខ្លះ ដល់ពេលមានរលកធំៗមកវាយក្រឡាប់គម្របធុងទឹកកកហ្នឹង ក៏យើងប្រឹងហែលដេញចាប់មកវិញខ្លាចយើងអត់មានអីតោង។ជីវិតខ្ញុំធ្លាប់អស់សង្ឃឹមថាយើងលែងមានជីវិតមកវិញ ដល់ពេលគេរកឃើញខ្ញុំសប្បាយចិត្តណាស់ ថង់ខ្ញុំច្រកទូរស័ព្ទហ្នឹងខ្ញុំគ្រវីទៅគេឃើញក៏គេបើកកាណូតមក។ ពេលខ្លះយើងអស់សង្ឃឹមខ្លាចគេរកមិនឃើញលែងបានជួបមុខប្រពន្ធកូន និងគ្រួសារ តែពេលខ្លះយើងឱ្យកម្លាំងចិត្តខ្លួនយើងនៅមានសង្ឃឹមខ្លះអាចមកជួបគ្រួសារវិញ»។

លោកឱ្យដឹងទៀតថា នៅកន្លែងលោកធ្វើការនោះ មានពលករខ្មែរប្រមាណ ៤០នាក់ ក៏ប៉ុន្តែពួកគេពុំបានដឹងថា លោកលិចទឹកទូកនោះទេ ដោយពួកគេដឹងនៅពេលដែលលោកបាត់ការទាក់ទងចំនួន ២ថ្ងៃ ក៏បាននាំគ្នាបើកកាណូតតាមរកលោក។ ទោះយ៉ាងណា ពលកររូបនេះត្រូវបានអ្នកនេសាទថៃប្រទះឃើញ និងស្រង់លោកឡើងពីទឹកសមុទ្រ បញ្ជូនទៅព្យាបាលរបួសនៅមន្ទីរពេទ្យក្នុងខេត្តរ៉ាក់យ៉ងចំនួន ៣ថ្ងៃ ក៏ចេញពីមន្ទីរពេទ្យ កាលពីដើមខែសីហា។ ពលករមានស្រុកកំណើតខេត្តកំពង់ឆ្នាំងរូបនេះ ថ្លែងថា ក្រោយពេលលោកចេញពីមន្ទីរពេទ្យបាន ២ថ្ងៃ មានមន្ត្រីស្ថានទូតខ្មែរប្រមាណ ៦នាក់បានចុះទៅសួរសុខទុក្ខលោក និងជួយប្រាក់ចំនួន ១ម៉ឺនបាត (១០.០០០) ឬប្រមាណ ៣០០ដុល្លារអាមេរិក។ ចំណែកថៅកែនៅកន្លែងធ្វើការធ្វើរបស់លោកជួយចេញថ្លៃព្យាបាលរបួស និងឱ្យប្រាក់លោកចំនួន ៥ពាន់បាត (៥.០០០) ឬប្រមាណ ១៦៥ដុល្លារ ដើម្បីឱ្យលោកធ្វើសោហ៊ុយត្រឡប់ទៅផ្ទះវិញ។

ប្រពន្ធជនរងគ្រោះ លោកស្រីហឹម គីមហៀង ប្រាប់អាស៊ីសេរីថា លោកស្រីស្លុតចិត្តយ៉ាងខ្លាំងនៅពេលឃើញវីដេអូឃ្លិប ដែលបានបង្ហោះនៅក្នុងហ្វេសប៊ុក ដែលប្តីរបស់លោកស្រីត្រូវភ្លើងឆេះដោយលិចទូកនៅកណ្តាលសមុទ្រថៃនោះ។លោកស្រីបញ្ជាក់ថា ចាប់ពីពេលនេះតទៅ លោកស្រីឈប់ឱ្យប្តីរបស់គាត់ទៅធ្វើការលើទូកនេសាទនៅប្រទេសថៃទៀតហើយ ព្រោះការងារដែលប្តីធ្វើនេះប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត៖ «ខ្ញុំឃើញរូបភាពប្តីខ្ញុំតក់ស្លុត ហើយស្រែកយំ នឹកឃើញអាណិតប្តី ជីវិតប្តីខ្ញុំដូចកើតម្តងទៀតខ្ញុំសប្បាយចិត្តណាស់ មិនមែនអ្វីមកផ្ទឹមបានទេ រឿងលុយមិនសំខាន់ដល់ប្តីទេ។នៅស្រុកខ្មែរមានការងារមានប្រាក់ខែតិចតួចយើងចេះតែធ្វើទៅ ដើម្បីដោះស្រាយជីវភាពបានមួយពេលៗ។ ខ្ញុំសូមផ្តាំផ្ញើបងៗ ទាំងឡាយដែលគាត់ទៅធ្វើការលើទូកនេសាទនៅប្រទេសថៃសូមឱ្យប្រយ័ត្នប្រយែងកុំឱ្យមានគ្រោះថ្នាក់ដូចប្តីខ្ញុំ»។

ពលករខ្មែររូបនេះធ្វើការនៅលើទូកនេសាទថៃជាង ១០ឆ្នាំតាំងពីនៅវ័យកុមារ ដោយ ៦ឆ្នាំមុនលោកធ្វើការនៅប៉ាតានី (Pattani) នៅភាគខាងត្បូងទីក្រុងបាងកក ចំងាយប្រមាណ ១ពាន់ (១.០០០)គីឡូម៉ែត្រ និងធ្វើការនៅខេត្តរ៉ាក់យ៉ង ចំនួន ៥ឆ្នាំ ដោយបានប្រាក់ឈ្នួល ប្រមាណ១៣.០០០ពាន់បាត ឬប្រហែល ៤៣០ដុល្លារអាមេរិកក្នុងមួយខែ។ ប្តីប្រពន្ធមួយគូរនេះនិយាយដូចគ្នាថា ប្រាក់ខែទាំងនេះមិនបានជួយឱ្យជីវភាពគ្រួសាររបស់គាត់ធូរធារឡើយ។ ពលកររូបនេះ បានត្រឡប់ទៅស្រុកកំណើតវិញ កាលពីថ្ងៃទី២០ សីហា ដោយសាររបួសដែលបណ្តាលមកពីភ្លើងឆេះរាងកាយមិនទាន់ជាសះស្បើយនៅឡើយ ហើយលោកមិនអាចធ្វើការងារបាននោះទេ។

មន្ត្រីអង្គការសង់ត្រាស់(Central)ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា កត់សំគាល់ថា ពលករខ្មែរធ្វើការនៅលើទូកនេសាទថៃ ប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតជាងគេ ហើយត្រូវថៅកែបោកប្រាស់កម្លាំងពលកម្មដោយបង្ខំឱ្យធ្វើការច្រើនម៉ោងបានប្រាក់កម្រៃតិចតួចជាដើម។ លោកបន្ថែមថា មានពលកររាប់រយនាក់ ដែលអង្គការរបស់លោក និងរដ្ឋាភិបាលបានជួយសង្គ្រោះក្នុងអំឡុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ រហូតមកដល់ថ្ងៃទី២៤ សីហានេះ ពួកគេនៅតែមិនទាន់ទទួលបានសំណងនៅឡើយ។៖ «ការងារចុះទូកនេះជាប្រភេទការងារគ្រោះថ្នាក់

បើថាគេចពីផ្ទះទៅធ្វើការស្រុកគេសូមជ្រើសរើសការងារ តាមរោងចក្រ ការងារណាដែលមិនប្រឈមគ្រោះថ្នាក់។ ចំពោះការងារដែលគួរប្រយ័ត្នប្រយែងហ្នឹងការងារចុះទូក ការងារសំណង់ ដែលជាប្រភេទការងារខ្វះការការពារ។ អ៊ីចឹងរដ្ឋាភិបាលប្រទេសបញ្ជូនក៏ដោយប្រទេសទទួលក៏ដោយធ្វើយ៉ាងម៉េចធានានូវ ដំណើរភាពមានប្រព័ន្ធការធានាសុវត្ថិភាព»។

កាលពីខែមិថុនាឆ្នាំ២០១៩ មានពលករខ្មែរចំនួន ២នាក់បានលិចទូកស្លាប់ម្តងរួចមកហើយ ក្នុងពេលដែលពួកគេធ្វើការនៅលើទូកនេសាទថៃ នៅខេត្តត្រាត ប្រទេសថៃ។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរប្រមាណ ២លាននាក់ធ្វើការនៅប្រទេសថៃ ក្នុងនោះពលករប្រមាណ ១ម៉ឺននាក់ ធ្វើការនៅលើទូកនេសាទ៕

## សមត្ថកិច្ចថៃបន្តចាប់ពលករខ្មែរជិត៣០នាក់ និងមេខ្យល់ជនជាតិថៃម្នាក់

http://peoplenews.asia/ ថ្ងៃទី 15 ខែ 08 ឆ្នាំ 2020 ម៉ោង 1: 53 PM ដោយ៖ រិទ្ធី

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរចំនួន ២៩នាក់ ហើយបានលបលួចឆ្លងដែនចូលប្រទេសថៃខុសច្បាប់ ត្រូវបានសមត្ថកិច្ចថៃបានធ្វើការចាប់ខ្លួននៅស្រុកតាប្រាយ៉ា ខេត្តស្រះកែវឈម ទឹកដីកម្ពុជា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីយប់ថ្ងៃទី ១៤ សីហា ឆ្នាំ២០២០នេះ។ ពលករទាំងនោះមានស្រី១១នាក់ ប្រុស១៨នាក់ ពួកគេភាគច្រើនមកពីខេត្តកំពង់ចាម នេះបើយោងតាមការចុះផ្សាយរបស់គេហទំព័រ និងកាសែតក្នុងស្រុកថៃមួយ។ ក្នុងចំណោមនោះ មានពលករ ៥នាក់ ត្រូវបានសមត្ថកិច្ចចាប់ពេលកំពុងជិះរថយន្តចេញពីព្រំដែនស្រុកតាប្រាយ៉ា។ លុះដល់៣ម៉ោងក្រោយមក មានពលករ២៤នាក់ ស្រី៩នាក់ ផ្សេងទៀតដើរដោយថ្មើជើង និងទើបឆ្លងដែនពីកម្ពុជា ក្នុងភូមិសាស្ត្រឃុំស្រុកខាងលើ ក៏ត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនបានបន្ថែមទៀត។

យោងតាមការសាកសួរពលករទាំងនោះ ពួកគេបានចំណាយប្រាក់ឲ្យមេខ្យល់ម្នាក់ ៤៥០០ បាត តែគេយកមុនម្នាក់ ២០០០បាតរួចហើយ។ ការឃាត់ខ្លួនពលករខ្មែរនេះ ក្នុងនោះមានសមត្ថកិច្ចថៃ ក៏បានឃាត់រថយន្តពាក់ស្លាកលេខថៃ ម៉ាកតូយ៉ូតា ១គ្រឿង ដែលដឹកជញ្ជូនពលករ ចាប់បាននៅវគ្គទី១ និងស្ត្រីជនជាតិថៃម្នាក់ដែរ ដែលជាប់ចោទថាជាមេខ្យល់ក៏ត្រូវគេឃាត់យកទៅស្ថានីយ៍ប៉ូលីសក្នុងស្រុកកើតហេតុរួមគ្នាដើម្បីបន្តចាត់ការតាមនីតិវិធី។

ពាក់ព័ន្ធនឹងករណីនេះ ជារឿយៗគេតែងសង្កេតឃើញសមត្ថកិច្ចខ្មែរ និងសមត្ថកិច្ចថៃតែងចាប់ខ្លួនបានពលករខ្មែរឆ្លងដែនចូលប្រទេសថៃជាបន្តបន្ទាប់ ប៉ុន្តែដំណឹងចាប់ពលករខ្មែរនេះវាហាក់មិនបានធ្វើឲ្យពលករខ្មែរដទៃទៀតមានការខ្លាចរអានឹងរាងចាលប៉ុន្មានទេ ពោលគឺពួកគេនៅតែបន្តសម្រុកចូលទៅប្រទេសថៃជាដដែល ព្រោះតែតម្រូវការផ្នែកជីវភាព។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៦នាក់

https://www.facebook.com/GDIOfficial 18-08-2020

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៦នាក់ ស្រី ២៦នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១៥នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្ដាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 18-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១៥នាក់ ស្រី ០៤នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១៦នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្ដាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 17-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១៦នាក់ ស្រី ០៨នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៩នាក់

https://www.facebook.com/GDIOfficial 17-08-2020

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។

ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៩នាក់ ស្រី ២១នាក់៕

## ថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 17-08-2020

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកទឹកជុំ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ប្រជាពលរដ្ឋខ្មែរចំនួន ២១នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 16-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២១នាក់ ស្រី ០៦នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់

https://www.facebook.com/GDIOfficial 16-08-2020

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៨៦នាក់ ស្រី ៤២នាក់៕

# ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០

## សមត្ថកិច្ចថៃស្រុកចាប់ទំនិញ និងពលករជាបន្តបន្ទាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២០ ម៉ោង ១៦:០២ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ប៉ុន្មានថ្ងៃចុងក្រោយនេះ សមត្ថកិច្ចនិងមន្ត្រីជំនាញថៃបានធ្វើការចាប់ទំនិញខ្មែរនៅម៉ុំផ្សាររុងក្លឿ ក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ និងពលករខ្មែរជាបន្តបន្ទាប់ចោទថាឆ្លងព្រំដែនពីកម្ពុជា ។ ទំនិញជាច្រើនមុខរួមមានខោអាវកីឡា, កម្រាល, ភួយ កាបូបស្ត្រី និងទំនិញប្រែនៗមួយចំនួនទៀតត្រូវបានភាគីថៃចាប់ម៉ុំ

ផ្សាររុងគ្លឿ ស្រុកអារញ្ញ កាលពីថ្ងៃទី២២ និង២៣ សីហា២០២០ ដោយចោទថាជាទំនិញរំលោភកម្មសិទ្ធបញ្ញា និងលួចនាំចូលតាមច្រករបៀង។

ដោយឡែកកាលពីថ្ងៃទី២៤ សីហា ឆ្នាំ២០២០ ពលករខ្មែរចំនួន៨នាក់(ប្រុស៥នាក់ និងកុមារម្នាក់) ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួននៅក្នុងស្រុកវ៉ាត់ថាណាណាក់ខន ខណៈពួកគេកំពុងជិះរថយន្ត១គ្រឿង ក្រោយឆ្លងព្រំដែនចេញពីកម្ពុជាតាមច្រករបៀង។ បើទោះជាប៉ុន្មានខែចុងក្រោយនេះ ថៃបានបិទព្រំដែននិងដាក់ប្រទេសក្នុងគ្រាអាសន្នព្រោះតែមេរោគកូវីដ១៩ក្តី ប៉ុន្តែច្រករបៀងមួយចំនួនក្នុងខេត្តបន្ទាយមានជ័យនៅតែមានបទល្មើសឆ្លងដែនខុសច្បាប់ទៅដីថៃ ហើយភាគីថៃធ្វើកាបង្ក្រាបនិងចាប់បានជាបន្តបន្ទាប់ដូចករណីខាងលើជាដើម៕ (កែសម្រួលដោយ ៖ ធីតា)

## បុរស៣នាក់ឆ្លងដែនកាប់ឈើក្រញូងសមត្ថកិច្ចថៃចាប់ដាក់ទោសចំនួន២ឆ្នាំ ទើបដោះលែងប្រគល់ឱ្យភាគីកម្ពុជា

http://nokorwatnews.com/ 25-08-2020

ខេត្តឧត្តរមានជ័យ៖ ពលករ៣នាក់ លបលួចឆ្លងដែនដោយខុសច្បាប់ កាប់ឈើក្រញូងត្រូវមត្ថកិច្ចថៃចាប់យកទៅផ្តន្ទាទោសតាមច្បាប់ប្រទេសថៃ រួចផុតទោសត្រូវបានសមត្ថកិច្ចថៃយកមកប្រគល់អោយភាគគីកម្ពុជាវិញនៅវេលាម៉ោង១៦ៈ៣០នាទីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០តាមច្រកទ្វាអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានអោយដឹងថា អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរ៣ នាក់ តាមច្រកអន្តរជាតិជាំ ដែលមានឈ្មោះដូចខាងក្រោម។

ទី១៖ឈ្មោះ កែវ សុគៀន ភេទប្រុសអាយុ ៣៣ ឆ្នាំរស់នៅភូមិបឹងបេង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

ទី២៖ឈ្មោះ ឃឹម ភិន ភេទប្រុសអាយុ ៤៧ ឆ្នាំរស់នៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ទី៣៖ឈ្មោះ កុល ឡា ភេទប្រុសអាយុ ២៥ឆ្នាំរស់នៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។អ្នកទាំងបីចាប់ខ្លួនថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ បទឆ្លងដែនកាប់ឈើគ្រញូង ចូលតាមច្រកត្រពាំងបី ស្រុកត្រពាំងប្រាសាទ ជាប់ពន្ធនាគា នៅស្រុកខាន់ថាឡាក់ខេត្តស៊ីសាកេតប្រទេសថៃ។ ក្រោយសមត្ថកិច្ចច្រកទ្វាអន្តរជាតិជាំ ធ្វើការអប់រំរួចអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន៕

## ទាហានថៃបាញ់យុវជនម្នាក់បណ្តាលឱ្យរបួសធ្ងន់ខណៈចូលកាប់ឈើខុសច្បាប់ក្នុងដីថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 25/08/2020

បាត់ដំបង ៖ ក្រុមទាហានថៃបានបាញ់យុវជនម្នាក់ដែលជាពលរដ្ឋខ្មែរ ឲ្យរងរបួសលើដៃស្តាំម្ខាង ខណៈដែលរូបគេចូលកាប់ឈើក្នុងទឹកដីថៃ។ តាមរបាយការណ៍សមត្ថកិច្ចបានបញ្ជាក់ថា យុវជនរូបនេះ រួមទាំងបក្ខពួកប្រមាណ២៩នាក់ បានលបឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដើម្បីរកកាប់ឈើលក់ឲ្យមេឈ្មួញស្រី ដែលឈរជើងចាំទទួលទិញប្រចាំតំបន់នេះ។ ករណីនេះកើតឡើងនៅវេលាម៉ោង១១ និង៣០នាទី កាលពីយប់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ត្រង់ចំណុចអូរជើមខ្នុរ ( លើទឹកដីថៃ ) ទល់មុខនឹងច្រក៣មតា ត្រង់ចំណុច ភូមិអូរគ្រែង ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង។

តាមប្រភពនៅតំបន់នោះបានឲ្យដឹងថា នៅមុនពេលកើតហេតុ គឺមានប្រជាពលរដ្ឋប្រមាណ២៩នាក់ ដែលជាកូនចៅរកស៊ីកាប់ឈើលក់ទៅឲ្យមេឈ្មួញដ៏ធំប្រចាំតំបន់នេះ ដោយពួកគេបាននាំគ្នាលបឆ្លងដែន ចូលទៅក្នុងទឹកដីថៃ ដើម្បីរកកាប់ឈើដូចសព្វមួយដង។ តាមប្រភពខាងលើបានបន្តថា នៅពេលនោះផងដែរកម្លាំងយោធាថៃប្រចាំខ្សែបន្ទាត់ព្រំដែន ក៏បានធ្វើការបាញ់រះជាច្រើនគ្រាប់មកលើពួកគេ បណ្តាលឲ្យចំដៃស្តាំម្នាក់ឈ្មោះ ចាន់ ឧត្តម ភេទប្រុស អាយុ២០ឆ្នាំ រស់នៅភូមិអូរព្រែង ឃុំតាតោក ស្រុកសំឡូត គឺមុខរបួសមានសភាពរយៈយ៉ាងធ្ងន់ធ្ងរ ហើយក៏បាននាំគ្នារត់គេចរៀងៗខ្លួន ត្រឡប់មកកាន់ទឹកដីខ្មែរវិញ ដោយឡែកជនរងគ្រោះក៏ត្រូវបានក្រុមគ្រួសារ ដឹកបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបងផងដែរ៕

## កជក: កុមារប្រើទូរស័ព្ទ អាចក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 25 August 2020 | 14:49 ICT

**ភ្នំពេញ:** ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) រកឃើញ ថាកុមារកម្ពុជាមួយចំនួនដែលកំពុងប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតអាចក្លាយជាជនងាយរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ មានដូចជាគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរស័ព្ទដៃវៃឆ្លាតនានា។

លោកស្រី ញេប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក.ជ.ក. បានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃអាទិត្យថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ Online child sexual exploitation (OCSE) គឺជាបញ្ហាសកលដែលកើតឡើងក្នុងទម្រង់ផ្សេងៗគ្នា និងបានក្លាយជាក្តីបារម្ភថ្មីមួយទៀតដែលទាមទារឲ្យភាគីពាក់ព័ន្ធទាំងសាធារណជន អាណាព្យាបាលរបស់កុមារ អាជ្ញាធរ និងសង្គមស៊ីវិលជាដើម ចាំបាច់ត្រូវធ្វើការរួមគ្នាដើម្បីទប់ស្កាត់ និង ការពារកុមារពីការរំលោភបំពានតាមប្រព័ន្ធអនឡាញនេះ។ លោកស្រីបន្តថា កុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទបានបន្សល់នូវផលប៉ះពាល់ធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត។ កុមាររងគ្រោះភាគច្រើនមានអារម្មណ៍ពិបាកក្នុងការទុកចិត្តអ្នកដទៃ អស់សង្ឃឹម បាក់ទឹកចិត្ត ឯកា ច្របូកច្របល់ ខកចិត្ត ស្តីបន្ទោសខ្លួនឯង និងធាប់ភ័យខ្លាចជាដើម។ លោកស្រីបញ្ជាក់ថា៖ «អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញគឺជាការព្រួយបារម្ភថ្មីមួយបានកើតឡើងគ្រប់រូបភាព ដែលយើងមិនអាចមើលដឹងព្រោះតែការវិវត្តជឿនលឿននៃបច្ចេកវិទ្យា»។ លោកស្រីថ្លែងថា ក.ជ.ក. មានការព្រួយបារម្ភខ្លាំងចំពោះបញ្ហានេះ ដូច្នេះ ក.ជ.ក កំពុងជំរុញ និងសម្របសម្រួលដល់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា ដើម្បីចូលរួមទាំងអស់គ្នាក្នុងការលើកកម្ពស់ការពារ និងទប់ស្កាត់ ការរំលោភបំពានលើកុមារតាមប្រព័ន្ធអនឡាញ។ លោកស្រី សុភាព ឱ្យដឹងថា កន្លងមកកុមារកម្ពុជាក៏ធ្លាប់ជួបប្រទះចំពោះអំពើហិង្សាលើប្រព័ន្ធអនឡាញនេះដែរក្នុងនោះក្រសួងមហាផ្ទៃមាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាជាសេនាធិការកំពុងបន្តចាត់វិធានការ នានាក្នុងការទប់ស្កាត់បញ្ហានេះ។

សេចក្តីប្រកាសព័ត៌មានរួមស្តីពីកិច្ចពិភាក្សាតុមូលក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ ការពារ និងទប់ស្កាត់ ការរំលោភបំពាន លើកុមារតាមប្រព័ន្ធអនឡាញ» អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ របស់ ក.ជ.ក ចុះផ្សាយកាលពីថ្ងៃទី ១៥ ខែសីហា បង្ហាញថាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញគឺជាទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ ដែលកំពុងកើតមានឡើងលើប្រព័ន្ធអនឡាញដោយពួកគេប្រើគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរស័ព្ទដៃវៃឆ្លាតនានា។ សេចក្តីប្រកាសនេះបន្ថែមថា នៅកម្ពុជា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតកើតមានឡើងគួរឱ្យព្រួយបារម្ភ និងទាមទារឱ្យមានការដោះស្រាយជាបន្ទាន់ មុនពេលវាកើតឡើងបន្ថែមទៀត។ «ស្របពេលដែលបច្ចេកវិទ្យាកាន់តែមានភាពរីកចម្រើន និងការប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតមានការពេញនិយមនោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញបានក្លាយជាក្តីបារម្ភថ្មីមួយទៀត ដែលទាមទារឱ្យភាគីពាក់ព័ន្ធចាំបាច់ត្រូវធ្វើការរួមគ្នាដើម្បីទប់ស្កាត់ និងការពារការរំលោភបំពាន

នេះ។ កុមារកម្ពុជាមួយចំនួនកំពុងប្រើប្រាស់ទូរស័ព្ទដៃវៃឆ្លាតអាចក្លាយជាជនងាយរងគ្រោះនៃការរំលោភបំពានតាមប្រព័ន្ធអនឡាញនេះ»។

លោកស្រី ម៉ែន វណ្ណារី មន្ត្រីសម្របសម្រួលគម្រោងប្រចាំប្រទេសកម្ពុជានៃអង្គការដែនដីមនុស្សហូឡង់ (Terre des Hommes-NL) បានថ្លែងថា តាមរយៈការវិភាគស្ថានភាពដំបូងដែលជាចំណុចចាប់ផ្តើមនៃដំណើរការដើម្បីរៀបចំផែនការសកម្មភាពជាតិលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញកុមារ ៨០% ក្នុងចំណោមកុមារប្រឈមបញ្ហាជិត ១ ០០០ នាក់បានរាយការណ៍ថា ពួកគេមិនមានអារម្មណ៍សុវត្ថិភាពទាំងស្រុងនៅលើប្រព័ន្ធអនឡាញឡើយ។ «អង្គការដែនដីមនុស្សហូឡង់មានមោទនភាពក្នុងការជួយគាំទ្រដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ក្នុងការវិភាគស្ថានភាពដំបូង នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជានេះ»។ លោកស្រីឱ្យដឹងថា ក.ជ.ក បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា និងការផ្សព្វផ្សាយនៅគ្រប់កម្រិតក្នុងឆ្នាំ ២០២០។ «កិច្ចខិតខំប្រឹងប្រែង ដែលសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះគឺទទួលបានផ្លែផ្កាល្អដែលវាចាំបាច់ត្រូវមាននិរន្តរភាពដើម្បីការពារ និងឆ្លើយតបទៅនឹងការរីករាលដាលនៃបញ្ហានេះ»៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ៥នាក់ឱ្យត្រឡប់ចូលមកកម្ពុជាវិញ បន្ទាប់ពីជាប់ទោស២ឆ្នាំពីបទឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2020-08-26 10:34am

**(ឧត្តរមានជ័យ)៖** ពលរដ្ឋខ្មែរចំនួន៥នាក់ ត្រូវបានអាជ្ញាធរប្រទេសថៃ បញ្ជូនត្រឡប់វិញមកវិញ តាមច្រកអន្តរជាតិជាំ ក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នៅល្ងាចថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០ បន្ទាប់ពីជាប់ទោស២ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់។

តាមរបាយការណ៍របស់សមត្ថកិច្ចបានបញ្ជាក់ឱ្យដឹងថា នៅម៉ោង០៣៖៣៤នាទីល្ងាចថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០ អាជ្ញាធរប្រទេសថៃ បានបញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរ ចំនួន៥នាក់តាមច្រកអន្តរជាតិជាំ បន្ទាប់ពីត្រូវទាហានថៃ ចាប់ខ្លួនកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ និងបានជាប់ទោស២ឆ្នាំក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូង តាមច្រកត្រពាំងបី ក្នុងភូមិត្រពាំងបី ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ប្រជាពលរដ្ឋខ្មែរទាំង៥នាក់ ខ្លះរស់នៅខេត្តឧត្តរមានជ័យ ខ្លះរស់នៅខេត្តព្រះវិហារ និងខ្លះទៀតរស់នៅខេត្តបន្ទាយមានជ័យ។

បន្ទាប់ពីបានស្តែនកំដៅរកមេរោគកូវីដ១៩ និងបានលាងសម្អាតខ្លួនប្រាណ ដោយទឹកអាល់កុលពីមន្ត្រីចត្តាឡីសក័ប្រចាំច្រករួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំ ឱ្យបញ្ឈប់សកម្មភាពឆ្លងដែនខុសច្បាប់តទៅទៀត និងអនុញ្ញាតឱ្យវិលត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ថៃ ចាប់បញ្ជូនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ចាំយាម ខេត្តកោះកុង

https://www.facebook.com/GDIOfficial 20-08-2020

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ខាងភាគីថៃ ចាប់បញ្ជូនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ចាំយាម ខេត្តកោះកុង។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ វង្ស សៀន ភេទ ប្រុស អាយុ ៤១ឆ្នាំ មានទីលំនៅភូមិចាំយាម ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង, ២-ឈ្មោះ ភី សុភាព ភេទ ប្រុស អាយុ ២៤ឆ្នាំ មានទីលំនៅ

ភូមិឬស្សីជុក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង, ៣-ឈ្មោះ ពេជ នឿន ភេទ ប្រុស អាយុ ៤៥ឆ្នាំ មានទីលំនៅភូមិព្រះម្លូ ឃុំព្រៃស្រឡឹក ស្រុកពារាំង ខេត្តព្រៃវែង និង៤-ឈ្មោះ សួង ចាន់ណារ៉ា ភេទស្រី អាយុ ៤២ឆ្នាំ មានទីលំនៅភូមិ១ សង្កាត់ ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការសាកសួរ អប់រំណែនាំរួចប្រគល់ជូនមន្ត្រីចត្តាឡីស័ក ប្រចាំការមាត់ច្រក ដើម្បីអនុវត្តនិតិវិធី នូវវិធានការរបស់ក្រសួងសុខាភិបាល៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣៤នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 20-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៤នាក់ ស្រី ១៩នាក់ និងកុមារ ០១នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៦នាក់

https://www.facebook.com/GDIOfficial 20-08-2020

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥៦នាក់ ស្រី ២៦នាក់៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ០៧នាក់ តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 19-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៧នាក់ ស្រី ០៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៨នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 19-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្តាំចំនួន ៤៨នាក់ ស្រី ២៣នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់

https://www.facebook.com/GDIOfficial 19-08-2020

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់ ស្រី ៣០នាក់៕

# ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

## ដំណឹងល្អ..! ពលករក្នុងវិស័យឧស្សាហកម្មដែលចប់អាណត្តិ៣ឆ្នាំ ឬ៤ឆ្នាំ១០ខែ អាចដាក់ពាក្យស្វែងរកការងារក្នុងវិស័យកសិកម្មបាន

http://nokorwatnews.com/ 26-08-2020

ភ្នំពេញ៖ ដំណឹងល្អ..! ពលករក្នុងវិស័យឧស្សាហកម្មដែលចប់អាណត្តិ៣ឆ្នាំ ឬ៤ឆ្នាំ១០ខែ អាចដាក់ពាក្យស្វែងរកការងារក្នុងវិស័យកសិកម្មបាន។ នេះបើយោងតាមតាមសេចក្តីជូនដំណឹង របស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ដែលអង្គភាព «នគរជ្រហ្គន»ទទួលបាននៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ សូមជម្រាបជូនដំណឹងដល់បងប្អូនពលករ ពលការិនីខ្មែរដែលកំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េកាន់ប្រភេទទិដ្ឋាការ E-9 ឲ្យបានជ្រាបថា ៖ យោងតាម សេចក្តីជូនដំណឹងរបស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ ពលករ-ពលការិនីបរទេសដែលបានបញ្ចប់ អណត្តិចំនួន ០៣ ឆ្នាំ ឬ ០៤ ឆ្នាំ ១០ ខែ អាចដាក់ពាក្យស្វែងរកការងារធ្វើក្នុងវិស័យកសិកម្ម និងនេសាទ ដែលមានរយៈពេលចាប់ពី ៣០ ថ្ងៃ ដល់ ៩០ ថ្ងៃ នៅសាធារណរដ្ឋកូរ៉េ។

១. ជាពលករកាន់ប្រភេទទិដ្ឋាការ E-9 ។ លក្ខខណ្ឌសំខាន់ៗរួមមាន ៖

២. ធ្លាប់ ឬជាពលករធ្វើការក្នុងវិស័យឧស្សាហកម្ម

៣.ត្រូវដាក់ពាក្យស្វែងរកការងារធ្វើនៅមជ្ឈមណ្ឌលគាំពារពលករបរទេស ឬចុះឈ្មោះតាមគេហទំព័រ WWW.eps.go.kr។

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េបញ្ជាក់ថា៖ ពលករខុសច្បាប់ ឬពលករធ្វើការក្នុងវិស័យកសិកម្ម ឬសំណង់ មិនអាចដាក់ពាក្យបានទេ។ ចាប់ទទួលពាក្យ ចុះឈ្មោះស្វែងរកការងារធ្វើពីថ្ងៃច័ន្ទ ទី២៤ ខែសីហា ដល់ ថ្ងៃច័ន្ទ ទី០៩ ខែកញ្ញា ឆ្នាំ២០២០។ សម្រាប់ព័ត៌មានបន្ថែម សូមបងប្អូនទំនាក់ទំនងមជ្ឈមណ្ឌលគាំពារពលករបរទេសនៅតាមតំបន់ ឬ ស្ថានឯកអគ្គរាជទូតកម្ពុជាតាមរយៈលេខទូស័ព្ទ ០២ ៣៧៨៥ ១០៤១៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩០នាក់

https://www.facebook.com/GDIOfficial 24-08-2020

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩០នាក់ ស្រី ៤២នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣០នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 24-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣០នាក់ ស្រី ១៨នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៤នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 24-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៤នាក់ ស្រី ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរចំនួន ០២នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 23-08-2020

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរវិលត្រឡប់ពីប្រទេសថៃ ចូលមកតាមអូរច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ចំនួន ០២នាក់ ស្រី ០២នាក់ និងបានសហការជាមួយផ្នែកចត្តាឡីស័ក ធ្វើការអប់រំណែនាំ និងពិនិត្យកំដៅជូនពួកគាត់ រួចបានប្រគល់អ្នកទាំងពីរនាក់ខាងលើ ជូនទៅមន្រ្តីចត្តាឡីស័ក ដើម្បីអនុវត្តតាមនីតិវិធីបន្ត។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ និងអន្តរជាតិ ចូល-ចេញ ឆ្លងកាត់នៅឡើយទេ ចំពោះរថយន្តដឹកជញ្ជូនទំនិញ គឺអនុញ្ញាតឲ្យ ចូល-ចេញ ជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៤នាក់

https://www.facebook.com/GDIOfficial 23-08-2020

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៤នាក់ ស្រី ១៥នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៣៨នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 22-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៨នាក់ ស្រី ១៥នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៥នាក់

https://www.facebook.com/GDIOfficial 22-08-2020

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៥នាក់ ស្រី ៥៨នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន២នាក់ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤២នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 22-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤២នាក់ ស្រី ១១នាក់ និងកុមារ ០៥នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤០នាក់ បានធ្វើដំណើរវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 21-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤០នាក់ ស្រី ២០នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩០នាក់

https://www.facebook.com/GDIOfficial 21-08-2020

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូ ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន៩០នាក់ ស្រី៥០នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃនិងលិខិតបញ្ជាក់សុខភាព៕

# ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

## កិច្ចប្រជុំប្រចាំខែសីហារបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោះស្រាយបញ្ហាប្រឈមកន្លងមក

https://www.facebook.com/deputygovernoryousophear/ 28-08-2020

នារសៀលថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានរៀបចំប្រជុំប្រចាំខែសីហា ឆ្នាំ២០២០ ក្រោមកិច្ចដឹកនាំរបស់លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ដោយមានការអញ្ជើញចូលរួមពីលោក លោកស្រី ជាសមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរ អង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធ ចំនួន ៥៨នាក់ចូលរួម ។ កិច្ចប្រជុំបានពិនិត្យទៅលើកំណត់ហេតុ និងត្រួតពិនិត្យលើផែនការដែលអង្គប្រជុំដែលបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំខែកក្កដា ឆ្នាំ២០២០កន្លងទៅ និងធ្វើការពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជាធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្ប៉តអប់រំ ការផ្សាយតាមវិទ្យុ ទូរទស្សន៍ ជាដើម។ល។ បន្ថែមពីនេះ ក៏មានការស៊ើបអង្កេត និងបង្ក្រាបបទល្មើស ដើម្បីយកទៅផ្តន្ទាទោសតាមនីតិវិធីច្បាប់បានរាល់ករណីផងដែរ។

ក្នុងកិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្តោតលើបញ្ហាដែលនៅតាមមូលដ្ឋានក្រុង ស្រុកជួបប្រទះ ដើម្បីជាគោលដៅក្នុងការដោះស្រាយឲ្យបានរួចរាល់ បញ្ហាប្រឈមរបស់គ្រួសារជនរងគ្រោះដោយការរំលោភសេពសន្ថវៈ ត្រូវគ្រួសារជនជាប់ចោទធ្វើការគម្រាមកំហែងធ្វើឲ្យគ្រួសារជនរងគ្រោះមានការភ័យក្លាច។

ក្នុងនោះដែរ លោកស្រី យូ សុភា ក៏បានលើកនូវចំណុចសំខាន់ៗមួយចំនួនដែលជាទិសដៅសម្រាប់ការអនុវត្តនៅខែបន្តហើយក៏បានស្នើឲ្យមានកិច្ចសហការជាមួយអង្គការដៃគូ ព្រមទាំងរៀបចំបើកវគ្គបណ្តុះបណ្តាលការកំណត់អត្តសញ្ញាណជនរងគ្រោះនៅថ្នាក់ក្រុង ស្រុក និង ដល់ក្រុមយុវជនក្នុងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និង ច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និង ផ្សព្វផ្សាយបន្តដល់យុវជននៅតាម សាលារៀនទាំង១២ ក្រុង ស្រុក បន្ទាប់ពីបើកដំណើរការសិក្សានៅតាមគ្រឹះស្ថានសិក្សារដ្ឋវិញ ។ លោកស្រីក៏បានបញ្ជាក់ថារបៀបវារៈកិច្ចប្រជុំក្នុងខែ កញ្ញាខាងមុខ គឺលើកឡើងពីការងារយុត្តិធម៌ ព្រហ្មទណ្ឌ ដើម្បីធ្វើការពង្រឹងទៅលើការអនុវត្តច្បាប់ ការផ្តល់សេវាកម្ម ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងពង្រឹងសមត្ថភាពក្រុមការងារនៅថ្នាក់ក្រុង ស្រុក ឃុំសង្កាត់ ពាក់ព័ន្ធនឹងការអនុវត្តតួនាទី ភារកិច្ច និង ច្បាប់ពាក់ព័ន្ធ ។ ម្យ៉ាងទៀត រដ្ឋបាលក្រុង ស្រុក និង អ្នកពាក់ព័ន្ធត្រូវពិនិត្យលើបញ្ហាជនបរទេស( ជនជាតិឥណ្ឌា) ប្រកបអាជីវកម្ម ដើររាប់លុយពីប្រជាពលរដ្ឋ ឬហៅថាការចង់ការប្រាក់ នៅតាមមូលដ្ឋានផងដែរ ៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ១៧នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 27-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១៧នាក់ ស្រី ១០នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៣៦នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 27-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៦នាក់ ស្រី ១៧នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតស្លាបឆ្វេង ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនខុសច្បាប់ ចូលមកប្រទេសចំនួន ០២នាក់

https://www.facebook.com/GDIOfficial 27-08-2020

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៨និង៣៥នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានចុះល្បាតស្លាបឆ្វេង ពិនិត្យឃើញពលរដ្ឋខ្មែរ ឆ្លងដែនខុសច្បាប់ ចូលមកប្រទេសចំនួន ០២នាក់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង ០២នាក់នេះ មាន ១-ឈ្មោះ ចំ ផារ៉ា ភេទ ស្រី អាយុ ១៨ឆ្នាំ, ២-ឈ្មោះ សំ អូន ភេទ ស្រី អាយុ ៤២ឆ្នាំ ទីលំនៅភូមិតាងួន ឃុំបរសេត ស្រុកបរសេត កំពុងស្ពឺ និងបានធ្វើការសាកសួរ អប់រំណែនាំ រួចប្រគល់ជូនមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក ដើម្បីអនុវត្តន៍នីតិវិធី នូវវិធានការរបស់ក្រសួងសុខាភិបាល៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៧នាក់

https://www.facebook.com/GDIOfficial 27-08-2020

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៧នាក់ ស្រី ៣៧នាក់៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 26-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៥នាក់ ស្រី ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៣នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 26-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិអន្តរជាតិចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៣នាក់ ស្រី ២០នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៦នាក់

https://www.facebook.com/GDIOfficial 26-08-2020

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៦នាក់ ស្រី ៤៣នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ១០នាក់ ស្រី ០៤នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប្រជាពលរដ្ឋខ្មែរចំនួន ២៧នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 25-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិចេញ-ចូលបាននោះទេ។ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២៧នាក់ ស្រី ១២នាក់ និងកុមារ ០២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ០២នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 25-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០២នាក់ ស្រី ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៩នាក់

https://www.facebook.com/GDIOfficial 25-08-2020

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៩នាក់ ស្រី ៤៧នាក់៕

## ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជួយអន្តរាគមន៍ពលករខ្មែរម្នាក់ ដែលរងគ្រោះធ្ងន់ធ្ងរដោយគ្រោះថ្នាក់ចរាចរណ៍ នៅប្រទេសម៉ាឡេស៊ី

https://www.facebook.com/tvkchannel7/ 28-08-2020

ពលករខ្មែរ ម៉ាន សូទី អាយុ២២ឆ្នាំ ដែលបានមកធ្វើការខុសច្បាប់ជាជាងដេរខោអាវ នៅរដ្ឋ Johor បានជួបគ្រោះថ្នាក់ចរាចរណ៍ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ ដោយបានជិះម៉ូតូទៅបុករនាំងចិញ្ចើមផ្លូវបណ្តាលឱ្យបែកក្បាលធ្ងន់ធ្ងរ បាក់ឆ្អឹងខ្នង និងឆ្អឹងទ្រូង (ប៉ះពាល់សួតធ្ងន់ធ្ងរ) ត្រូវការវះកាត់ជាបន្ទាន់ ហើយបច្ចុប្បន្នកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ Pakar Sultanah Fatimah នៃរដ្ឋJohor។

មន្ទីរពេទ្យបានតម្រូវឱ្យបង់ប្រាក់កក់ជាមុនសិនចំនួន ១០០០០ រីងហ្គិត (ប្រមាណ២៥០០ ដុល្លារអាមេរិក) ហើយគ្រូពេទ្យនឹងតាមដានសុខភាពរបស់អ្នកជម្ងឺរហូតដល់សួតរបស់គាត់ដំណើរការល្អឡើងវិញទើបកំណត់ថ្ងៃវះកាត់។ ដោយមានជីវភាពក្រីក្រខ្លាំង ភរិយារបស់ពលករ ឈ្មោះ កុំរី អាំមុី បានស្នើ សុំស្ថានទូតអន្តរាគមក្នុងការជួយបង់ថ្លៃវះកាត់ និងព្យាបាល។

មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី និងតំណាងអង្គការ Elshaddai Center បានចុះសួរសុខទុក្ខពលកររងគ្រោះ នៅ មន្ទីរពេទ្យ ហើយស្ថានទូតបានធ្វើកំណត់ទូតទៅមន្ទីរពេទ្យស្នើសុំបន្ធូរបន្ថយថ្លៃវះកាត់ និងការព្យាបាល។ ស្ថានទូតបានឧបត្ថម្ភថវិកាខ្លះជូនភរិយារបស់ពលកររងគ្រោះផងដែរ។ បន្ទាប់ពីបានពិភាក្សាជាមួយស្ថានទូត និងគ្រូពេទ្យ អង្គការ Elshaddai Center បានសន្យាពិនិត្យលទ្ធភាព ក្នុងការជួយឧបត្ថម្ភថ្លៃវះកាត់ព្យាបាលដល់ពលករខាងលើ។

## ស្ត្រីពលករខ្មែរម្នាក់ត្រូវថៅកែថៃបញ្ឈប់អោយធ្វើការទាំងកណ្តាលទី កំពុងបន្តសពុលភាពប័ណ្ណការងារនិងវីសាស្នាក់

https://www.facebook.com/MrPheaktraPrak 28-08-2020

ថ្ងៃនេះខ្ញុំសូមលើកយករឿងរ៉ាវ វិបត្តិរបស់ស្ត្រីពលករខ្មែរម្នាក់ត្រូវថៅកែថៃបញ្ឈប់អោយធ្វើការទាំងកណ្តាលទីកំពុងបន្តសពុលភាពប័ណ្ណការងារនិងវីសាស្នាក់។ ស្ត្រីពលករខ្មែរម្នាក់ ឈ្មោះ ហួរ ឈូក អាយុ 26ឆ្នាំ ស្រុកកំណើតរស់នៅភូមិសាំរ៉ាំង ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង បច្ចុប្បន្នជាពលករចំណាកស្រុកធ្វើការសំណង់នៅតំបន់ប្រាំមកៅ នៃទីក្រុងបាងកក ប្រទេសថៃ។ តាមសាច់រឿងស្ត្រីពលករខ្មែរខាងលើគាត់រៀបរាប់ប្រាប់យើងខ្ញុំទាំងអួលដើមករថាបច្ចុប្បន្នគាត់ធ្វើការសំណង់នៅលើអាគារ66ជាន់ មួយកន្លែងនៅកណ្តាលទីក្រុងបាងកកប្រទេសថៃ ហើយគាត់ត្រូវថៅកែថៃបង្ខំអោយឈប់ធ្វើការ នៅល្ងាចថ្ងៃព្រហស្បតិ៍ទី27 ខែសីហា ឆ្នាំ2020 ដោយសារមូលហេតុតែគាត់សុំថៅកែមិនធ្វើការនៅកន្លែងខ្ពស់ ព្រោះមូលហេតុសុខភាពគាត់មិនសូវល្អហើយមានអាការៈវិលមុខជាញឹកញាប់ការសុំរបស់គាត់បានធ្វើអោយថៅកែថៃនោះសម្រេចបញ្ឈប់ការងារគាត់ទៅវិញ ។ គាត់បានបញ្ជាក់បន្តទៀតថានៅស្អែកគាត់ត្រូវទៅដំណើរការបន្តសពុលភាពប័ណ្ណការងារ និងវីសាស្នាក់នៅជាមួយថៅកែនេះប៉ុន្តែបើគាត់បញ្ឈប់ខ្ញុំដូច្នេះតើអោយខ្ញុំធ្វើយ៉ាងណា ស្ត្រីដដែលបានរៀបរាប់ទាំងអួលដើមកថាគាត់គ្រាន់តែសុំមិនធ្វើការនៅកន្លែងខ្ពស់ហេតុអ្វីបញ្ឈប់គាត់ ។

គាត់ប្រាប់ខ្ញុំថា គាត់មានការបារម្ភយ៉ាងខ្លាំងរឿងត្រូវបន្តសពុលភាពប័ណ្ណការងារ និងវីសាស្នាក់នៅនៅស្អែកនេះ ព្រោះបើគេបញ្ឈប់ខ្ញុំត្រឹមរឿងការងារខ្ញុំមិនព្រួយបារម្ភទេប៉ុន្តែរឿងបន្តឯកសារខ្ញុំត្រូវខាងមន្ទីរការងារកំណត់ឲ្យទៅបន្តសពុលភាពនៅថ្ងៃស្អែកនេះតើខ្ញុំត្រូវធ្វើដូចម្តេច.? វិញ។ នៅព្រឹកស្អែកនេះខាងថៅកែថៃបានណាត់គាត់អោយទៅទទួលលិខិតឈប់ធ្វើការ គាត់មានការសោកស្តាយយ៉ាងខ្លាំងនូវរឿងរ៉ាវដែលកើតឡើងចំពោះគាត់ ។ ចំពោះរឿងរ៉ាវនេះដែរខ្ញុំបាទបានណែនាំអោយគាត់ទៅទំនាក់ទំនងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ អោយជួយអន្តរាគមន៍ដើម្បីទទួលបានសិទ្ធិផ្សេងពីបញ្ឈប់ការងារដោយមិនមានមូលហេតុ។ "ការចំណាកស្រុកអាចធ្វើការអោយអ្នកប្រឈមនឹងបញ្ហាគ្រប់បែបយ៉ាង ឧទាហរណ៍ដូចជាករណីខាងលើនេះដើម មុននឹងចំណាកស្រុកសូមគិតអោយច្បាស់មុនសម្រេចចិត្ត"។

# មន្ត្រីសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្ស និងសិទ្ធិការងារព្រួយបារម្ភពីបញ្ហាពលរដ្ឋខ្មែរបន្តឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.rfa.org/ ដោយ ខែ សុណង 2020-08-27

មន្ត្រីសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្ស និងសិទ្ធិការងារព្រួយបារម្ភថា ប្រសិនបើអាជ្ញាធរមិនបង្កើនការទប់ស្កាត់ពលរដ្ឋចូលទៅកាប់ឈើនៅតំបន់ព្រំដែន និងលួចឆ្លងដែនទៅរកការងារធ្វើដូចសព្វថ្ងៃទេ ប្រជាពលរដ្ឋអាចនឹងត្រូវទាហានថៃបាញ់ស្លាប់ ឬចាប់ដាក់គុកមិនដាច់ឡើយ។ ក្ដីបារម្ភនេះ បន្ទាប់ពីទាហានថៃ បានបាញ់ប្រជាពលរដ្ឋខ្មែរ ២នាក់ប្ដីប្រពន្ធរងរបួសកាលពីថ្ងៃទី១៨ កក្កដា ស្របពេលដែលមនុស្សជាច្រើននាក់នៅតែបន្តនាំគ្នាចូលទៅកាប់ឈើលក់នៅតំបន់ព្រំដែន ដោយពុំមានអាជ្ញាធរណាទប់ស្កាត់ឡើយ។ សង្គមស៊ីវិលដែលធ្វើការនៅតំបន់ជាប់ព្រំដែនកម្ពុជាថៃ អះអាងថា ពលរដ្ឋខ្មែរនៅតែប្រថុយឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ថ្វីបើដឹងថា ប្រឈមគ្រោះថ្នាក់អំឡុងពេល ភាគីថៃបន្តបិទច្រកព្រំដែនទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ក្ដី។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តឧត្តរមានជ័យ លោក ស្រី ណារ៉េន កត់សំគាល់ថា ដោយសារកត្តាបញ្ហាជីវភាពខ្វះខាតនិងគ្មានមុខរបរបានជំរុញឲ្យពលរដ្ឋខ្មែរបន្តលួចឆ្លងដែន ចូលកាប់ឈើ និងទៅស្វែងរកការងារធ្វើ នៅប្រទេសថៃជាប់ឥតដាច់ឡើយ៖«សំណាងល្អគេគ្រាន់តែដាក់ឲ្យជាប់ពន្ធនាគារទទួលទោសមួយឆ្នាំជាង ពីរឆ្នាំអីទៅ ហើយបើសំណាងអាក្រក់ភាគីថៃគេបាញ់អ៊ុំចឹងទៅ។ បើកាលណាស្លាប់ហើយគ្មាននរណាគេរកខុសត្រូវអីទៀតតាំងពីយូរមកហើយតាំងពីយើងឃ្លាំមើលនៅឆ្នាំ២០០៨ ផ្ទុះរឿងបាញ់ពលករខ្មែរដែលឆ្លងព្រំដែនមកដល់ពេលបច្ចុប្បន្នគ្រាន់តែថាដាក់កំណត់ទូតទៅតែលទ្ធផលចុងក្រោយដូចមិនឃើញមានអីផង»។

កាលពីពេលថ្មីៗ នេះប្រជាពលរដ្ឋ ២នាក់ប្ដីប្រពន្ធគឺលោកស្រី ឡាយ វាសនា លោក ផល ឆៃ រស់នៅភូមិសំបួរមាស សង្កាត់បន្សាយរាក់ ក្រុងសំរោង ត្រូវបានទាហានថៃបាញ់ឲ្យរបួសក្នុងពេលដែលពួកគាត់ចូលព្រៃកាប់ឈើនៅលើភ្នំដងរែក ជាប់ព្រំដែនថៃ។ បុរសជាប្ដីត្រូវគ្រាប់កាំភ្លើងចំកដៃ ចំណែកប្រពន្ធត្រូវចំភ្លៅខាងស្ដាំ និងកដៃខាងឆ្វេងបណ្ដាលឱ្យរបួសធ្ងន់ ហើយត្រូវបានទាហានខ្មែរប្រចាំនៅតំបន់ព្រំដែនបញ្ជូនតាមរថយន្តទៅព្យាបាលនៅមន្ទីរឯកជន នៅក្រុងសំរោង។

ជុំវិញការលួចចូលកាប់ឈើនៅចំណុចព្រំដែនកម្ពុជាថៃនេះដែរ អាជ្ញាធរថៃក៏ទើបបញ្ជូនពលរដ្ឋខ្មែរ ៥នាក់ត្រឡប់ទៅកម្ពុជាវិញ បន្ទាប់ពីអនុវត្តទោសក្នុងពន្ធនាគារខេត្តស៊ីសាកេត ចំនួន ២ឆ្នាំ ពីបទឆ្លងដែនខុសច្បាប់ កាលពីល្ងាចថ្ងៃទី២៥ ខែសីហា ។ ពួកគាត់ជាអ្នករស់នៅខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តបន្ទាយមានជ័យ ត្រូវបានទាហានថៃ ចាប់ខ្លួនកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ក្នុងគ្រាដែលពួកគាត់ចូលកាប់ឈើគ្រញូង តាមច្រកត្រពាំងបី ក្នុងភូមិត្រពាំងបី ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

មន្ត្រីទទួលបន្ទុកផ្នែកពលករចំណាកស្រុកនៃអង្គការសង់ត្រាស់ (Central) លោក ឌី ថេហូយ៉ា ថ្លែងថាកត្តាចម្បងដែលពលរដ្ឋនៅតែបន្តឆ្លងដែនចូលថៃ គឺបញ្ហាជីវភាពក្រីក្រគ្មានដីស្រែចម្ការ រួមទាំងកត្តានេកក្នុងជាជនជាតិថៃ ដែលអូសទាញឱ្យពួកគាត់ហ៊ានប្រថុយដើម្បីក្រពះ។ លោកថា មានករណីខ្លះពលរដ្ឋបានធ្លាក់ខ្លួនចាញ់បោកជនជាតិថៃដោយមិនបានប្រាក់កម្រៃថែមទៅទៀតផង។ ប៉ុន្តែអាជ្ញាធរតាមព្រំដែន និងរដ្ឋាភិបាលគួរតែធ្វើការសម្របសម្រួលណាមួយជាមួយអាជ្ញាធរថៃ ឬមានអនុសារណៈយោគយល់គ្នាឲ្យបានច្បាស់លាស់ឲ្យដាក់ទោសពលរដ្ឋត្រឹមអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ អប់រំផ្សព្វផ្សាយ និងពិន័យជាដើម មិនគួរឈានដល់ការប្រើហិង្សា និងបាញ់សម្លាប់នោះទេ៖ «ឧទាហរណ៍ថាអនុវត្តតាមច្បាប់ក៏ពិតមែនយើងអាចទទួលយកបាន បើយើងក្រឡេកមើលទៅមួយជ្រុងទៀត ក្នុងន័យមនុស្សធម៌ក្នុងន័យភាពជាមនុស្សយើងដឹងហើយគាត់ដាច់ក្រពះហើយ ដីស្រែដីចម្ការ

បង្ខំចិត្តហើយថ្មីៗ នេះយើងឃើញថាជាន់មីនទៀតវាគួរតែមានការលើកលែងចំពោះអ្នកដែលស្លូតត្រង់ទាំងអស់នេះ គាត់ក្រីក្រខ្លាំងណាស់»។ មន្ត្រីសិទ្ធិការងាររូបនេះបន្តថា ទន្ទឹមនឹងគ្នានេះ រដ្ឋាភិបាលគួរមានគោលនយោបាយគាំទ្រ អ្នកក្រីក្រដោយផ្តល់ឲ្យគាត់ទទួលបានដីស្រែចម្ការដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដែលពួកគាត់កំពុងជំពាក់បំណុលធនាគារ ហើយកំពុងប្រឈមការដាច់ស្បៀងក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ នេះ៕

## ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

### នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://cambodiapolice.com/policekh/ 10:30 am 31 សីហា 2020

**ភ្នំពេញ៖** ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នៅព្រឹកថ្ងៃចន្ទ ១៣កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០នេះ អញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការពង្រឹងវិធានការសន្តិសុខ និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងនៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានការចូលរួមពី អគ្គស្នងការរង, ប្រធាននាយកដ្ឋាន, ស្នងការ ស្នងការរងរាជធានី-ខេត្ត និងមន្ត្រីនគរបាលពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ។

ក្នុងពិធីនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានផ្តល់កិត្តិយសអញ្ជើញបំពាក់ឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនស្នងការនគរបាលខេត្ត ចំនួន៤រូបផងដែរ។ ស្នងការនគរបាលខេត្ត ដែលត្រូវបំពាក់ឋានន្តរសក្តិក្នុងឱកាសនោះរួមមាន៖

១-ឧត្តមសេនីយ៍ត្រី សម្បត្តិ សុជារដ្ឋ ស្នងការនគរបាលខេត្តកែប
២-ឧត្តមសេនីយ៍ត្រី ឈឿន សុចិត្ត ស្នងការនគរបាលខេត្តកណ្តាល
៣-ឧត្តមសេនីយ៍ត្រី អ៊ូត សីវុត្ថា ស្នងការនគរបាលខេត្តស្ទឹងត្រែង
៤-ឧត្តមសេនីយ៍ត្រី ព្រុំ សន្ធរ ស្នងការនគរបាលខេត្តព្រៃវែង៕

### ប្រជាពលរដ្ឋខ្មែរចំនួន ៦៣នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 30-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៦៣នាក់ ស្រី ២៩នាក់ និងកុមារ ០៨នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៧នាក់

https://www.facebook.com/GDIOfficial 30-08-2020

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៧នាក់ ស្រី ៤៩នាក់៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៧៥នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 29-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៧៥នាក់ ស្រី ២១នាក់ និងកុមារ ០៩នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៤៧នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 29-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៤៧នាក់ ស្រី ២២នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 29-08-2020

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូល

ប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន១០២នាក់ ស្រី ៥៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ២៨នាក់ មកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត

https://www.facebook.com/GDIOfficial 28-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ២៨នាក់ ស្រី ០៧នាក់ និងកុមារ ០២នាក់។ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ប្រជាពលរដ្ឋខ្មែរចំនួន ៥៥នាក់ បានធ្វើដំណើរចូលតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 28-08-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាម**ច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៥៥នាក់ ស្រី ២៨នាក់ និងកុមារ ០៥នាក់**។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្រ្តីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៣នាក់

https://www.facebook.com/GDIOfficial 28-08-2020

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរគ្រប់សញ្ជាតិចេញ-ចូលឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន១១៣នាក់ ស្រី៤៨នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន០៣នាក់ដោយមានឯកសារចេញពីស្ថានទូតថៃនិងលិខិតបញ្ជាក់សុខភាព៕